# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ទីផ្សារមូលបត្រៈ ឱកាសវិនិយោគ
# និងបញ្ហាប្រឈម

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ហាក់ សៀកម៉េង**

**ប្រាក់ សុខវិបុល**

សាស្ត្រាចារ្យណែនាំ

លោក **ឈុន សម្បត្តិ**


ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច

ជំនាញ គ្រប់គ្រងធុរៈកិច្ច ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ប្រាក់ សុខវិបុល និង ហាក់ សៀកម៉េង ជានិស្សិតថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្រ្ត សេដ្ឋកិច្ច ឆ្នាំទី៤ ជំនានទី១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៣-២០១៧ ដែលបានធ្វើសារណាបញ្ចប់ការសិក្សា ជាមួយនិងប្រធានបទស្តីពី ទីផ្សារមូលបត្រ៖ ឱកាសវិនិយោគ និង បញ្ហាប្រឈម សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

- លោកអ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើត ព្រមទាំងយកចិត្តទុកដាក់ក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំប្រៀនប្រដៅ ប្រកបទៅដោយក្តីស្រលាញ់ពេញចិត្ត និងពោរពេញទៅដោយព្រហ្មវិហារធម៌។ លោកបានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីផ្គត់ផ្គង់ដល់ការសិក្សារបស់ខ្ញុំបាទទាំងផ្នែកសម្ភារៈ និងស្មារតីរហូតដល់បានបញ្ចប់ថ្នាក់ឧត្តមសិក្សាដោយជោគជ័យ។
- ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរងលោក និង លោកស្រីសាស្រ្តចារ្យ ព្រមទាំងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំបង្ហាត់បង្រៀន ណែនាំ និងផ្តល់ចំណេះដឹងដល់យើងខ្ញុំអស់ពីកម្លាំងកាយចិត្ត ព្រមទាំងផ្តល់នូវដំបូន្មាន និងទស្សនល្អៗជាច្រើនសម្រាប់ការសិក្សា និងក្នុងសង្គម ដើម្បីអភិវឌ្ឍន៍ខ្លួនក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អ ជាពិសេសជាសសរទ្រូង់ជាតិ។
- ជាពិសេសយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកសាស្រ្តាចារ្យ ឈុន សម្បត្តិ ដែលបានដឹកនាំ ចង្អុលបង្ហាញ ក៏ដូចជាផ្តល់នូវយោបល់អំពីវិធីសាស្រ្តក្នុងការស្រាវជ្រាវប្រមូលពត៌មាន និងកែសម្រួលរៀបចំសារណាបញ្ចប់ការសិក្សានេះឲ្យបានសម្រេចជោគជ័យយ៉ាងប្រសើរ។
- រៀមច្បងដែលបានបន្សល់ទុកនូវស្នាដៃ ដែលមានជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយធ្វើជាគំរូ និងសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។
- ជាទីបញ្ចប់ យើងខ្ញុំទាំងអស់គ្នាសូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ ជូនចំពោះអ្នកមានគុណទាំងអស់ឲ្យជួបប្រទះ នឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋម ខ្ញុំបាទសូមលំឱនកាយ អនុញ្ញាតគោរពជម្រាបសួរលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៣-២០១៧ និងមិត្តនិស្សិត ជាទីគោរព និងស្រលាញ់រាប់អាន។

ផ្សារមូលបត្រកម្ពុជាត្រូវបានដាក់សម្ពោធឲ្យដូចញដូរជាលើដំបូងនៅ ថ្ងៃទី១៨ មេសា ២០១២ ដោយភាគហ៊ុនរបស់ក្រុមហ៊ុន រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ ការបោះផ្សាយលក់ជាលើកដំបូងនេះបានទាក់ទាញចំណាប់អារម្មណ៍របស់ប្រជាពលរដ្ឋកម្ពុជាយ៉ាងខ្លាំង ប៉ុន្តែដោយសារតែកង្វះខាតខាងចំណេះដឹងនិងបទពិសោធន៍សកម្មភាពរបស់ផ្សារក៏មានភាពស្ងប់ស្ងាត់ទៅវិញ។ ដោយសម្លឹងឃើញពី ភាពចាំបាច់នៃផ្សារមូលបត្រនៅក្នុងសេដ្ឋកិច្ច រួមជាមួយនឹងមូលហេតុដែល ធ្វើឲ្យផ្សារមូលបត្រកម្ពុជាមិនសូវមានសកម្មភាពខ្លាំងក្លានៅឡើយនោះ ខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយស្តីពី "ផ្សារមូលបត្រៈ ឱកាសវិនិយោគ និងបញ្ហាប្រឈម" ដើម្បីសរសេរជាសារណាបញ្ចប់ការសិក្សា។ នៅក្នុងសារណានេះ ខ្ញុំបាទបានបកស្រាយពីហានិភ័យ និង ឱកាសដែលវិនិយោគិនគួរពិចារណា ដើម្បីធ្វើការសម្រេចចិត្តវិនិយោគលើភាគហ៊ុនរបស់ក្រុមហ៊ុនណាមួយ គួបផ្សំនឹងកត្តាមួយចំនួនទៀត ដែលវិនិយោគិនគួរយកចិត្តទុកដាក់នៅពេលខ្លួនចូលរួមក្នុងវិស័យភាគហ៊ុន។

ខ្ញុំបាទសង្ឃឹមថា សារណាបញ្ចប់ការសិក្សាមួយនេះ នឹងក្លាយជាមិត្តដ៏ល្អ របស់និស្សិតជំនាន់ក្រោយ ក៏ដូចជាវិនិយោគិន ដែលមានចំណាប់អារម្មណ៍លើការវិនិយោគភាគហ៊ុនកម្ពុជា ដើម្បីស្វែងយល់ឲ្យបានកាន់តែស៊ីជម្រៅក្នុងវិស័យនេះ ព្រមទាំងចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ តាមរយៈទីផ្សារថ្មី ដែលទើបនឹងកើតឡើងមួយនេះ។

រាល់កិច្ចការទាំងឡាយ គឺមិនអាចជៀសផុតពីកំហុសឆ្គងបានឡើយ ដូច្នេះសូមលោកគ្រូ-អ្នកគ្រូសាស្ត្រាចារ្យ គណៈកម្មាការការពារសារណា មេត្តាសណ្តោសប្រណី ខន្តីអធ្យាស្រ័យនូវរាល់កំហុសឆ្គងដែលកើតមានឡើងដោយចេតនារបស់ខ្ញុំបាទដោយក្តីអនុគ្រោះ។ ខ្ញុំបាទនឹងរង់ចាំដោយក្តីសោមនស្សនូវរាល់ការរិះគន់ទាំងឡាយ ដើម្បីស្ថាបនា និងកែលម្អប្រធានបទនេះឲ្យមានអត្ថន័យកាន់តែល្អប្រសើរឡើង។

# មាតិកា

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ........ ២

៣.គោលបំណងនៃការស្រាវជ្រាវ ........ ៣

៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ ........ ៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៥

៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ........ ៥

## ជំពូកទី ១

## រំលឹកទ្រឹស្តី ការវិនិយោគ

១.១. និយមន័យ........ ៦

១.១.១. ការវិនិយោគពិត ........ ៦

១.១.២. ការវិនិយោគហិរញ្ញវត្ថុ........ ៦

១.១.២.១. ទ្រព្យសកម្មហិរញ្ញវត្ថុមិនអាចជួញដូរបាន (Non Marketable Financial Asset).. ៧

ក. ការដាក់ប្រាក់សន្សំ (Saving deposits) ........ ៧

ខ. ការដាក់ប្រាក់សន្សំមានកាលកំណត់ (Term Deposits or Time Deposits) ........ ៧

គ. មូលបត្រទីផ្សារហិរញ្ញវត្ថុ (Money Market Instruments) ........ ៨

១.១.២.២. ទ្រព្យសកម្មហិរញ្ញវត្ថុអាចជួញដូរបាន (Marketable Financial Assets) ........ ៩

ក. ភាគហ៊ុន ........ ៩

ខ. មូលបត្រចំណូលថេរ........ ១០

គ. មូលនិធិសង្គហ ឬមូលនិធិរួម Mutual funds........ ១០

ឃ. មូលប័ត្រដេរីវេ ឬក្លាយ Derivative Securities............................................................. ១១
១.២. ការទិញ និងលក់មូលបត្រ ...................................................................................... ១២
១.២.១. ការជ្រើសរើសក្រុមហ៊ុនជើងសារ ..................................................................... ១២
១.២.២. ការបើកគណនីជើងសារ ................................................................................. ១៣
១.២.៣. ការលក់មូលបត្ររយៈពេលខ្លី (Short Sales) ...................................................... ១៤
ក. មូលដ្ឋាននៃការលក់មូលបត្ររយៈពេលខ្លី Basics of a Short Sale ....................... ១៤
ខ. ការលក់មូលបត្ររយៈពេលខ្លី Short Sales´: Some Details................................. ១៤
១.៣. មូលដ្ឋាននៃការសម្រេចចិត្តក្នុងការវិនិយោគ The Basic of Investment Decisions................ ១៥
១.៣.១. ផលចំណេញរបស់វិនិយោគ Investment Returns................................................. ១៥
ក. ផលចំណេញជាដុល្លា Dollar Return.............................................................. ១៦
ខ. ផលចំណេញជាភាគរយ Percentage Returns .................................................. ១៦
គ. មធ្យមនព្វន្តរបស់ផលចំណេញ Average Return ............................................... ១៧
ឃ. ផលចំណេញមធ្យមនៃប័ណ្ណភាគហ៊ុន និងអត្រាគ្មានហានិភ័យ (Average stock return and risk free rate)................................................................................... ១៧
១.៣.២. ការវាស់វែងហានិភ័យ Measuring Risk .............................................................. ១៨

## ជំពូកទី ២
## ទស្សនៈទានទូទៅស្តីពីផ្សារមូលបត្រកម្ពុជា

២.១. សារតារនៃផ្សារមូលបត្រកម្ពុជា.................................................................................២០
២.២. តួអង្គសំខាន់ៗក្នុងវិស័យមូលបត្រកម្ពុជា .....................................................................២២
២.២.១. និយ័តករមូលបត្រ .........................................................................................២២
២.២.១.១. រចនាសម្ព័ន្ធគណៈគ្រប់គ្រងបច្ចេកទេស ....................................................២៣
ក. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ...........................................................................២៤
ខ. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ..........................................................២៤

គ. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ....... ២៥
ឃ. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ....... ២៦
ង. នាយកដ្ឋានកិច្ចការគតិយុត្ត ....... ២៦
ច. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ....... ២៧
ឆ. អង្គភាពសវនកម្មផ្ទៃក្នុង....... ២៨
២.២.២. ក្រុមហ៊ុនមូលបត្រ....... ២៩
២.២.២.១. ក្រុមហ៊ុនធានាទិញមូលបត្រ ....... ៣០
២.២.២.២. ក្រុមហ៊ុនពានិជ្ជករមូលបត្រ ....... ៣១
២.២.២.៣. ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ ....... ៣១
២.២.២.៤. ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ....... ៣២
២.២.៣. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ....... ៣២
២.២.៣.១. ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត....... ៣៦
២.២.៣.២. នីតិបុគ្គលប្រតិស្រុត....... ៣៦
២.២.៤. វិនិយោគិនមូលបត្រ ....... ៣៧

## ជំពូកទី ៣
## ដំណើរការវិនិយោគនៅកម្ពុជា

៣.១. និយមន័យ ....... ៣៨
៣.២. ដំណើរការនៃការវិនិយោគលើទីផ្សារមូលបត្រកម្ពុជា....... ៣៩
៣.២.១. ប្រតិបត្តិការទីផ្សារ ....... ៣៩
៣.២.១.១. ការចាប់ផ្តើមការជួញដូរ....... ៣៩
៣.២.១.២. នីតិវិធីមូលដ្ឋាននៃការជួញដូរ ....... ៤០
៣.២.១.៣. ប្រតិបត្តិការទីផ្សារ ....... ៤២

៣.២.១.៤. ការផ្សាយជាសាធារណៈនូវពត៌មានទីផ្សារ ........ ៤៩
៣.២.១.៥. ការត្រួតពិនិត្យ និងឃ្លាំមើលទីផ្សារ ........ ៥០
៣.២.២. ការផាត់ទាត់ និងការទូទាត់ ........ ៥០
៣.២.៣. ការរក្សាទុកមូលបត្រ ........ ៥២
៣.៣. ដំណើរការនៃការវិនិយោគលើឧបករណ៍និស្សន្ទ ........ ៥៣
៣.៣.១. និយមន័យឧបករណ៍និស្សន្ទ ........ ៥៣
៣.៣.២. យន្តការនៃការជួញដូរអត្រាប្តូរប្រាក់បរទេស (Forex)និងហាងឆេងមាស ........ ៥៤

## ជំពូកទី ៤

## ឱកាសវិនិយោគ និងបញ្ហាប្រឈម

៤.១. ឱកាសវិនិយោគ ........ ៥៧
៤.១.១. ឱកាសវិនិយោគសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ........ ៥៧
៤.១.១.១. ហិរញ្ញប្បទានសម្រាប់ពង្រីកការវិនិយោគ ........ ៥៧
៤.១.១.២. កេរ្តិ៍ឈ្មោះ ........ ៦០
៤.១.១.៣. លទ្ធភាពទទួលបានឥណទានពីធនាគារ ........ ៦១
៤.១.១.៤. ផលចំណេញផ្នែកពន្ធដារ ........ ៦២
៤.១.២. ឱកាសវិនិយោគសម្រាប់វិនិយោគសាធារណៈ ........ ៦២
៤.១.២.១. ផលចំណេញ ........ ៦៣
៤.១.២.២. ផលចំណេញមូលធន ........ ៦៤
៤.១.២.៣. ផលចំណេញផ្នែកពន្ធដារ ........ ៦៤
៤.១.៣.ទីផ្សារមូលបត្រជំរុញវិស័យសេដ្ឋកិច្ច ........ ៦៥
៤.១.៤. យុទ្ធសាស្រ្តទាក់ទាញការវិនយោគក្នុងវិស័យមូលបត្រ ........ ៦៦
៤.១.៤.១. ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ........ ៦៦
ក. ពន្ធលើប្រាក់ចំណេញចំពោះក្រុមហ៊ុនបោះផ្សាយមូលបត្រ ........ ៦៦

ខ. ពន្ធកាត់ទុកចំពោះវិនិយោគិនមូលបត្រ ........................................................ ៦៧
៩.១.៤.២. ការបណ្ដុះបណ្ដាល និងការផ្សព្វផ្សាយ ........................................................ ៦៧
៩.១.៤.៣. ទំនាក់ទំនងអន្តរជាតិ ........................................................ ៦៨
៩.១.៤.៤. កសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទីផ្សារមូលបត្រ ........................................................ ៦៩
៩.២. បញ្ហាប្រឈម ........................................................ ៧០
៩.២.១. អាយុកាល និងទំហំទីផ្សារ ........................................................ ៧០
៩.២.២. ស្ថានភាពនយោបាយ និងសេដ្ឋកិច្ច ........................................................ ៧០

## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

១. សេចក្ដីសន្និដ្ឋាន ........................................................ ៧២
២. ការផ្ដល់អនុសាសន៍ ........................................................ ៧៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

សេដ្ឋកិច្ចរបស់ប្រទេសជាតិមួយ រីកចម្រើនលូតលាស់ខ្លាំងទៅបាន លុះត្រាតែប្រទេសជាតិនោះមានប្រព័ន្ធហិរញ្ញវត្ថុមួយដែលមានស្ថេរភាព និងដំណើរការល្អ។ ប្រព័ន្ធហិរញ្ញវត្ថុប្រៀបបានទៅនឹងស្ពានពីរ ដែលជួយជម្រុញឲ្យសេដ្ឋកិច្ចកាន់តែមានភាពរីកចម្រើនលូតលាស់ទៅមុខ។ ប្រសិនបើគ្មានប្រព័ន្ធហិរញ្ញវត្ថុនោះទេ នោះការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រាកដជាជួបការលំបាកច្រើន ដោយសារតែការមិនអាចធ្វើឲ្យមាននូវលំហូរសាច់ប្រាក់ដែលនៅសល់ចូលទៅក្នុងការវិនិយោគ។ ជាទូទៅប្រព័ន្ធហិរញ្ញវត្ថុត្រូវបានគេបែងចែកជាពីរផ្នែកដែលរួមមានស្ថាប័នហិរញ្ញវត្ថុ (មានស្ថាប័នធនាគារ និងមិនមែនធនាគារ) និងទីផ្សារហិរញ្ញវត្ថុ។

ចំពោះប្រទេសកម្ពុជាវិញក៏មិនខុសគ្នាប៉ុន្មានដែរ ដើម្បីជួយដល់កំណើនសេដ្ឋកិច្ច គឺតម្រូវឲ្យខ្លួនមាននូវប្រព័ន្ធហិរញ្ញវត្ថុមួយដ៏រឹងមាំ និងមានស្ថិរភាពបំផុត។ ចំពោះស្ថាប័នហិរញ្ញវត្ថុនៅកម្ពុជាដោយ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា គេសង្កេតឃើញយ៉ាងច្បាស់ពីការរីកចម្រើនយ៉ាងខ្លាំងក្លានៃស្ថាប័នហិរញ្ញវត្ថុ ទាំងវិស័យធនាគារនិងមិនមែនធនាគារ។ ប៉ុន្តែចំពោះទីផ្សារហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) វិញ កម្ពុជាទើបតែអនុញ្ញាតិដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នូវទីផ្សារថ្មីមួយដែលត្រូវបានគេហៅថា ផ្សារមូលបត្រកម្ពុជា (ផ.ម.ក) ដើម្បីធ្វើការជួញដូរនូវមូលបត្រផ្សេងៗរាប់បញ្ចូលទាំងមូលបត្រកម្មសិទ្ធ មូលបត្របំណុល និងឧបករណ៍ដេរិវេទីវផ្សេងៗទៀតជាច្រើន។ ក្នុងពេលបច្ចុប្បន្ននេះ នៅលើទីផ្សារគឺមានមូលបត្រចំនួនប្រាំប្រភេទនោះគឺ ៖

- មូលបត្រកម្មសិទ្ធរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA)
- មូលបត្រកម្មសិទ្ធរបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី (GTI)
- មូលបត្រកម្មសិទ្ធរបស់ក្រុមហ៊ុន ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី (PPSP)
- មូលបត្រកម្មសិទ្ធរបស់ក្រុមហ៊ុន កំពង់ផែស្វយ័តភ្នំពេញ (PPAP)
- មូលបត្រកម្មសិទ្ធរបស់ក្រុមហ៊ុន កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS)។

ដោយសារតែប្រជាពលរដ្ឋកម្ពុជាមួយភាគធំខ្វះនូវចំណេះដឹង និងបទពិសោធន៍ដែលទាក់ទង នឹងវិស័យនេះរួមទាំងស្ថានភាពសេដ្ឋកិច្ចនៅមានភាពទន់ខ្សោយនៅឡើយនោះ វាបានធ្វើឲ្យដំណើរការរបស់ផ្សារមូលបត្រកម្ពុជាមិនសូវមានសកម្មភាពខ្លាំងក្លា និងរីកចម្រើន។ ដំណើរការនៃការបោះផ្សាយមូលបត្រ និងចុះបញ្ជីគឺ ប្រព្រឹត្តទៅយ៉ាងម៉ត់ចត់ ពីសំណាក់មន្ត្រីពាក់ព័ន្ធ ក្នុងគណៈកម្មការមូលបត្រកម្ពុជា ព្រោះដើម្បីធានាឲ្យបាននូវសុក្រឹត្យភាព ចំពោះម្ចាស់ក្រុមហ៊ុន និងអ្នកវិនិយោគលើមូលបត្រ។ ការយល់ច្បាស់ពីឱកាស និងកត្តាប្រឈមទៅលើមូលបត្រគឺមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាបានបង្ហាញពីកត្តាដែលជួយជម្រុញ និងជះឥទ្ធិពលទៅលើការវិនិយោគលើមូលបត្រ ដែលម្ចាស់ក្រុមហ៊ុន និងវិនិយោគិនគួរចាប់អារម្មណ៍ នឹងយកចិត្តទុកដាក់មុនធ្វើការបោះផ្សាយ និងវិនិយោគទៅលើមូលបត្រ។ ម្យ៉ាងវិញទៀតការដឹងច្បាស់ពីឱកាស និងបញ្ហាប្រឈមនៃមូលបត្រគឺជាសញ្ញាណមួយផងដែរ ដើម្បីជួយជម្រុញដល់ការវិនិយោគ ស្វែងរកវិធីសាស្ត្រក្នុងការកាត់បន្ថយ និងទប់ស្កាត់ហានិភ័យឲ្យស្ថិតនៅក្នុងកម្រិតមួយសមស្រប។ ហេតុដូច្នេះហើយបានជាក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសយកប្រធានបទ "ទីផ្សារមូលបត្រ ៖ ឱកាសវិនិយោគ និងបញ្ហាប្រឈម" មកធ្វើការសិក្សាស្រាវជ្រាវ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសារតែទីផ្សារមូលបត្រកម្ពុជាទើបតែចាប់ផ្តើមដំណើរការនៅឆ្នាំ ២០១១ ដូច្នេះការយល់ដឹង និងពត៌មានពីទីផ្សារមូលបត្រកម្ពុជាសម្រាប់ប្រជាពលរដ្ឋ ម្ចាស់ក្រុមហ៊ុន និងវិនិយោគិនគឺនៅមានកម្រិត។ យ៉ាងណាមិញ ទោះជាពត៌មានរបស់ទីផ្សារមូលបត្រកម្ពុជានៅមានកម្រិតសម្រាប់មហាជនក្តី ក៏ទីផ្សារមូលបត្រកម្ពុជានៅតែមានការចាប់អារម្មណ៍យ៉ាងខ្លាំង ពីសំណាក់មិត្តនិស្សិតប្រជាជនទូទៅ ហើយជាពិសេសគឺបណ្តាវិនិយោគិន និងម្ចាស់ក្រុមហ៊ុន ដែលមានចំណាប់អារម្មណ៍ក្នុងការវិនិយោគ និងចូលរួមក្នុងវិស័យមូលបត្រកម្ពុជា។ ម្យ៉ាងទៀតការទទួលបានពត៌មានពិតជាសំខាន់ណាស់ ព្រោះនៅពេលដែលកង្វះពត៌មាន វាជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់យើងផងហើយវាក៏បង្កើននូវហានិភ័យទៅលើការវិនិយោគរបស់យើងផងដែរ។ ដូច្នេះដើម្បីបង្កើនពត៌មាន និងកាត់បន្ថយហានិភ័យលើការវិនិយោគទៅលើទីផ្សារមូលបត្រកម្ពុជា ក៏ដូចជាជំនួយស្មារតី និងលើកទឹកចិត្តបន្ថែមទៅលើវិនិយោគិន ឲ្យវិនិយោគទៅលើទីផ្សារមូលបត្រកម្ពុជា និងក្រុមហ៊ុនដែល

មានបំណងបោះផ្សាយលក់ភាគហ៊ុនរបស់ខ្លួនបន្ថែមទៀត អ្នកវិនិយោគត្រូវសិក្សាអោយច្បាស់ពីមូលបត្រ និងចេះកេងយកអត្ថប្រយោជន៍របស់វា។

ដោយផ្អែកតាមបញ្ហាខាងលើនេះទើបធ្វើឲ្យមិត្តនិស្សិត និងបណ្តាលសាធារណៈជនជាច្រើនមានចម្ងល់ថា តើមានបញ្ហាប្រឈម និងឱកាសអ្វីខ្លះក្នុងការវិនិយោគទៅលើទីផ្សារមូលបត្រ? និងតើយើងអាចមើលឃើញឱកាស និងបញ្ហាប្រឈមទៅលើវិស័យមូលបត្របានរឺទេ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវ គឺដើម្បីស្វែងយល់ពីឱកាស និងបញ្ហាប្រឈមដែលទាក់ទងនឹងវិស័យមូលបត្រកម្ពុជា ព្រោះកម្ពុជាយើងទើបតែមានទីផ្សារមូលបត្រ ដែលជាហេតុទាមទារឲ្យមិត្តនិស្សិត ក៏ដូចជាវិនិយោគិន និងម្ចាស់ក្រុមហ៊ុនស្វែងយល់ និងទទួលបានពត៌មានឲ្យកាន់តែច្បាស់លាស់ទាក់ទងនឹងមូលបត្រ ហើយជាពិសេសនោះ គឺចំណេះដឹងទាក់ទងនឹងឱកាស និងបញ្ហាប្រឈមនៃមូលបត្រ។ សរុបសេចក្តីមកការសិក្សាស្រាវជ្រាវនេះ មានបំណងសំខាន់ក្នុងការសិក្សាអំពីទ្រឹស្តី ក៏ដូចជាវិធីសាស្ត្រក្នុងការស្វែងយល់ពីឱកាស និងបញ្ហាប្រឈមទៅលើមូលបត្រ និងចង់បង្ហាញអំពីអត្ថប្រយោជន៍នៃការគ្រប់គ្រងឱកាស និងបញ្ហាប្រឈមលើមូលបត្រ។ ម៉្យាងវិញទៀត យើងខ្ញុំនឹងបង្ហាញពីឱកាស និងបញ្ហាប្រឈមដែលអាចកើតមានឡើងចំពោះមូលបត្រ និងលើកយកវិធីសាស្ត្រក្នុងការគ្រប់គ្រងឱកាសនិងបញ្ហាប្រឈមរបស់គណៈកម្មការមូលបត្រកម្ពុជាគ.ម.ក។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

ដោយសារតែទីផ្សារមូលបត្រកម្ពុជាទីផ្សារថ្មី ព្រមទាំងការសិក្សាស្រាវជ្រាវមាន រយៈពេលខ្លីផងនោះ ទើបធ្វើឲ្យមានការលំបាកក្នុងការស្វែងរកឯកសារ ដូច្នេះហើយដើម្បីឲ្យសារណាបញ្ចប់ការសិក្សានេះមានភាពច្បាស់លាស់ នោះក្រុមយើងខ្ញុំសម្រេចចិត្តផ្តោតសំខាន់ទៅលើតែ "ទីផ្សារមូលបត្រ៖ ឱកាសវិនិយោគ និងបញ្ហាប្រឈម" ដែលសិក្សាតែនៅឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៦ ប៉ុណ្ណោះ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក្រុមយើងខ្ញុំនឹងលើកយកបង្ហាញផងដែលនូវ រាល់ឱកាស និងបញ្ហាប្រឈមទៅលើមូលបត្រកម្មសិទ្ធិរបស់កម្ពុជា និងដំណើរការនៃការវិនិយោគលើមូលបត្រ និងឧបករណនិស្សន្ទ័ដែលបានបង្ហាញជាលក្ខណៈទ្រឹស្តីនិងមាននៅកម្ពុជា។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះសារៈសំខាន់នៃប្រធានបទ ដែលក្រុមយើងខ្ញុំលើកយកមកធ្វើការសិក្សាស្រាវជ្រាវមានដូចជា៖

- ចំពោះមិត្តនិស្សិត និងអ្នកស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សាមួយនេះនឹងផ្តល់ជាពត៌មាន និងគំនិតខ្លះៗពីឱកាស និងបញ្ហាប្រឈមនៃវិស័យមូលបត្រ ជាពិសេសគឺផ្តល់ជាគន្លឹះដល់មិត្តនិស្សិត និងអ្នកស្រាវជ្រាវក្នុងការសិក្សាបន្ថែមក៏ដូចជាបង្កើនចំណេះដឹងរបស់ខ្លួនទាក់ទងនឹងវិស័យមូលបត្រ ព្រោះចំណេះដឹងដែលទាក់ទងនឹងវិស័យមូលបត្រគឺជា ចំណេះដឹងដែលថ្មីៗដែលទទួលបានការយកចិត្តទុក ដាក់ពីសំណាក់មហាជន។

- ចំពោះវិនិយោគិន

ប្រធានបទនេះនឹងផ្តល់ជាគំនិត និងជំនួយផ្នែកស្មារតីក្នុងការសម្រេចចិត្តទៅដល់វិនិយោគិនក្នុងការចូលខ្លួនទៅវិនិយោគលើវិស័យមូលបត្រ និងវិធីសាស្ត្រក្នុងការគ្រប់គ្រង ក៏ដូចជាវិធីសាស្ត្រមើលឃើញពីរាល់ឱកាស និងបញ្ហាប្រឈម ព្រោះនៅពេលដែលយើងដឹងច្បាស់ពីរាល់ឱកាស និងបញ្ហាប្រឈមដែលកើតមានក្នុងវិស័យមូលបត្រដែលធ្វើឲ្យវិនិយោគិនអាចធ្វើការសម្រេចចិត្តថា "តើគួរវិនិយោគឬទេ?" និង "គួរជ្រើសរើសការវិនិយោគទៅលើមូលបត្រប្រភេទណា?" និងជួយឲ្យវិនិ-យោគិនយល់ដឹងពីឱកាស និងបញ្ហាប្រឈមដើម្បីជៀសផុតពីហានិភ័យ រឺកាត់បន្ថយហានិភ័យឲ្យនៅកម្រិតមួយទាបបំផុតតាមតែអាចធ្វើបាន។

- ចំពោះបណ្តាក្រុមហ៊ុនដែលមានបំណងចង់បោះផ្សាយលក់មូលបត្រ

សារណាបញ្ចប់ការសិក្សានេះនឹងផ្តល់ជាពត៌មាន សម្រាប់បណ្តាក្រុមហ៊ុនដែលមានបំណងចង់បោះផ្សាយលក់មូលបត្រឲ្យដឹងច្បាស់ពីឱកាស និងបញ្ហាប្រឈមដែលអាចកើតមាន នៅពេលដែលខ្លួនបោះផ្សាយមូលបត្រ និងដើម្បីទាក់ទាញវិនិយោគិនមកវិនិយោគលើមូលបត្រ រឺភាគហ៊ុនដែលខ្លួនបានបោះផ្សាយ។ ព្រោះនៅពេលដែលក្រុមហ៊ុនមានយុទ្ធសាស្ត្រច្បាស់ក្នុងការបង្ហាញពីឱកាស និងបញ្ហាប្រឈមដែលឈានទៅស្វែងរកវិធីសាស្ត្រក្នុងការទប់ស្កាត់ហានិភ័យ។

- ចំពោះមហាជន ក៏ដូចជាប្រជាពលរដ្ឋទូទៅ

ផ្តល់ការយល់ដឹងបន្ថែមពីការអភិវឌ្ឍន៍សង្គមជាតិ ការរីកចម្រើននៃសេដ្ឋកិច្ច ដោយសារការរីកលូតលាស់ដ៏ឆាប់រហ័សនៃវិស័យមូលបត្រ ដោយសារមានវិធានការ និងយុទ្ធសាស្រ្តច្បាស់លាស់ក្នុងការបង្ហាញពីឱកាស និងបញ្ហាប្រឈមដែលជម្រុញឬពន្លឿននៃការរីកចម្រើនសេដ្ឋកិច្ច។ ដើម្បីឲ្យវិស័យមូលបត្រ ក៏ដូចជាសេដ្ឋកិច្ចមានការអភិវឌ្ឍន៍ទៅរកភាពថ្កុំថ្កើង គឺត្រូវធ្វើឲ្យមានភាពជឿជាក់ និងទំនុកចិត្តពីសាធារណជន និងឲ្យប្រជាពលរដ្ឋមានចំណេះដឹងហើយស្វែងយល់ច្បាស់ពីមូលបត្រ។

## ៦. វិធីសាស្រ្តនៃការស្រាវជ្រាវ

ក្នុងដំណើរការនៃការស្រាវជ្រាវចងក្រងជាសៀវភៅនេះឡើង ក្រុមយើងខ្ញុំបានអនុវត្តវិធីសាស្រ្តមួយក្នុងការប្រមូលទិន្នន័យ។ វិធីសាស្រ្តនោះគឺ៖

- ទិន្នន័យបន្ទាប់សន្សំ (Second Data) ៖ ក្នុងវិធីសាស្រ្តនេះ ក្រុមយើងខ្ញុំបានស្វែងរកឯកសារទាំងឡាយដែលទាក់ទងនឹងប្រធានបទនេះ ទាំងនៅក្នុងគណៈកម្មការមូលបត្រកម្ពុជា ផ្សារមូលបត្រកម្ពុជា ច្បាប់ អនុក្រឹត្យ ប្រកាស បទបញ្ញត្តិ តាមប្រព័ន្ធអ៊ីនធឺណេត ការណែនាំរបស់សាស្រ្តចារ្យដឹកនាំ និក្ខេបបទរបស់និស្សិតរៀមច្បង និងស្វែងរកឯកសារផ្សេងៗតាមបណ្ណាល័យនានាជាដើម។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ការសិក្សានេះត្រូវបានបែងចែកដូចខាងក្រោម៖

- សេចក្តីផ្តើម
- ជំពូកទី១ រំលឹកទ្រឹស្តីការវិនិយោគ
- ជំពូកទី២ ទស្សនៈទានទូទៅស្តីពីផ្សារមូលបត្រកម្ពុជា
- ជំពូកទី៣ ដំណើរការវិនិយោគនៅកម្ពុជា
- ជំពូកទី៤ ឱកាសវិនិយោគ និងបញ្ហាប្រឈម
- សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី១
# រំលឹកទ្រឹស្តី ការវិនិយោគ

## ១.១. និយមន័យ

ការវិនិយោគ គឺជាការប្រើប្រាស់ ឬការចំណាយមូលនិធិដោយរំពឹងថានឹងទទួលបានចំណូល ឬការកើនឡើងជាទុន(Increase in capital) អំពីវិនិយោគនោះនៅពេលអនាគត។

ការវិនិយោគ គឺជាការប្រើប្រាស់សាច់ប្រាក់ដើម្បីបង្កើនសាច់ប្រាក់ (The use of money for making more money)។

ការវិនិយោគ គឺជាការផ្តល់ប្រភពធនធាននាពេលបច្ចុប្បន្នដោយសង្ឃឹមថានឹងទទួលបានមកវិញនូវប្រភពធនធានកើនឡើង ឬធ្វើអោយដំណើរការរបស់ក្រុមហ៊ុនកាន់តែប្រសើរឡើងនាពេលអនាគត។នៅក្នុងដំណើរការនៃការវិនិយោគគេបានបែងចែកការវិនិយោគជាពីរគឺ ការវិនិយោគពិត និងវិនិយោគហិរញ្ញវត្ថុ។

### ១.១.១. ការវិនិយោគពិត

ការដាក់ទុនវិនិយោគលើ អចលនទ្រព្យ(Real Estate) គេអោយឈ្មោះថា ការវិនិយោគពិត។ ដោយសារមនុស្សមួយចំនួនបានយកដើមទុនរបស់ពួកគេទៅវិនិយោគលើទ្រព្យសម្បត្តិពិត ដូចជា សង់សណ្ឋាគារ ឬផ្ទះសំណាក់សំរាប់ជួល ទិញដីរាប់ហិចតាដើម្បីសង់ផ្ទះល្វែង ឬសម្រាប់លក់ចេញទៅវិញដើម្បីប្រាក់ចំណេញ សង់រោងចក្រសំរាប់ផលិតកម្ម ទិញរថយន្តក្រុងសំរាប់បំរើសេវាឈ្នួល។ល។ ការធ្វើវិនិយោគរបស់បុគ្គលខាងលើនេះត្រូវបានចាត់ទុកជាប្រភេទវិនិយោគពិត។ បច្ចុប្បន្ននេះ នៅប្រទេសជឿនលឿនមួយចំនួន អ្នកវិនិយោគបានចាប់អារម្មណ៍ដាក់ទុនវិនិយោគ លើអចលនទ្រព្យមួយចំនួនដូចជា: សង់ផ្ទះជួល សង់អាគារការិយាល័យជួល ដីសំរាប់ធ្វើកសិកម្ម ជាដើម។

### ១.១.២. ការវិនិយោគហិរញ្ញវត្ថុ

តាមន័យវិនិយោគ គេចាត់ទុកប្រភេទវិនិយោគបែបហិរញ្ញវត្ថុ គឺរាល់ការដាក់ទុនលើឧបករណ៍ហិរញ្ញវត្ថុ (Financial Instruments) ដូចជា ភាគហ៊ុន សញ្ញាប័ណ្ណក្រុមហ៊ុន សញ្ញាប័ណ្ណរដ្ឋាភិបាល។ល។

បើសិនជាយើងមិនអាចមានចំណែកជា ម្ចាស់ក្រុមហ៊ុនលើក្រុមហ៊ុនទាំងមូលបាន យើងក៏អាចមានចំណែកជាម្ចាស់លើក្រុមហ៊ុនបានមួយភាគដែរ។ មានន័យថា បើយើងគ្មានលទ្ធភាពបង្កើតក្រុមហ៊ុនដោយខ្លួនឯងនោះទេ យើងក៏អាចចូលរួមទិញភាគហ៊ុននៅក្នុងក្រុមហ៊ុនសាជីវកម្មមួយទៀតបាន ហើយយើងក៏នឹងអាចទទួលបានចំណែកជាម្ចាស់តាមសមាមាត្រទុនដែលយើងបានធ្វើឬដាក់ទុនវិនិយោគនោះដែរ។ បន្ថែមលើនេះទៀតយើងអាចទិញសញ្ញាប័ណ្ណពីក្រុមហ៊ុនណាមួយ ឬទិញមូលបត្រក្លាយ (Derivative Securities) លើទីផ្សារហិរញ្ញវត្ថុដែលការធ្វើវិនិយោគបែបនេះគេអោយឈ្មោះថា ការធ្វើវិនិយោគបែបហិរញ្ញវត្ថុ។

**១.១.២.១. ទ្រព្យសកម្មហិរញ្ញវត្ថុមិនអាចជួញដូរបាន** (Non Marketable Financial Assets)

អ្នកវិនិយោគអាចប្រើប្រាស់ទុនរបស់ខ្លួនវិនិយោគលើ ទ្រព្យសកម្ម ដែលមិនអាចលក់ដូរបាន ដូចជា ការដាក់ប្រាក់សន្សំ ការដាក់ប្រាក់សន្សំមានកាលកំណត់ និងមូលបត្រទីផ្សារហិរញ្ញវត្ថុ។

**ក. ការដាក់ប្រាក់សន្សំ** (Saving deposits)

ការដាក់ប្រាក់សន្សំ ជាប្រភេទវិនិយោគមានលក្ខណៈងាយស្រួលគឺគ្រាន់តែទៅបើកគណនីសន្សំនៅធនាគារ ហើយដាក់ប្រាក់ក្នុងគណនីសន្សំនោះ។ នៅក្នុងធនាគារមានប្រភេទគណនីជាច្រើនដូចជា Current account Saving account Time deposits…។ ដាក់ប្រាក់ក្នុង Current account ពុំបានទទួលការប្រាក់ទេ ប៉ុន្តែដើម្បីទទួលបានការប្រាក់ចាំបាច់ត្រូវដាក់ប្រាក់ក្នុង Saving account or Time deposit account។ អតិថិជនអាចដាក់ ឬដកប្រាក់ពីគណនីសន្សំតាមតំរូវការអាស្រ័យនឹងទឹកប្រាក់ដែលយើងមាន។ ការប្រាក់ទទួលបានពីការវិនិយោគលើ Saving account ប្រែប្រួលតាមបរិមាណទឹកប្រាក់ និងពេលវេលា។ ជាទូទៅ ធនាគារផ្តល់អត្រាការប្រាក់ទាបចំពោះប្រភេទគណនីសន្សំគ្មានកាលកំណត់នេះ។ ប៉ុន្តែគេមានជំរើសជាច្រើនទៀតទាក់ទងនឹងការវិនិយោគនេះ។ ដើម្បីទទួលបានការប្រាក់ច្រើនចាំបាច់ដាក់ប្រាក់ក្នុងគណនី Saving account រយៈពេលយូរ និងច្រាសមកវិញ។

**ខ. ការដាក់ប្រាក់សន្សំមានកាលកំណត់** (Term Deposits or Time Deposits)

ការដាក់ប្រាក់សន្សំមានកាលកំណត់ ការវិនិយោគប្រភេទនេះគឺមានលក្ខណៈប្រហាក់ប្រហែលនឹងការដាក់ប្រាក់សន្សំដែរ ប៉ុន្តែវាមានលក្ខណៈពិសេសដោយឡែកបន្តិចគឺ:

- គេកំណត់អោយដាក់សន្សំ ក្នុងគណនីនេះលើបរិមាណទឹកប្រាក់យ៉ាងតិចពី $1,000 ទៅ $5,000 ប៉ុន្តែមិនអោយលើស $100,000 នៅប្រទេសអាមេរិក ។ ទឹកប្រាក់ដាក់សន្សំ ចាប់ពី

$100,000 ឡើងទៅគេចាត់ទុកថាជាការសន្សំ នៅក្នុង CDs ដែលត្រូវមានបែបបទដោយឡែក។ ប៉ុន្តែនៅប្រទេសកម្ពុជាយើងវិញធនាគារអេស៊ីលីដា (ACLEDA Bank) បានកំនត់ទឹកប្រាក់អប្បរបមា $500 សំរាប់បើកគណនីសន្សំមានកាលកំណត់នេះ។ ដោយឡែក ANZ Royal Bank កំណត់ទឹកប្រាក់លើសពី $2,000 ដោយផ្តល់ការប្រាក់ 6 ខែម្តង ហើយគិតអត្រាការប្រាក់ចំនួន 4% ក្នុងមួយឆ្នាំ។

- អត្រាការប្រាក់លើការសន្សំ ប្រភេទនេះគឺមានអត្រាខ្ពស់ជាងអត្រាការប្រាក់ដែលគេបានអនុវត្តនៅការដាក់ប្រាក់សន្សំគ្មានកាលកំណត់ ហើយអត្រាការប្រាក់ទាំងនេះប្រែប្រួលតាមធនាគារ។

- ក្រោយពីបានដាក់ប្រាក់ក្នុងគណនីសន្សំមានកាលកំណត់ហើយ អតិថិជនមិនអនុញ្ញាតអោយដកប្រាក់មុនកាលបរិច្ឆេទកំណត់នោះទេ។ ប្រសិនបើមានតំរូវការចាំបាច់ហើយអ្នកដាក់ប្រាក់ចង់ដកមុនកាលបរិច្ឆេតកំណត់ ក្នុងករណីនេះ ធនាគារពិន័យអោយខាតបង់លើការប្រាក់ជាច្រើន។ នៅប្រទេសកម្ពុជាយើងមានករណីលើកលែងខ្លះដែរចំពោះធនាគារពាណិជ្ជខ្លះ។ ក្នុងករណីណាមួយដែលអតិថិជនត្រូវការប្រាក់ជាបន្ទាន់នោះ ធនាគារនឹងមានគោលការណ៍មួយដាច់ដោយឡែកដោយតំរូវអោយអតិថិជននោះខ្ចីពីធនាគារវិញ ដោយធនាគារសំអាងថាអតិថិជនមានប្រាក់គ្រប់គ្រាន់នៅក្នុងគណនីរបស់ខ្លួន ដែលតាមធម្មតាការខ្ចីលុយពីធនាគារមានបែបបទច្រើនហើយខ្លះទាមទាររបស់បញ្ចាំ ចំពោះស្រុកយើងដែលមានហានិភ័យខ្ពស់។ ក្នុងករណីនេះធនាគារយកការប្រាក់តាមរយៈពេលដែលអតិថិជនបានខ្ចីយកទៅប្រើប្រាស់ដោយគិតតាមអត្រាអោយខ្ចី។

### គ. មូលបត្រទីផ្សាររូបិយវត្ថុ (Money Market Instruments)

ជាមូលបត្រ (Securities) ដែលមានរយៈពេលតិចជាងមួយឆ្នាំចេញផ្សាយលក់ដោយក្រុមហ៊ុនសាជីវកម្ម និងរដ្ឋាភិបាលដើម្បីទទួលបានមូលនិធិរយៈពេលខ្លី។ មូលបត្ររបស់ទីផ្សាររូបិយវត្ថុមាន ៣ ដូចខាងក្រោម ៖

- ប័ណ្ណរតនាគាររយៈពេលខ្លី (T-bills)
- ផលប័ត្រពាណិជ្ជកម្ម (Commercial paper)
- សញ្ញាបណ្ណបំណុល (Certificate of deposits)

### ១.១.២.២. ទ្រព្យសកម្មហិរញ្ញវត្ថុអាចជួញដូរបាន (Marketable Financial Assets)

**ក. ភាគហ៊ុន** (Stock)

ភាគហ៊ុន គឺជាមូលបត្រដែលតំណាងអោយចំណែកនៃទុនរបស់ភ្នាក់ងារសេដ្ឋកិច្ចដែលបានដាក់ទុនវិយោគ ហើយនឹងចំណែកនៃកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនសាជីវកម្មនោះ។

ភាគហ៊ុន គឺជាទុនផ្ទាល់របស់ក្រុមហ៊ុនមួយ។ រាល់ភាគហ៊ុននីមួយៗគឺតំណាងអោយចំណែកនៃមូលធនដែលអ្នកវិនិយោគមាន ឬបានដាក់ទុនវិនិយោគលើក្រុមហ៊ុននោះ។ ម្ចាស់កាន់កាប់ភាគហ៊ុនទាំងអស់មានសិទ្ធិចូលរួមទទួលចំណូលរបស់អាជីវកម្ម តាមរយៈការបែងចែកភាគលាភ (Dividends) ឬ មូលធនចំណេញនៅក្នុងតំលៃដែលបានកាន់កាប់ភាគហ៊ុននោះ។ ភាគលាភ (Dividends) គឺជាចំណែកនៃប្រាក់ចំណេញទទួលបានដោយក្រុមហ៊ុនហើយត្រូវបែងចែក ទៅម្ចាស់ភាគហ៊ុនម្នាក់ៗតាមសមាមាត្រនៃទឹកប្រាក់ដែលគាត់បានធ្វើវិនិយោគ លើភាគហ៊ុនរបស់ក្រុមហ៊ុននោះ។ ចំណែកឯការចំណេញ ឬខាតមូលធន គឺទទួលបានមកពីការលក់ភាគហ៊ុនដែលបានវិនិ-យោគនោះ។

ភាគហ៊ុនមិនដូចមូលបត្រចំណូលថេរនោះទេ។ បើសិនជាក្រុមហ៊ុនទទួលបានជោគជ័យលើអាជីវកម្មរបស់ខ្លួន (អត្រាប្រាក់ចំណេញខ្ពស់ និង មាននយោបាយបែងចែកភាគលាភល្អ) នោះថ្លៃរបស់ភាគហ៊ុននឹងកើនឡើង ហើយប្រសិនបើក្រុមហ៊ុនមិនបានជោគជ័យលើអាជីវកម្មរបស់ខ្លួននោះទេនោះវានឹងធ្វើអោយថ្លៃភាគហ៊ុនរបស់ក្រុមហ៊ុននឹងធ្លាក់ចុះ។ សរុបមកការ វិនិយោគលើភាគហ៊ុនគឺមានហានិភ័យច្រើនជាងការវិនិយោគលើមូលបត្រចំណូលថេរ (Fixed Income Securities)។

ចំពោះក្រុមហ៊ុនសាជីវកម្មមួយ បើតាមទស្សនៈរបស់អាជីវកម្ម ការចេញផ្សាយលក់ភាគហ៊ុនគឺជាការទទួលបាននូវប្រភពមូលនិធិ ឬប្រភពហិរញ្ញវត្ថុរយៈពេលវែងដែលបង្កលក្ខណៈងាយស្រួលដល់ការធ្វើហិរញ្ញប្បទានដាក់ស្តែងដូចជាការចំណាយក្នុងសំណង់ ការទិញសំភារៈបរិក្ខារ និង ការចំណាយផ្សេងៗទៀត។

ភាគហ៊ុនមួយប្រភេទទៀតគឺភាគហ៊ុនអាទិភាពដែលមានលក្ខណៈដូចគ្នានឹងភាគហ៊ុនធម្មតាដែរ តែអ្នកកាន់ភាគហ៊ុនអាទិភាពពេលបែងចែកភាគលាភគឺទទួលបានមុនគេ ហើយត្រូវបានកំណត់ជាដំបូងគឺថេរ លើទឹកប្រាក់កំណត់មួយ។ បន្ថែមលើនេះអ្នកកាន់ភាគហ៊ុនអាទិភាពពុំមានសិទ្ធិបោះឆ្នោតផ្សេងៗក្នុងក្រុមហ៊ុនទេ។ ការធ្វើវិនិយោគដោយទិញភាគហ៊ុនអាទិភាព គឺទទួល

បានភាគលាភថេរ និងអាចទទួលបានចំណេញមូលធន ក្នុងតំលៃទីផ្សាររបស់ភាគហ៊ុននោះឡើងថ្លៃនៅពេលគេចង់លក់។

### ខ. មូលបត្រចំនូលថេរ

មូលបត្រចំណូលថេរ គឺជាមូលបត្រដែលសន្យាផ្តល់ចំនូលចរន្តថេរ ឬចំនូលចរន្តដែលត្រូវបានកំណត់ដោយបែបបទជាក់លាក់មួយ។ មូលបត្រដែលជាការសន្យាផ្តល់ចំណូលថេរដល់អ្នកវិនិ-យោគរួមមាន សញ្ញាប័ណ្ណ ភាគហ៊ុនអាទិភាព និង មូលបត្រអាចប្តូរទៅជាភាគហ៊ុនធម្មតាបាន។

- **សញ្ញាប័ណ្ណ** (Bonds)

សញ្ញាប័ណ្ណ គឺជាបំណុលរយៈពេលវែងចេញផ្សាយលក់ដោយក្រុមហ៊ុនសាជីវកម្មនិង រដ្ឋា-ភិបាល។ អ្នកចេញផ្សាយលក់សញ្ញាប័ណ្ណចុះកិច្ចសន្យាត្រូវទូទាត់ការប្រាក់ និងប្រាក់ដើមនៅកាលបរិច្ឆេទកំណត់ជាក់លាក់។

- **មូលបត្រអាចទៅជាភាគហ៊ុនធម្មតាបាន** (Convertible Securities)

មូលបត្រអាចទៅជាភាគហ៊ុនធម្មតាបាន រួមមាន សញ្ញាប័ណ្ណអាចទៅជាភាគហ៊ុនធម្មតា និងភាគហ៊ុនបុរិមាអាចទៅជាភាគហ៊ុនធម្មតា ដែលផ្តល់នូវចំណូលថេរ (ការប្រាក់ថេរ និង ភាគលាភថេរ) ហើយអាចប្តូរទៅជាភាគហ៊ុនធម្មតាក្នុង ករណីអ្នកវិនិយោគចង់ផ្លាស់ប្តូរដោយមានការព្រមព្រៀងពីក្រុមហ៊ុន។ពេលខ្លះអ្នកវិនិយោគត្រូវចំណាយប្រាក់បង់ថែមពីលើ ក្នុងប្រតិបត្តិការផ្លាស់ប្តូរទៅអោយក្រុមហ៊ុនអ្នកចេញផ្សាយលក់ភាគហ៊ុនធម្មតា។

- **ភាគហ៊ុនបុរិមា** (Preferred Stock)

ភាគហ៊ុនអាទិភាពដែលមានលក្ខណៈដូចគ្នានឹងភាគហ៊ុនធម្មតាដែរ តែអ្នកកាន់ភាគហ៊ុនអាទិភាពពេលបែងចែកភាគលាភគឺទទួលបានមុនគេ ហើយត្រូវបានកំណត់ជាដំបូងគឺថេរ លើទឹកប្រាក់កំណត់មួយ។ បន្ថែមលើនេះអ្នកកាន់ភាគហ៊ុនអាទិភាពពុំមានសិទ្ធិបោះឆ្នោតផ្សេងៗក្នុងក្រុមហ៊ុនទេ។ ការធ្វើវិនិយោគដោយទិញភាគហ៊ុនអាទិភាព គឺទទួលបានភាគលាភថេរ និងអាចទទួលបានចំណេញមូលធន ក្នុងតំលៃទីផ្សាររបស់ភាគហ៊ុននោះឡើងថ្លៃនៅពេលគេចង់លក់។

### គ. មូលនិធិសង្គហ ឬមូលនិធិរួម (Mutual funds)

មូលនិធិសង្គហ ឬមូលនិធិរួម គឺជាក្រុមហ៊ុនដែលគ្រប់គ្រង និង វិនិយោគទុនសម្រាប់ម្ចាស់ភាគហ៊ុនដែលរួមទុនគ្នា។ ដោយអ្នកវិនិយោគតូចតាច (Small investors) មិនអាចទិញមូលបត្រនៅលើទីផ្សារបានដោយសារប្រភពទុនរបស់គេដូចនេះគេត្រូវប្រមូលផ្តុំគ្នាដាក់ទុនដោយបង្កើត ជាមូល

និធិរួមហើយអាចធ្វើវិនិយោគចំរុះឬពហុវិនិយោគ (Diversification) ដើម្បីកាត់បន្ថយហានិភ័យ ។ អ្នកវិនិយោគទទួលបានប្រាក់ចំណេញតាមចំណែកដែលខ្លួនបានវិនិយោគ។ ដើម្បីគ្រប់គ្រងមូលនិធិរួម គេត្រូវជ្រើសរើសអ្នកគ្រប់គ្រងដែលមានបទពិសោធន៍។

**ឃ. មូលបត្រដេរីវេទីវ ឬភ្ជាយ** (Derivative Securities)

បន្ថែមលើការវិនិយោគលើភាគហ៊ុន ឬសញ្ញាប័ណ្ណដែលត្រូវបានចាត់ទុកជាប្រភេទវិនិយោគបែបហិរញ្ញវត្ថុនោះ គឺអ្នកវិនិយោគអាចដាក់ទុនវិនិយោគរបស់ខ្លួនលើមូលប័ត្រដេរីវេទីវដទៃទៀត មានដូចជា Option, Swap Forward, Future… ដែលត្រូវបានគេឲ្យឈ្មោះថាមូលបត្រដេរីវេទីវ ។ មូល-បត្រដេរីវេទីវ បានក្លាយជាផ្នែកមួយនៃផលិតផលហិរញ្ញវត្ថុដ៏ទៃទៀតសំរាប់អ្នកធ្វើវិនិយោគលើទី-ផ្សារហិរញ្ញវត្ថុក្នុងពេលបច្ចុប្បន្ននេះ នៅសហរដ្ឋអាមេរិក។ ការប្រើប្រាស់មូលបត្រដេរីវេទីវ ជាលើកដំបូងនៅសហរដ្ឋអាមេរិកគឺដើម្បីការពារហានិភ័យតែប៉ុននោះ។

- Option: គឺជាសិទ្ធិតែមិនមែនជាកាតព្វកិច្ចក្នុងការទិញ ឬលក់ទ្រព្យ ក្នុងតម្លៃកំណត់មួយនៅកាលបរិច្ឆេទមួយកំណត់។ Option ត្រូវបានបែងចែកជា Call option និង Put option។ Call option ផ្តល់សិទ្ធិក្នុងការទិញទ្រព្យសកម្ម ថ្លៃកំណត់មួយព្រមព្រៀងលើកិច្ចសន្យា នៅកាលបរិច្ឆេទកំណត់មួយហៅថា Exercise price or Strike price។ ចំណែកឯ Put option ផ្តល់ជូនសិទ្ធិក្នុងការលក់ទ្រព្យ លើថ្លៃកំណត់មួយនៅកាលបរិច្ឆេទកំណត់ជាក់លាក់។

- Forward: គឺជា កិច្ចសន្យាដែលក្នុងនោះគេអាចទិញ ឬលក់បរិមាណទំនិញ ឬផលិតផលដែលកំណត់ថ្លៃ និងបរិមាណនៅថ្ងៃនេះ ហើយប្រតិបត្តិការគឺនឹងត្រូវធ្វើនៅពេលក្រោយ។ គ្រប់លក្ខ-ខ័ណ្ឌទាំងអស់ត្រូវបានកំណត់នៅថ្ងៃនេះនៅក្នុងកិច្ចសន្យារវាងភាគីលក់ និងអ្នកទិញ។ ដល់កាលបរិច្ឆេទកំណត់អ្នកលក់មានកាតព្វកិច្ចប្រគល់ទំនិញ ឬផលិតផលតាមកិច្ចសន្យាកំណត់ហើយអ្នកទិញត្រូវទូទាត់លើថ្លៃព្រមព្រៀងនោះ ទោះបីដល់ថ្ងៃកំណត់នោះថ្លៃមានការប្រែប្រួលឡើង ឬចុះយ៉ាងណាក៏ដោយ។

ក្នុងពេលបច្ចុប្បន្នមូលបត្រដេរីវេទីវ ត្រូវបានគេពេញនិយមប្រើប្រាស់យ៉ាងទូលំទូលាយលើប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិដូចជា ក្រុមហ៊ុនមួយត្រូវលក់ទំនិញទៅក្រៅប្រទេសដោយជឿអោយក្រុមហ៊ុនមួយទៀត ហើយតំរូវអោយទូទាត់ជារូបិយវត្ថុបរទេស។ ក្នុងករណីនេះ ក្រុមហ៊ុនលក់ទំនិញចាំបាច់ត្រូវទិញ Options ឬ Forward ដើម្បីការពារហានិភ័យដែលអាចកើតមានដោយសារមាន

ការប្រែប្រួលអត្រាប្តូរប្រាក់រវាងប្រទេសទាំងពីរ។ បន្ថែមលើនេះដែរ បើគេចង់វិនិយោគលើភាគហ៊ុន (ទិញភាគហ៊ុន) របស់ក្រុមហ៊ុនសាជីវកម្មណាមួយនៅកាលបរិច្ឆេទណាមួយកំណត់ច្បាស់លាស់ពេលខ្លះ គឺគេពុំចាំបាច់ដាក់ទុនចំនួនច្រើនក្នុងពេលដែលគេពុំមានលទ្ធភាពពេលបច្ចុប្បន្ននោះទេ។ គឺថាគេគ្រាន់តែទៅទិញសិទ្ធិទិញ Call Option ពីធនាគារ ឬស្ថាប័នហិរញ្ញវត្ថុដទៃទៀតដោយគ្រាន់តែបង់ប្រាក់បន្ថែម(Premium) ដើម្បីធានាដំណើរការប្រតិបត្តិការនេះ។ ជាចុងក្រោយគឺយើងរង់ចាំដល់កាលបរិច្ឆេទកំណត់នៃកិច្ចសន្យា (Exercise or Strike price)។ ក្នុងករណីដែលស្ថានភាពមិនអំណោយផលដល់ការវិនិយោគរបស់យើង គឺថាយើងត្រូវបោះបង់ចោលកិច្ចសន្យាទិញ Call Option នោះ មានន័យថាយើងខាតប្រាក់បង់បន្ថែម (Premium) ដែលបានបង់នោះ។ ចំណែកឯការទិញ Forward or Future វិញគឺពុំមានចំណាយលើប្រាក់បង់បន្ថែម (Premium) ទេ[1]។

## ១.២. ការទិញ និងលក់មូលបត្រ

អ្នកទិញភាគហ៊ុននៅលើទីផ្សារហ៊ុនទាំងអស់មានការរំពឹងចង់បានរួមគ្នាមួយគឺ ចង់បានភាគលាភច្រើន និងប្រាក់ចំណេញជាមូលធន (Capital gain) នៅពេលដែលត្រូវការលក់ភាគហ៊ុនទាំងនោះវិញ។ គេសង្កេតឃើញថាអ្នកទិញភាគហ៊ុនខ្លះគាត់មិនចាំបាច់រក្សាទុកភាគហ៊ុនរបស់គាត់រហូតដល់ពេលបែងចែកភាគលាភដោយក្រុមហ៊ុននោះទេ ពោលគឺគាត់លក់ភាគហ៊ុនភ្លាមនៅពេលឡើងថ្លៃ ហើយគាត់ត្រូវរកទិញជាបន្តភាគហ៊ុនណាដែលមានតម្លៃទាបដើម្បីរងចាំឱកាសឡើងថ្លៃទើបលក់ជាថ្មីម្តងទៀត។

### ១.២.១. ការជ្រើសរើសក្រុមហ៊ុនជើងសារ

មុននឹងឈានទៅដល់ការបើកនូវគណនីវិនិយោគឬ គណនីជើងសារគេត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនជើងសារជាមុនសិន។ កត្តាវិនិយោគិនត្រូវពិចារណា ក្នុងការជ្រើសរើសក្រុមហ៊ុនជើងសារមានដូចជា ថ្លៃឈ្នួលក្នុងការបើកគណនី កម្រៃសេវានៅពេលជួញដូរ និងកម្រិតនៃសេវាកម្មដែលគេចង់បានពីឈ្មួញជើងសារទាំងនោះ។ ប្រសិនបើមិនចង់ចំណាយច្រើនទៅលើកម្រៃសេវាជើងសារនោះគេអាចជ្រើសរើសនូវក្រុមហ៊ុនជើងសារតាមអេឡិចត្រូនិច (Online Brokerage Firms – Deep Discount Brokerage Firms) ប៉ុន្តែ សេវាដែលពួកគេផ្តល់ឲ្យមកវិញក៏មានកម្រិតតិចតួចដែរ។

[1] ឈាង ហ៊ុយ (២០១៦) មូលដ្ឋានគ្រឹះនៃការវិនិយោគ

ប្រសិនបើគេចង់ជ្រើសរើសនូវក្រុមហ៊ុនជើងសារដែលផ្តល់នូវសេវាប្រឹក្សាយោបល់ច្រើន ក្នុងការវិនិយោគនិងសំបូរទៅដោយពត៌មាន នោះគេត្រូវជ្រើសរើសក្រុមហ៊ុនជើងសារដែលផ្តល់ សេវាពេញលេញ (Full Services Brokerage Firms)។ ក្រៅពីនេះ គេនៅមានជម្រើសកណ្តាល មួយក្នុងការជ្រើសរើសក្រុមហ៊ុន ដែលផ្តល់សេវាប្រឹក្សាយោបល់ក្នុងកម្រិតមធ្យម ជាមួយនឹងកម្រៃសេវាដ៏សមស្របមួយ។ ក្នុងករណីនេះ ក្រុមហ៊ុនជើងសារដែលផ្តល់នូវអប្បហារ (Discount Brokerage Firms) គឺជាជម្រើសដ៏ល្អបំផុត ព្រោះវាផ្តល់នូវការប្រឹក្សាយោបល់មួយដ៏សមស្រប ជាមួយនឹងតម្លៃសេវាសមរម្យ។ ការជ្រើសរើសក្រុមហ៊ុនឈ្មួញជើងសារឲ្យបានត្រឹមត្រូវ គឺជាបញ្ហាសំខាន់បំផុត មុននឹងឈានទៅដល់ការវិនិយោគទៅលើទីផ្សារមូលបត្រកម្មសិទ្ធិនេះ។

### ១.២.២. ការបើកគណនីជើងសារ

បន្ទាប់ពី បានជ្រើសរើសក្រុមហ៊ុនជើងសាររួចហើយ នោះជំហានបន្ទាប់ដែលត្រូវធ្វើ គឺការបើកគណនីជើងសារនៅក្នុងក្រុមហ៊ុនឈ្មួញជើងសារនោះ។ គណនីជើងសារ ត្រូវបានបែងចែកជាពីរប្រភេទគឺ គណនីបេឡា ឬ គណនីសាច់ប្រាក់ (Cash Account) និងគណនីជើងសារមានកម្រិតកំណត់ (Margin Account)។ គណនីបេឡា គឺជាគណនីមួយប្រភេទដែលអនុញ្ញាតឲ្យវិនិយោគិនទិញមូលបត្របានលុះត្រាតែ គេមានសាច់ប្រាក់គ្រប់គ្រាន់យ៉ាងតិច ១០០% និងមិនអាចខ្ចីពីក្រុមហ៊ុនឈ្មួញជើងសារបាននោះទេ។ ភាគហ៊ុនដែលវិនិយោគិននោះទិញបាន គឺជាកម្មសិទ្ធិរបស់គាត់ ១០០% ហើយក្រុមហ៊ុនឈ្មួញជើងសារ មិនមានសិទ្ធិនៅលើភាគហ៊ុនរបស់បុគ្គលនោះឡើយ។ ផ្ទុយពីគណនីបេឡាចំពោះគណនីជើងសារមានកម្រិតកំណត់វិញ គឺជាគណនីមួយប្រភេទ ដែលក្រុមហ៊ុនជើងសារ អនុញ្ញាតឲ្យអតិថិជនរបស់គេខ្ចីប្រាក់ដើម្បីទិញមូលបត្របន្ថែម ដូច្នេះម្ចាស់គណនីប្រភេទនេះមិនមានសិទ្ធិគ្រប់គ្រងលើភាគហ៊ុននោះទេ ពោលគឺ វាត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនជើងសារសម្រាប់ធ្វើជាវត្ថុធានាលើបំណុលដែលវិនិយោគិននោះបានខ្ចី។ ប្រសិនបើតម្លៃភាគហ៊ុនដែលបានទិញនោះធ្លាក់ដល់កម្រិតទាបមួយ ក្រុមហ៊ុនជើងសារនឹងលក់នូវមូលបត្រទាំងនោះ ដើម្បីយកប្រាក់ដែលខ្លួនបានផ្តល់កម្ចីត្រលប់មកវិញ។ គណនីប្រភេទនេះគឺមានហានិភ័យខ្ពស់ជាងគណនីបេឡា ប៉ុន្តែវាក៏មានឱកាសទទួលបានប្រាក់ចំណេញច្រើនប្រសិនបើភាគហ៊ុនឡើងថ្លៃ។

ប៉ុន្តែចំពោះ ព្រះរាជាណាចក្រកម្ពុជាវិញនាពេលបច្ចុប្បន្ន គឺអនុញ្ញាតឲ្យមានតែគណនីសាច់ប្រាក់តែប៉ុណ្ណោះ ពោលគឺ ការវិនិយោគត្រូវមានសាច់ប្រាក់ ឬមូលបត្រយ៉ាងតិច ១០០%។ ការ

កំណត់បែបនេះ គឺដើម្បីរក្សានូវសណ្តាប់ធ្នាប់របស់ផ្សារ និងធានាពីដំណើរការនៃការជួញដូរឲ្យមានភាពរលូន និងរីកចម្រើន។

### **១.២.៣. ការលក់មូលបត្ររយៈពេលខ្លី** (Short Sales)

អ្នកវិនិយោគដែលទិញភាគហ៊ុនហើយរក្សាទុក ក្នុងគោលបំណងទទួលបានភាគលាភត្រូវបានចាត់ទុកថាមានភាគហ៊ុនរយៈពេលវែង ឬស្ថានភាពវែង។ ផ្ទុយទៅវិញប្រសិនបើអ្នកវិនិយោគគេឆ្លៀតយកចំណេញតាមរយៈការទិញហើយលក់ក្នុងរយៈពេលដ៏ខ្លី។ គេចាត់ទុកប្រតិបត្តិការលក់នេះថាជាស្ថានភាពខ្លី (Short position)។ អ្នកវិនិយោគលើភាគហ៊ុនរយៈពេលវែងនឹងទទួលបានប្រាក់ចំណេញប្រសិនបើតំលៃរបស់ភាគហ៊ុននោះកើនឡើង ហើយគាត់នឹងមានការខាតបង់បើសិនជាថ្លៃភាគហ៊ុនធ្លាក់ចុះ។

**ក. មូលដ្ឋាននៃការលក់មូលបត្ររយៈពេលខ្លី** Basics of a Short Sale

- អ្នកអាចលក់ប័ណ្ណភាគហ៊ុនដែលមិនមែនជារបស់អ្នកបាន។
- អ្នកអាចខ្ចីប័ណ្ណភាគហ៊ុនពីក្រុមហ៊ុនជើងសាររបស់អ្នកហើយលក់ប័ណ្ណភាគហ៊ុននោះ។
- អ្នកអាចរកទិញ ប័ណ្ណភាគហ៊ុនដូចគ្នានឹងភាគហ៊ុនដែលបានខ្ចីសងត្រលប់ទៅវិញទៅ Broker របស់អ្នកវិញតាមកាលបរិច្ឆេទកំណត់។

**ខ. ការលក់មូលបត្ររយៈពេលខ្លី** Short Sales: some details

នៅពេលដែលអ្នកខ្វះប័ណ្ណភាគហ៊ុនក្នុងការលក់ អ្នកត្រូវខ្ចីប័ណ្ណភាគហ៊ុនពីជើងសាររបស់អ្នក ហើយដែលអ្នកត្រូវបំពេញលក្ខ័ខ័ណ្ឌមួយចំនួនដូចខាងក្រោម៖

- ត្រូវមាន Initial margin និង Maintenance margin។
- បន្ទាប់ពីអ្នកបានលក់ភាគហ៊ុនដែលបានខ្ចីហើយ ទឹកប្រាក់ដែលទទួលបានពីការលក់ភាគហ៊ុននោះនឹងដាក់នៅក្នុងគណនីរបស់អ្នក ប៉ុន្តែអ្នកមិនអាចប្រើប្រាស់វាបានឡើយ។ ជាទូទៅអ្នកអាចដកបានលុះត្រាតែអ្នកបានទិញប័ណ្ណភាគហ៊ុនដែលបានខ្ចីសងត្រលប់ទៅអោយឈ្មួញជើងសារ Broker វិញ។
- បើសិនជាភាគហ៊ុនដែលអ្នកបានខ្ចីលក់តំរូវអោយបង់ភាគលាភ អ្នកត្រូវទូទាត់បង់ភាគលាភនោះ។

## ១.៣. មូលដ្ឋាននៃការសម្រេចចិត្តក្នុងការវិនិយោគ The Basic of Investment Decisions

ជាធម្មតាអ្នកវិនិយោគសង្ឃឹមថានឹងទទួលបានចំណូលជាភាគលាភ (Return)ពីប្រាក់របស់គេដែលបានដាក់វិនិយោគ។ មានកត្តាច្រើនដែលមានឥទ្ធិពលទៅលើការសម្រេចចិត្តធ្វើវិនិយោគ។ ក្នុងចំណោមកត្តាទាំងនោះបញ្ហាហានិភ័យ និងផលចំណេញមានសារៈសំខាន់សំរាប់អ្នកវិនិយោគក្នុងការធ្វើការសំរេចចិត្ត ព្រោះពេលអនាគតគឺយើងមិនអាចដឹងច្បាស់ ឬមិនអាចកំណត់បានទេ។ មានពេលខ្លះគំរោងវិនិយោគមួយមានហានិភ័យខ្ពស់គឺផ្តល់ភាពប្រថុយប្រថានខ្ពស់ ហើយសង្ឃឹមបានផលចំណេញខ្ពស់ មានន័យថា High risk High return តែមានករណីខ្លះ អ្នកវិនិយោគប្រថុយប្រថានខ្ពស់តែទទួលបានផលចំណេញទាបទៅវិញ។ ជាទូទៅ ភាពប្រថុយប្រថានទាំងអស់គឺមិនមែនសុទ្ធតែនឹងទទួលនូវសំណងមកវិញតាមកំរិតហានិភ័យនោះទេ។

មុននឹងសម្រេចចិត្តជ្រើសរើសវិនិយោគ គេត្រូវគិតគូរអំពីស្ថានភាពមានហានិភ័យដែលនឹងអាចកើតមាន។ គេបានធ្វើចំណាត់ថ្នាក់អ្នកវិនិយោគជាបីក្រុមធំៗគឺ៖

- អ្នកមិនចូលចិត្តហានិភ័យ Risk averse investors
- អ្នកចូលចិត្តហានិភ័យ Risk seeking investors
- ណឺតចំពោះហានិភ័យ Neutral risk ឬ Risk indifferent investors

ចំពោះអ្នកវិនិយោគដែលមិនសូវចូលចិត្តហានិភ័យ គឺគេចូលចិត្តទិញសញ្ញាប័ណ្ណរដ្ឋាភិបាល ឬ ប័ណ្ណរតនាគាររយៈពេលខ្លី (T-bill: Treasury bill)។ ចំណែក ឯអ្នកវិនិយោគដែលចូលចិត្តហានិភ័យគឺពួកគេចូលចិត្តដាក់ទុនដោយទិញប័ណ្ណភាគហ៊ុន នៅលើទីផ្សារភាគហ៊ុន។

ជាទូទៅ គេពិតជាមិនអាចបំបាត់ហានិភ័យបានទាំងអស់ទេ ប៉ុន្តែគេអាចកាត់បន្ថយវាបានខ្លះតាមរយៈការធ្វើវិនិយោគចំរុះបែប ឬ គេអាចហៅម្យ៉ាងទៀតថាធ្វើពហុវិនិយោគ (Diversification)។

### ១.៣.១. ផលចំណេញរបស់វិនិយោគ Investment Returns

គោលដៅចំបងរបស់អ្នកវិនិយោគ គឺចង់បានផលចំណេញ (Return) ខ្ពស់អំពីការដាក់ទុនវិនិយោគរបស់ខ្លួន។ គ្រប់អ្នកវិនិយោគទាំងអស់មិនចូលចិត្តហានិភ័យទេ។ ប៉ុន្តែប្រសិនបើគេពុំអាចជៀសវាងហានិភ័យបានទេ គេចាំបាច់ត្រូវជ្រើសរើសគំរោងវិនិយោគណា ដែលនឹងផ្តល់ផលចំណេញខ្ពស់ និងហានិភ័យក្នុងកំរិតទាបបំផុតតាមដែលនឹងអាចធ្វើបាន។

ជាទូទៅរាល់ការដាក់ទុនវិនិយោគ គឺត្រូវប្រឈមនឹងហានិភ័យទាំងអស់គ្រាន់តែហានិភ័យនោះទាប ឬខ្ពស់តែប៉ុណ្ណោះ។ តាមពិតហានិភ័យស្មើសូន្យគឺពិតជាពុំមានទេ។ ប៉ុន្តែនៅសហរដ្ឋអាមេរិចគេបានចាត់ទុកថា ការវិនិយោគលើប័ណ្ណរតនាគាររយៈពេលខ្លីជាប្រភេទវិនិយោគតែមួយគត់ដែលគ្មានហានិភ័យ ឬហានិភ័យស្មើសូន្យ ( Risk free rate = $R_f$)ដោយគេសំអាងទៅលើប្រវត្តិសាស្ត្ររបស់ប្រទេសគេដែលជានិច្ចកាលមានលទ្ធភាព និង បានសងបំណុលរាល់ ការចេញផ្សាយលក់ប័ណ្ណរតនាគាររយៈពេលខ្លីទាំងប៉ុន្មាន បើទោះជាបានឆ្លងកាត់សង្គ្រាមលោកទាំងពីរលើកក៏ដោយហើយដែលប្រទេសដ៏ទៃទៀតមិនបានធ្វើដូច។

### ក. ផលចំណេញជាដុល្លា (Dollar Return)

ផលចំណេញដែលនឹងទទួលបានអំពីវិនិយោគមួយចេញមកពីប្រភពច្រើន។ បើសិនជាយើងវិនិយោគដោយទិញភាគហ៊ុន ឬសញ្ញាប័ណ្ណ នៅលើផ្សារហ៊ុនផលចំណេញ ដែលយើងនឹងត្រូវទទួលបានមានពីរបែបគឺ:

- ចំណូលរយៈពេលខ្លី គឺសំដៅលើភាគលាភទទួលបានអំពីការវិនិយោគលើភាគហ៊ុន ឬការប្រាក់ទទួលបានពីវិនិយោគលើសញ្ញាប័ណ្ណ ឬ មូលនិធិរួម។
- ផលចំណេញមូលធន គឺសំដៅលើការផ្លាស់ប្តូរតំលៃផ្សារ Market value or Fair market value របស់តំលៃដែលយើងបានធ្វើវិនិយោគក្នុងករណីយើងត្រូវការលក់ទៅវិញ នៅកាលបរិច្ឆេទកំណត់មួយ។ ប្រសិនបើអ្នកវិនិយោគលក់ភាគហ៊ុន ឬសញ្ញាប័ណ្ណ ដែលគាត់បានទិញ ក្នុងតំលៃមួយលើសអំពីតំលៃដែលបានវិនិយោគ ក្នុងករណីនេះ គាត់នឹងទទួលបាន Capital gain និងច្រាសមកវិញ គេហៅថា Capital loss។

យើងបាន

| |
|---|
| Total dollar return = Dividend income + Capital gain (or loss) |

### ខ. ផលចំណេញជាភាគរយ (Percentage Returns)

ការគណនាផលចំណេញ គិតជាភាគរយធៀបនឹងទុនដែលបានវិនិយោគ គឺជាវិធីសាស្ត្រដែលគេនិយមប្រើប្រាស់ជាងការគណនាតាម Total dollar return។ វិធីសាស្ត្រនេះផ្តល់លក្ខណៈងាយស្រួលដល់អ្នកវិនិយោគ ព្រោះថាលទ្ធផលទទួលបានផ្តល់ភាពងាយស្រួលក្នុងការបកស្រាយថាតើ $1 ដែលគេវិនិយោគផ្តល់ជា Return ប៉ុន្មានភាគរយ។

យើងបាន:

$$\text{Percentage return} = \left[\frac{Capital\ gain\ (loss) + Dividend}{\text{Initial share price}}\right] \text{ x } 100$$

$$R = \frac{(PE + PB) + D}{PB}$$

ដែល:

$P_E$ = Ending price of the investment.

$P_B$ = Beginning price or initial share price.

D = Dividend paid at the end of period.

R = Total return over the period

ទាញចេញពីរូបមន្ត Percentage returnគេអាចទទួលបាន

Dividend return Capital gain (loss) return

$$R = \frac{(P_E - P_B)}{P_E} + \frac{D}{P_E}$$

- $Dividend\ return = \frac{Dividend}{Initial\ share\ Price} X\ 100$

- Capital gain (loss)return $= \frac{Capitial\ Gain}{Initial\ Share\ price} \text{X } 100$

### គ. មធ្យមនព្វន្តរបស់ផលចំណេញ Average Return

ដើម្បីគណនាមធ្យមរបស់ផលចំណេញ ច្រើន គេនិយមប្រើ Average or mean return ដែលបានពីតំលៃមធ្យមនៃផលចំណេញ ផ្សេងៗគ្នា ឬក៏ឆ្នាំខុសៗគ្នា។ គេទទួលបានរូបមន្តរបស់ស៊េរី Total Return

$$\bar{R} = \frac{\sum_{i=1}^{n} R_i}{n} = \frac{(R_1 + R_2 + \ldots.. + R_n)}{n}$$ ដែល

$\bar{R}$: Average or mean return

$R_i$ : $i^{th}$ value of total return

n : Number of total return

### ឃ. ផលចំណេញមធ្យមនៃប័ណ្ណភាគហ៊ុន និងអត្រាគ្មានហានិភ័យ (Average stock return and risk free rate)

យើងបានគណនា Average Return រាល់វិនិយោគនីមួយៗដើម្បីងាយស្រួលក្នុងការសំរេចចិត្តវិនិយោគ។ គេអាចប្រៀបធៀបតួរលេខទាំងនេះទៅនឹងផលចំណេញទទួលបានវិនិយោគលើប័ណ្ណរតនាគាររយ:ពេលខ្លី Treasury bills (T-bills) ដែលគេសន្មតថាគ្មានហានិភ័យ Risk free rate ហើយ

មានរយៈពេលខ្លី។ ភាពខុសគ្នារវាងផលចំណេញ លើវិនិយោគមានហានិភ័យ និង អត្រាគ្មានហានិ-ភ័យ Risk free rate ត្រូវបានគេអោយឈ្មោះថា Risk Premium។

### ១.៣.២. ការវាស់វែងហានិភ័យ Measuring Risk

ហានិភ័យបកស្រាយថាជាព្រឹត្តិការណ៍ដែលផលចំណេញ ទទួលបានពីវិនិយោគបច្ចុប្បន្ន ប្រែប្រួលផ្លាស់ប្តូរខុសគ្នាពីផលចំណេញ ដែលបានរំពឹងទុក។ គេអាចបកស្រាយម្យ៉ាងទៀតថាហា-និភ័យ គឺជាស្ថានភាពឬភាពមិនប្រាកដប្រជាដែលយើងនឹងមិនអាចទទួលបានផលចំណេញដូចការស្មាន ឬរំពឹងទុករបស់យើងលើវិនិយោគ។ ឧទាហរណ៍ យើងប៉ាន់ស្មានថានឹងទទួលបាន ១០% លើការវិនិយោគលើភាគហ៊ុនប៉ុន្តែផលចំណេញ (Return) ដែលទទួលបានពិតប្រាកដគឺអាចទាបជាង ១០% ដែលគេបកស្រាយថាគឺជាហានិភ័យដែលនាំអោយយើងរងការខាត់បង់លើវិនិយោគនេះ។ ដោយដឹងថាក្នុងស្ថានភាពមិនប្រាកដប្រជា ឬក្នុងស្ថានភាពមានហានិភ័យអ្នកវិនិយោគ តែងធ្វើការសំរេចចិត្តវិនិយោគដោយឈរលើគោលការណ៍ផលចំណេញរំពឹងទុក Expected Return ហើយផលចំណេញ ទទួលបានពិតប្រាកដគឺមានការប្រែប្រួលផ្លាស់ប្តូរ។ ដូចនេះគេហៅថាការសំរេចចិត្តវិនិ-យោគបែបនេះជាការសំរេចចិត្តមានហានិភ័យ។ ហានិភ័យ(Risk)ត្រូវបានគេបែងចែកចេញជាប្រភេទផ្សេងៗមានដូចជា:[2]

- ហានិភ័យវិនិយោគ (Investment Risk) គឺជាប្រភេទហានិភ័យដែលអាចកើតមានឡើងចំពោះវិនិយោគដែលគ្រោងនឹងដាក់ទុនវិនិយោគ។ ឧទាហរណ៍ ការវិនិយោគលើទីផ្សារហ៊ុនដោយទិញភាគហ៊ុនអ្នកវិនិយោគអាចទទួលរងហានិភ័យនេះប្រសិនបើថ្លៃហ៊ុននោះថយចុះហើយ ចំពេលគេត្រូវការលក់ភាគហ៊ុននោះនៅលើទីផ្សារ។ Standard deviation គឺជាខ្នាតវាស់ដែលត្រូវបានគេប្រើប្រាស់ជាទូទៅសំរាប់វាស់ហានិភ័យ របស់ធនលាភភាពលើវិនិយោគមួយ ឬច្រើន។
- ហានិភ័យទីផ្សារ (Market Risk) បកស្រាយថាជាហានិភ័យរបស់ទីផ្សារ។ ជាធម្មតាហានិភ័យស្មើសូន្យគឺពិតជាពុំអាចកើតមានទេ។ ប៉ុន្តែទ្រឹស្តីដែលថាហានិភ័យស្មើសូន្យនោះគ្រាន់តែជាការសន្មត់ ឬនិយាយដោយខ្លីគឺជាសម្មតិកម្មតែប៉ុណ្ណោះ។ តាមពិតនៅលើទីផ្សារគឺអ្វីៗមានការប្រែប្រួលផ្លាស់ប្តូរតាមច្បាប់ផ្គត់ផ្គង់ និងតំរូវការដោយរាប់ទាំងថ្លៃភាគហ៊ុននៅលើទីផ្សារហ៊ុនដែលមាន

[2] ឈាង ហ៊ុយ (២០១៦) មូលដ្ឋានគ្រឹះនៃការវិនិយោគ

ការឡើងចុះរាល់វិនាទី។ គេហៅព្រឹត្តិការណ៍នេះថាជាហានិភ័យទីផ្សារ ដែលពុំមានអ្នកណាអាចមានឥទ្ធិពលកាត់បន្ថយ ឬបំបាត់បានឡើយ។

- ហានិភ័យអត្រាការប្រាក់ (Interest Rate Risk) អត្រាការប្រាក់ខ្ពស់ ឬទាបគឺពិតជាមានគន្លឹះដល់អ្នកដែលត្រូវសំរេចចិត្តធ្វើវិនិយោគ។ អត្រាការប្រាក់កើនឡើងខ្ពស់ពេកនឹងនាំអោយវិនិយោគមានការថយចុះ។ ដោយហេតុថា អត្រាការប្រាក់គឺជាថ្លៃដើមចំនាយលើមូលធន (Cost of Capital) សំរាប់អ្នកវិនិយោគ។ អត្រាការប្រាក់កើនឡើងបកស្រាយថាគាត់ត្រូវចំណាយកាន់តែច្រើនលើមូលធនដែលបានខ្ចីយកមកប្រើប្រាស់ ហើយក៏បណ្តាលឲ្យផលចំណេញពីវិនិយោគរបស់គាត់ថយចុះដែរ។ ការកើនឡើង ឬថយចុះអត្រាការប្រាក់ត្រូវបានគេចាត់ទុកថាជា Interest Rate Risk។

- ហានិភ័យនៃអតិផរណា (Inflation Risk) ផលប៉ះពាល់លើវិនិយោគរបស់យើង នៅពេលដែលមានអតិផរណាកើតឡើងគឺ:

- ធ្វើអោយតំលៃបច្ចុប្បន្ននៃការប្រាក់ (Present Value of Coupon) នៃសញ្ញាប័ណ្ណមានការថយចុះប្រសិនបើគេដាក់ទុនវិនិយោគលើសញ្ញាប័ណ្ណ (Bonds)។

- ចំណាយជាមូលធន (Capital Expenditures) មានការកើនឡើងនៅពេលដែលក្រុមហ៊ុនដល់ពេលចាំបាច់ត្រូវធ្វើវិនិយោគបន្ថែម។ ដូចនេះអតិផរណាពិតជាអាចបណ្តាលអោយមានហានិភ័យលើគំរោងវិនិយោគបន្ថែមទៀត ព្រោះថាវានឹងធ្វើអោយយើងត្រូវចំណាយទុនបន្ថែមលើសតំលៃចាស់ដែលបានធ្វើគំរោងរួចហើយ។

ក្រៅពីប្រភេទហានិភ័យខាងលើនេះ នៅមានប្រភេទហានិភ័យជាច្រើនផ្សេងៗទៀតមានដូចជា: Credit risk, Industry risk, Liquidity risk, Currency risk និង Payment risk។ គេមានមធ្យោបាយតែមួយគត់ដើម្បីវាស់វែងហានិភ័យ គឺត្រូវគណនាវ៉ារ្យង់ Variance ឬគំលាតស្តង់ដា Standard deviation របស់ផលចំណេញ។

# ជំពូកទី២

# ទស្សនៈទានទូទៅស្តីពីផ្សារមូលបត្រកម្ពុជា

## ២.១. សាវតារនៃផ្សារមូលបត្រកម្ពុជា

ដោយសង្កេតឃើញថា ផ្សារមូលបត្រអាចជំរុញខឿនសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលកម្ពុជាខិតខំប្រឹងប្រែងក្នុងការបង្កើតឲ្យចេញជារូបរាងឡើងនៃផ្សារមូលបត្រ។ គោលបំណងចម្បងបំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតផ្សារមូលបត្រកម្ពុជានេះឡើង គឺដើម្បីកៀរគរមូលធនដែលធ្វើឲ្យមានចលនាសាច់ប្រាក់បន្ថែមទៀត និងដើម្បីកំណត់សេដ្ឋកិច្ចជាតិ ក៏ដូចជាការអភិវឌ្ឍប្រទេសកម្ពុជាឲ្យកាន់តែរីកចម្រើន។ នៅក្នុងឆ្នាំ១៩៩៥ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើនូវសេចក្តីព្រៀងច្បាប់ផ្សារទុនដែលជាគំនិតផ្តួចផ្តើមរបស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលអាណត្តិទី១។ ប៉ុន្តែអ្វីដែលគួរឲ្យសោកស្តាយនោះ គឺគំនិតផ្តួចផ្តើមនេះត្រូវបានកាត់ផ្តាច់ដោយសារតែការរំខានខាងផ្នែកនយោបាយ និងវិបត្តិហិរញ្ញវត្ថុនៅអាស៊ីក្នុងឆ្នាំ១៩៩៧។ ក្រោយមកដោយសារតែការរង់ចាំការអភិវឌ្ឍផ្នែកហិរញ្ញវត្ថុ និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្នែកច្បាប់ដែលចាំបាច់សម្រាប់ទីផ្សារមូលបត្រដូចនេះ ទើបធ្វើឲ្យការអភិវឌ្ឍនូវទីផ្សារមូលបត្រមានភាពយឺតយ៉ាវ។

រហូតដល់ឆ្នាំ២០០១ រាជរដ្ឋាភិបាលបានដាក់ចេញនូវ "ចក្ខុវិស័យ និងផែនការអភិវឌ្ឍ វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០" ដែលក្នុងនោះ បានបែងចែកជាបីដំណាក់កាល។ នៅក្នុងដំណាក់កាលទី១ ដែលចាប់ពីឆ្នាំ២០០១ រហូតដល់ឆ្នាំ ២០០៤ រាជរដ្ឋាភិបាលបានរៀបចំនូវលក្ខណៈចាំបាច់ដូចជាបង្កើតប្រព័ន្ធច្បាប់ និងនីតិបញ្ញត្តិ ដើម្បីជាគ្រឹះនៃទីផ្សារមូលបត្រ។ នៅក្នុងដំណាក់កាលទី២ ដែលចាប់ផ្តើមពីឆ្នាំ ២០០៥ រហូតដល់ឆ្នាំ ២០០៧ រាជរដ្ឋាភិបាលបានបង្កើតមូលដ្ឋានគ្រឹះនៃទីផ្សារមូលធន និងរចនាសម្ព័ន្ធចាំបាច់សម្រាប់តាមដានទីផ្សារមូលធន និងអនុម័តនូវនិតិវិធីលម្អិតមួយចំនួនទៀត រួមទាំងពង្រឹងសមត្ថភាពនិងចំណេះដឹងរបស់សាធារណជនអំពីទីផ្សារមូលបត្រ។ នៅក្នុងដំណាក់កាលទី៣ ដែលចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ ២០១០ ជាដំណាក់កាលដែលផ្តោតទៅលើការអភិវឌ្ឍទីផ្សារមូលបត្រដែលចែកចេញជា ការពង្រឹងការគ្រប់គ្រង និងការតាមដានទីផ្សារមូលបត្រ ការពង្រីកទីផ្សារប័ណ្ណបំណុលឯកជន រួមទាំងការលើកកម្ពស់ និងការពង្រីកសមត្ថភាពសម្រាប់អ្នកចូលរួមក្នុងទីផ្សារមូលបត្រដើម្បីធានាបានថាទីផ្សារមូលបត្រអាចដំណើរការបានយ៉ាងរលូន។ ប៉ុន្តែ

ដោយសារវិបត្តិហិរញ្ញវត្ថុដែលកើតមានឡើងនៅឆ្នាំ២០០៨ បានជះឥទ្ធិពលអវិជ្ជមានដល់គម្រោងអភិវឌ្ឍន៍ទីផ្សារមូលបត្រ ដែលជាហេតុនាំឲ្យមានការពន្យាពេលដល់ការបង្កើតទីផ្សារមូលបត្រកម្ពុជា។

ដោយយោងតាម "យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦-២០១៥" ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មមកពី "ចក្ខុវិស័យ និងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០១-២០១០" ក្នុងនោះចែកចេញជាបីដំណាក់កាល។ ដំណាក់កាលទី១ ចាប់ពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០០៩ ជាដំណាក់កាលផ្តោតទៅលើការអប់រំវិនិយោគិនសាធារណៈ បង្កើតដៃគូរជាមួយទីផ្សារមូលបត្របរទេស និងការអនុវត្តនូវច្បាប់ស្តីពី "ការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន"។ ចំណែកឯដំណាក់កាលទី២ ចាប់ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១២ ជាដំណាក់កាលដែលរាជរដ្ឋាភិបាលបង្កើតចំណាត់ថ្នាក់ក្រុមហ៊ុន រៀបចំបង្កើតប្រតិបត្តិកររក្សាទុកមូលបត្រ និងរៀបចំបង្កើតទីផ្សារមូលបត្រ។ ដំណាក់កាលទី៣ ចាប់ពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០១៥ ជាដំណាក់កាលបង្កើតនូវមូលនិធិវិនិយោគ គម្រោងមូលនិធិសោធនិវត្តន៍/-សន្សំ/គ្រឹះស្ថាន/ក្របខណ្ឌមូលនិធិនិយ័តកម្ម និងឧបករណ៍ដេរីវេទីវ។

នៅថ្ងៃទី ០៤ ឧសភា ឆ្នាំ ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានចុះអនុស្សរណៈយោគយល់គ្នានៅក្នុងទីក្រុងឥតិរបទ ប្រទេសឥណ្ឌា ក្នុងពេលប្រជុំប្រចាំឆ្នាំ ADB និងប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានបូក៣ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រទេសកម្ពុជា និងក្រសួងហិរញ្ញវត្ថុ និងសេដ្ឋកិច្ចនៃសាធារណៈរដ្ឋកូរ៉េទៅលើការអភិវឌ្ឍវិស័យមូលបត្រកម្ពុជា។ នៅក្នុងខែ ឧសភា ឆ្នាំ ២០០៦ នេះដដែលភាគីកូរ៉េបានបញ្ជូនគណៈប្រតិភូមកពីទីផ្សារមូលបត្រកូរ៉េចំនួន ០២ (ពីរ) លើក មកធ្វើការសិក្សា និងវិភាគពីលទ្ធភាពរបស់ក្រុមហ៊ុន សហគ្រាស ធនាគារ និងសកម្មភាពសេដ្ឋកិច្ចនៅកម្ពុជា។ មកដល់នៅថ្ងៃទី ២០ វិច្ឆិកា ឆ្នាំ ២០០៦ រាជរដ្ឋាភិបាលកម្ពុជា បានចុះអនុស្សរណៈយោគយល់គ្នា រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា និងទីផ្សារមូលបត្រកូរ៉េ នៃសាធារណៈរដ្ឋកូរ៉េ ដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា។ ច្បាប់ស្តីពីមូលបត្ររដ្ឋ ត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ១០ មករា ២០០៧ ហើយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ១៩ តុលា ២០០៧។ ចំណែកឯ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវបានប្រកាសនៅថ្ងៃទី ២៣ កក្កដា ២០០៨។ រហូតមកដល់ខែ កុម្ភៈ ឆ្នាំ ២០០៩ ទីផ្សារមូលបត្រកូរ៉េ ចុះកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតទីផ្សារមូលបត្រ

ដែលទីផ្សារមូលបត្រ កូរ៉េគ្រប់គ្រងភាគហ៊ុន ៤៥ (សែសិបប្រាំ) ភាគរយ និងរាជរដ្ឋាភិបាលកម្ពុជាគ្រប់គ្រងភាគហ៊ុន ៥៥ (ហាសិបប្រាំ) ភាគរយ។ នៅថ្ងៃទី ០៨ មេសា រាជរដ្ឋាភិបាលបានប្រកាសនូវអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។ ថ្ងៃទី ២៩ មេសា ២០០៩ គណៈកម្មការមូលបត្រកម្ពុជាត្រូវបានដាក់សម្ពោធឲ្យដំណើរការជាផ្លូវការ ក្រោមអធិបតីភាព ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា។ មកដល់ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១១ សមិទ្ធិផលដ៏ធំមួយជាប្រវត្តិសាស្ត្របានលេចចេញជារូបរាងឡើងនោះ គឺជាការចាប់ផ្តើមបើកជាស្ថាពរនូវទីផ្សារមូលបត្រកម្ពុជាដែលបានគ្រោងទុកអស់រយៈ១៦ឆ្នាំកន្លងមកនេះ។

## ២.២. តួអង្គសំខាន់ៗក្នុងវិស័យមូលបត្រកម្ពុជា

ទីផ្សារមូលបត្រកម្ពុជា គឺជាទីផ្សារដ៏ថ្មីស្រឡាងមួយសម្រាប់សាធារណជនក្នុងប្រទេសកម្ពុជា។ ទីផ្សារនេះអាចដំណើរការទៅបានអាស្រ័យលើតួអង្គសំខាន់ៗដែលមានដូចជា និយ័តករមូលបត្រសំដៅដល់គណៈកម្មការមូលបត្រកម្ពុជា ប្រតិបត្តិករមូលបត្រសំដៅដល់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយមូលបត្រ ក្រុមហ៊ុនមូលបត្រ និងវិនិយោគិនមូលបត្រ។

### ២.២.១. និយ័តករមូលបត្រ

និយ័តករមូលបត្រ គឺជាអាជ្ញាធរដែលមានសមត្ថកិច្ចគ្រប់គ្រង និងអភិវឌ្ឍលើវិស័យមូលបត្រ។ និយ័តករមូលបត្រ គឺជាតួអង្គមួយយ៉ាងសំខាន់ដោយមិនអាចខ្វះបានដើម្បីធានាបាននូវសណ្តាប់ធ្នាប់ក្នុងវិស័យមូលបត្រ។ នៅក្នុងប្រទេសកម្ពុជានិយ័តករមូលបត្រ គឺជាគណៈ កម្មការមូលបត្រកម្ពុជា ដែលហៅកាត់ថា គ.ម.ក.។ គណៈកម្មការមូលបត្រកម្ពុជា ជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុម-ហ៊ុនបោះផ្សាយមូលបត្រ និងការពារវិនិយោគិនមូលបត្រ ព្រមទាំងធានាឲ្យការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។ ការគ្រប់គ្រងនេះមានគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការកៀងគរមូលធន ពីសាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅក្នុងប្រទេសកម្ពុជា។

គណៈកម្មការមូលបត្រកម្ពុជា មានគោលដៅទូទៅដូចខាងក្រោម[3]៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់ដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា
- បង្កើត និងរក្សាទំនុកចិត្តវិនិយោគិនដោយការពារសិទ្ធិរបស់វិនិយោគិន និងធានាឲ្យមានការបោះផ្សាយមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ
- ជំរុញការអភិវឌ្ឍទីផ្សារមូលបត្រ
- ដោះស្រាយវិវាទនានា ដែលទាក់ទងនឹងវិស័យមូលបត្រ
- បង្ការ និងដាក់ទណ្ឌកម្មចំពោះបទល្មើសនានាដែលផ្តល់ផលប៉ះពាល់ដល់ទីផ្សារមូល-បត្រ និងវិនិយោគិន

### ២.២.១.១. រចនាសម្ព័ន្ធគណៈគ្រប់គ្រងបច្ចេកទេស

គណៈគ្រប់គ្រងបច្ចេកទេស និងមន្ត្រីនៃ គ.ម.ក. ទទួលខុសត្រូវបំពេញមុខងារ និងភារកិច្ចលើការដាក់ឲ្យដំណើរការទីផ្សារមូលបត្រ និងការរក្សាទីផ្សារឲ្យមានតម្លាភាព ប្រសិទ្ធភាព និងសុវត្ថិ-ភាពជាពិសេសពង្រឹងទំនុកចិត្តរបស់វិនិយោគិន។ ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួននេះ គ.ម.ក. បានបែងចែកជារចនាសម្ព័ន្ធគ្រប់គ្រង ជានាយកដ្ឋាន-អង្គភាពដូចជា នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយក-ដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាលអភិវឌ្ឍទីផ្សារមូលបត្រនិងទំនាក់ទំនងអន្តរជាតិ និងអង្គភាពសវនកម្មផ្ទៃក្នុង។ នាយកដ្ឋាននីមួយៗត្រូវរាយការណ៍ជូនអគ្គនាយករងទទួលបន្ទុក និងអគ្គនាយក ដោយឡែកអង្គភាពសវនកម្មផ្ទៃក្នុងត្រូវរាយការណ៍ជូនប្រធាន និងសមាជិកគណៈមូលបត្រកម្ពុជា។ នាយកដ្ឋាន និងអង្គភាពមានការិយាល័យចំណុះសម្រាប់អនុវត្តការងារ និងរាយការណ៍ទៅប្រធាននាយកដ្ឋាន-អង្គភាព។

---

[3] ច្បាប់ស្តីពីការបោះផ្សាយនិង ការជួញដូរមូលបត្រមហាជន

គ.ម.ក. មាននាយកដ្ឋានចំណុះប្រាំមួយ និងអង្គភាពមួយដែលមានមុខងារដូចខាងក្រោម៖

**ក. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**

នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ មានមុខងារតួនាទីដូចតទៅ៖

- រៀបចំផែនការ និងថវិការបស់ គ.ម.ក.
- គ្រប់គ្រងកិច្ចការរដ្ឋបាល
- ផ្គត់ផ្គង់ និងជុសជុលសំភារៈបរិក្ខារការិយាល័យ
- ចាត់ចែងការងារពិធីការ
- ធ្វើទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ និងឯកជននានា
- រៀបចំគោលនយោបាយ គ្រប់គ្រង និងជ្រើសរើសបុគ្គលិក
- រៀបចំតារាងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភនានាដល់មន្ត្រីនៃ គ.ម.ក.
- គ្រប់គ្រង និងផ្តល់សេវាកម្មបច្ចេកវិទ្យាពត៌មាន

**ខ. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ**

នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ មានមុខងារ និងតួនាទីដូចតទៅ៖

- រៀបចំលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតឲ្យក្រុមហ៊ុននានាបោះផ្សាយលក់មូលបត្រសាធារណៈ
- រៀបចំលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ចនិងការគ្រប់គ្រងក្រុមហ៊ុនបោះ-ផ្សាយមូលបត្រជាសាធារណៈ
- ត្រួតពិនិត្យលក្ខខណ្ឌតម្រូវនានាទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈជាប្រចាំ
- ត្រួតពិនិត្យការអនុវត្តតាមស្តង់ដាគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យ និងផ្តល់យោលបល់លើការស្នើសុំបោះផ្សាយមូលបត្រលក់ជាសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជី ឯកសារផ្តល់ពត៌មាន ឯកសារផ្តល់ពត៌-មានបន្ថែម ឯកសារផ្តល់ពត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ

- ចុះបញ្ជីឯកសារផ្តល់ពតិមាន ឯកសារផ្តល់ពតិមានបន្ថែម ឯកសារផ្តល់ពតិមានជំនួស និង សេចក្តីថ្លែងនានារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យ និងផ្សព្វផ្សាយឯកសារផ្តល់ពតិមាន ឯកសារផ្តល់ពតិមានបន្ថែម ឯកសារផ្តល់ពតិមានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រតាមប្រព័ន្ធអេឡិចត្រូនិច និងតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍អាជីវកម្មរបស់ក្រុមហ៊ុនបោះ-ផ្សាយមូលបត្រ ជាសាធារណៈ
- ត្រួតពិនិត្យ ដល់ទីកន្លែងរបស់ក្រុមហ៊ុនស្នើសុំបោះផ្សាយមូលបត្រជាសាធារណៈ ប្រសិនបើមានការចាំបាច់ស្របតាមក្របខ័ណ្ឌការងារ
- គ្រប់គ្រងយន្តការបោះផ្សាយលក់មូលបត្រសាធារណៈ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើស នឹងច្បាប់និងបទបញ្ញាត្តិពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីធ្វើការស៊ើបអង្កេតបន្ត

**គ. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ**

នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ មានមុខងារ និងតួនាទីដូចតទៅ៖

- រៀបចំបទប្បញ្ញាត្តិ និងលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញដើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងចូលរួមដទៃនៅក្នុងទីផ្សារ ដើម្បីដាក់សុំការពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.
- ពិនិត្យ និងផ្តល់យោបល់ដល់ការស្នើសុំអាជ្ញាប័ណ្ណដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រភ្នាក់ងាររបស់ ក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញដើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតនៅក្នុងទីផ្សារ
- ត្រួតពិនិត្យ និងតាមដាននូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញដើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតនៅក្នុងទីផ្សារ

- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ នូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតនៅក្នុងទីផ្សារ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងក្រុមហ៊ុនមូលបត្រភ្នាក់ងារ ក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងចូលរួមដទៃទៀតនៅក្នុងទីផ្សារ

**ឃ. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ**

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រមានមុខងារ និងតួនាទីដូចតទៅ៖

- រៀបចំបទប្បញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតឲ្យធ្វើប្រតិបត្តិការជាមួយប្រតិបត្តិករទីផ្សារមូលបត្រប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់និងប្រតិ-បត្តិកររក្សាមូលបត្រដើម្បីដាក់សុំការពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.
- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាត ដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធទូទាត់និងផាត់ទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើការផ្ទេរផ្គងប្រព័ន្ធជួញដូរមូលបត្រ និងប្រតិបត្តិការផ្សេងៗទៀតរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ ចំពោះប្រតិបត្តិករទីផ្សារមូលបត្រប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ទៅនាយកដ្ឋានកិច្ចការគតិយុត្តដើម្បីធ្វើការស៊ើបអង្កេតបន្ត

**ង. នាយកដ្ឋានកិច្ចការគតិយុត្ត**

នាយកដ្ឋានកិច្ចការគតិយុត្ត មានមុខងារនិងតួនាទីដូចតទៅ៖

- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការត្រួតពិនិត្យ និងសម្រេចពីអគ្គនាយកនៃ គ.ម.ក.
- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការដែលស្នើដោយស្ថាប័ននិយ័តករ
- រៀបចំបទប្បញ្ញត្តិចាំបាច់នានា និងលើកសំណើធ្វើវិសោធនកម្មច្បាប់ រួមទាំងបទប្បញ្ញត្តិផ្សេងៗដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យមូលបត្រ
- ពង្រឹងការអនុវត្តច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធវិស័យមូលបត្រ
- ទទួលពាក្យបណ្តឹង និងធ្វើការស៊ើបអង្កេតពាក់ព័ន្ធនឹងប្រតិបត្តិការបោះផ្សាយ និងជួញដូរមូលបត្រដែល ល្មើសច្បាប់ ឬមិនប្រក្រតី ទាំងនៅក្នុងទីផ្សារដំបូង និងនៅក្នុងទីផ្សារបន្ទាប់
- ពិនិត្យ និងផ្តល់យោបល់ដើម្បីចាត់វិធានការដាក់ពិន័យនានា ពាក់ព័ន្ធនឹងបុគ្គលប្រព្រឹត្តល្មើសច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- សម្រុះសម្រួលដោះស្រាយវិវាទអ្នកចូលរួមក្នុងទីផ្សារមូលបត្រ
- ចាត់វិធានការផាកពិន័យអន្តរការណ៍ លើបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- រៀបចំសំណុំរឿងពាក់ព័ន្ធដើម្បីដាក់ពាក្យបណ្តឹងទៅតុលាការ
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ គ.ម.ក.

### ច. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ

នាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាលអភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិមានមុខងារតួនាទីដូចតទៅ៖

- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់សាធារណៈជន និងអ្នកចូលរួមនានាក្នុងវិស័យមូលបត្រ
- សិក្សាស្រាវជ្រាវពីយុទ្ធសាស្ត្រនានា ដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅប្រទេសកម្ពុជា និងសិក្សាស្រាវជ្រាវលើការអភិវឌ្ឍ

- គ្រប់គ្រង និង ការអភិវឌ្ឍវិស័យមូលបត្រ រៀបចំយុទ្ធសាស្ត្រដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ សិក្សាវាយតម្លៃ និងផ្តល់យោបល់
- រៀបចំយុទ្ធសាស្ត្រ ដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- សិក្សាវាយតម្លៃ និងផ្តល់យោបល់លើការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មី មុននឹងអនុញ្ញាតឲ្យបោះផ្សាយនៅលើទីផ្សារ
- ធ្វើទំនាក់ទំនងជាមួយនិយ័តករមូលបត្រនៃបណ្តាប្រទេសក្នុងតំបន់ និងក្នុងពិភព-លោក
- ចូលរួមក្នុងវេទិកាជាតិ និងអន្តរជាតិពាក់ព័ន្ធនានា

**ឆ. អង្គភាពសវនកម្មផ្ទៃក្នុង**

គណៈកម្មការមូលបត្រកម្ពុជា មានអង្គភាពសវនកម្មផ្ទៃក្នុងមួយដែលឋិតនៅក្រោមការដឹកនាំផ្ទាល់របស់ប្រធាន គណៈកម្មការមូលបត្រកម្ពុជា។ អង្គភាពសវនកម្មផ្ទៃក្នុងមានមុខងារ និងតួ-នាទីដូចតទៅ៖

- ត្រួតពិនិត្យលើមុខងារ សកម្មភាព កម្មវិធី និងប្រតិបត្តិការនានារបស់ គ.ម.ក. ដើម្បីកំណត់ការអនុវត្តឲ្យសមស្របតាមការរៀបចំផែនការ ការចេញបទបញ្ជា និងបទ-ប្បញ្ញត្តិផ្សេងៗ ការចាត់តាំងការងារ និងការត្រួតពិនិត្យ ដោយផ្អែកតាមគោលនយោបាយ ការណែនាំរបស់ថ្នាក់ដឹកនាំ និងនីតិវិធីជាធរមាន និងស្របតាមគោលដៅរបស់ គ.ម.ក.
- កំណត់ភាពសមស្រប និងប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ផ្នែកគណនេយ្យ រដ្ឋ-បាល និង ប្រតិបត្តិការនានារបស់ គ.ម.ក.
- ត្រួតពិនិត្យលើភាពដែលអាចជឿជាក់បាន និងភាពពេញលេញនៃពត៌មាន ទិន្នន័យ និងវិធីសាស្ត្រនៃការរៀបចំរបាយការណ៍អំពីពត៌មាន និងទិន្នន័យទាំងនោះ ក្នុងការិយបរិច្ឆេទសមស្រប
- ពិនិត្យលើប្រព័ន្ធដែលបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលនយោបាយផែនការនីតិវិធីច្បាប់និងបទប្បញ្ញត្តិនានា ហើយលើកសំណើកែតម្រូវ និងកែលំអប្រសិនបើមានកំហុស

- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពសេដ្ឋកិច្ច នៃការប្រើប្រាស់ធនធានរបស់ គ.ម.ក. ហើយលើកសំណើដោះស្រាយ និងកែលំអការអនុវត្តិប្រតិបត្តិការ
- ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការចំណាយ ចំណូលថវិការរបស់ គ.ម.ក. ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ
- ពិនិត្យលើមធ្យោបាយក្នុងការថៃរក្សាទ្រព្យសម្បត្តិរបស់ គ.ម.ក.
- ធ្វើរបាយការណ៍សវនកម្មជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ គ.ម.ក. អំពីការប្រព្រឹត្តទៅរបស់នាយកដ្ឋាន ឬអង្គភាពដែលបានធ្វើសវនកម្មរួច
- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួន ប្រចាំត្រីមាស និងប្រចាំឆ្នាំដើម្បីផ្ញើរជូនប្រធាន និងសមាជិកនៃ គ.ម.ក. ពិនិត្យ និងផ្តល់ការណែនាំ
- ធ្វើសវនកម្មផ្ទៃក្នុង ពេលដែលមានការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជាប្រធាននៃ គ.ម.ក.
- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដើម្បីដាក់ជូនប្រធាន និងសមាជិកនៃ គ.ម.ក ត្រួតពិនិត្យ និង សម្រេច
- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុង ជាមួយនឹងអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាដំណើរការឲ្យបានគ្រប់គ្រាន់ និងសមស្រប ជាពិសេសកាត់បន្ថយការងារស្ទួនគ្នា

គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានដាក់សម្ពោធដំណើរការជាផ្លូវការ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨។ គណៈកម្មការមូលបត្រកម្ពុជា ដែលមានទីតាំងស្ថិតនៅផ្ទះលេខ៩៩ ផ្លូវ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ហើយមានគេហទំព័រ www.secc.gov.kh ។

### ២.២.២. ក្រុមហ៊ុនមូលបត្រ

ក្រុមហ៊ុនមូលបត្រដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការទិញ-លក់ក្នុងទីផ្សារមូលបត្រកម្ពុជា តាមរយៈការដើរតួនាទីជាអន្តរការី។ ជាទូទៅ ក្រុមហ៊ុននេះដើរតួនាទីជាអន្តរការី ឬជាអ្នកសម្របសម្រួលប្រតិបត្តិការមូលបត្រនៅក្នុងទីផ្សារ។ ក្រុមហ៊ុនមូលបត្រ គឺជាតួអង្គសំខាន់មួយនៅក្នុងដំណើរការទីផ្សារមូលបត្រ ព្រោះក្រុមហ៊ុនមូលបត្រ ត្រូវបានចាត់ទុកជាអ្នកជំនាញក្នុងវិស័យមូលបត្រ ដែលមានតួនាទីយ៉ាងសំខាន់ដើម្បីជួយក្រុមហ៊ុនបោះផ្សាយក្នុងដំណើរការបោះផ្សាយលក់មូលបត្រ នៅលើទីផ្សារទទួលបានជោគជ័យ។ លើសពីនេះទៀតក្រុមហ៊ុនមូលបត្រក៏មានតួនាទី

ជួយដល់វិនិយោគិនមូលបត្រនៅក្នុងដំណើរការនៃការជួញដូរមូលបត្រ (ការទិញ-លក់មូលបត្រ) នៅក្នុងទីផ្សារផងដែរ ព្រោះវិនិយោគិនមូលបត្រ មិនអាចធ្វើការជួញដូរ មូលបត្រដោយផ្ទាល់នៅលើទីផ្សារមូលបត្រដោយខ្លួនឯងបាននោះទេ។ រាល់ការជួញដូរមូលបត្ររបស់វិនិយោគិន ត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលជាឈ្មួញជើងសារ។ ជារួម ក្រុមហ៊ុនមូលបត្រត្រូវបានចាត់ទុកជាអន្តរការីមូលបត្រដែលមិនអាចខ្វះបាននៅក្នុងទីផ្សារ ទាំងក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈរបស់ក្រុមហ៊ុនបោះផ្សាយ និង ក្នុងដំណើរការនៃការជួញដូរមូលបត្ររបស់វិនិ-យោគិន។ បច្ចុប្បន្ននៅកម្ពុជាមាន ក្រុមហ៊ុនមូលបត្រចំនួន១២(ដប់ពីរ) ដែលមានសកម្មភាពអាជីវ-កម្ម ៤(បួន) យ៉ាងសំខាន់ៗ៖

- ក្រុមហ៊ុនធានាទិញមូលបត្រ (Securities Underwriters) ចំនួន០៦ (ប្រាំមួយ)
- ក្រុមហ៊ុនពាណិជ្ជករមូលបត្រ (Securities Dealers) ចំនួន០១ (មួយ)
- ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ (Securities Brokers) ចំនួន០៣ (បី)
- ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ (Investment Advisers) ចំនួន០២ (ពីរ)

ចំពោះក្រុមហ៊ុនមូលបត្រដែលមានសកម្មភាពអាជីវកម្មជា ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ ទាមទារឲ្យមានការផ្តល់អាជ្ញាប័ណ្ណពីគណៈកម្មការមូលបត្រកម្ពុជា ដើម្បីធ្វើអាជីវកម្មនៅលើទីផ្សារមូលបត្រ។ ដោយឡែកក្រុមហ៊ុនទីប្រឹក្សាវិនិយោគ មិនតម្រូវឲ្យមានអាជ្ញាប័ណ្ណពីគណៈកម្មការមូលបត្រកម្ពុជាទេ តែក្រុមហ៊ុននេះត្រូវតែមានភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាប័ណ្ណពីគណៈកម្មការមូលបត្រកម្ពុជាយ៉ាងតិចមួយរូប។

### ២.២.២.១ ក្រុមហ៊ុនធានាទិញមូលបត្រ

ក្រុមហ៊ុនធានាទិញមូលបត្រ មាននាទីទិញយកមូលបត្រដែលនៅសល់ទាំងអស់ ឬមួយផ្នែកទៅតាមលក្ខខណ្ឌនៃកិច្ចសន្យារវាងក្រុមហ៊ុនធានាទិញមូលបត្រ និងក្រុមហ៊ុនបោះផ្សាយមូលបត្រក្នុងករណីដែលមូលបត្រដែលបោះផ្សាយនោះមិនបានលក់អស់ក្នុងដំណាក់កាលបរិវិសកម្ម។ ក្នុងការបោះផ្សាយជាសាធារណៈជាលើកដំបូង (Initial Public Offering / IPO) ក្រុមហ៊ុនធានាទិញមូល-បត្រដើរតួនាទីយ៉ាងសំខាន់ក្នុងការទិញយកមូលបត្រដែលនៅសល់ និងផ្តល់ជាការប្រឹក្សាដល់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។ ការប្រឹក្សាក្នុងការបោះផ្សាយជាសាធារណៈលើកដំបូងនេះមានដូចជា

ការកំណត់ទំហំទឹកប្រាក់ ការកំណត់ថ្លៃមូលបត្រ ការកំណត់ចំនួនមូលបត្រ និងការកំណត់ពេលវេលាក្នុងការបោះផ្សាយ។ ចំពោះក្រុមហ៊ុនដែលជាក្រុមហ៊ុនធានាទិញមូលបត្រ អាចមានសិទ្ធធ្វើអាជីវកម្មធានាទិញមូលបត្រអាជីវកម្មជួញដូរមូលបត្រ អាជីវកម្មឈ្មួញជើងសារមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។

បច្ចុប្បន្ន ក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលអាជ្ញាប័ណ្ណពីគណៈកម្មការមូលបត្រកម្ពុជា មានចំនួន ០៦ (ប្រាំពីរ) គឺ៖

- យាន់តា ស៊ីឃ្យួរីធី ភីអិលស៊ី (ខេមបូឌា) (Yuanta Securities (Cambodia) Plc.)
- អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យួរីធី មក. (RHB Indochina Securities PLC.)
- កាណា ស៊ីឃ្យួរីធី អិលធីឌី (Cana Securities Ltd.)
- កម្ពុ ស៊ីឃ្យួរីធី ភីអិលស៊ី (Campu Securities Plc.)
- អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យួរីធី (SBI Royal Securities Plc.)
- ភ្នំពេញ ស៊ីឃ្យួរីធី ភីអិលស៊ី (Phnom Penh Securities Plc.)

### ២.២.២.២. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ

ក្រុមហ៊ុនពាណិជ្ជករមូលបត្រ អាចធ្វើការជួញដូរមូលបត្រ (ទិញ-លក់) ក្នុងទីផ្សារមូលបត្រ ដូចនេះ តម្រូវឲ្យក្រុមហ៊ុនពាណិជ្ជករមូលបត្រមានគណនីផ្ទាល់ខ្លួនសម្រាប់ធ្វើការជួញដូរមូលបត្រ។ ក្នុងការជួញដូរមូលបត្រ អាចទទួលបានផលចំណេញពីមូលបត្រ ហើយក៏ត្រូវប្រឈមមុខនឹងហានិភ័យក្នុងការជួញដូរមូលបត្រផងដែរ។ ក្នុងនាមជាក្រុមហ៊ុនពាណិជ្ជករមូលបត្រអាចមានសិទ្ធិធ្វើអាជីវកម្មជួញដូរមូលបត្រ អាជីវកម្មឈ្មួញជើងសារមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។

បច្ចុប្បន្នក្រុមហ៊ុនពាណិជ្ជករមូលបត្រដែលទទួលអាជ្ញាប័ណ្ណគឺគណៈកម្មការមូលបត្រកម្ពុជា មានចំនួន ០១ (មួយ) គឺ៖

- ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា)ស៊ីឃ្យួរីធី ភីអិលស៊ី (Golden Fortune (Cambodia) Securities Plc.)

### ២.២.២.៣. ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ

ក្រុមហ៊ុនមូលបត្រដែលជាក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ មាននាទីជាអ្នកទទួលទិញ ឬលក់មូលបត្រ តាមបញ្ជារបស់អតិថិជនរបស់ខ្លួន។ ក្នុងន័យនេះ សាធារណជនមិនអាចធ្វើការទិញ-

លក់មូលបត្រដោយផ្ទាល់នៅលើទីផ្សារមូលបត្របានទេ ប្រតិបត្តិការនេះទាមទារឲ្យឆ្លងកាត់អន្តរការីដែលជាក្រុមហ៊ុនជើងសារមូលបត្រ។ ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ ទទួលបានកម្រៃជើងសារពីទទួលបញ្ជាទិញឬលក់ពីអតិថិជនរបស់ខ្លួន។ ក្នុងនាមជាក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ អាចមានសិទ្ធិអាជីវកម្មឈ្មួញជើងសារមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។

បច្ចុប្បន្ន ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ ដែលទទួលបានអាជ្ញាប័ណ្ណពីគណៈកម្មការមូលបត្រកម្ពុជាមានចំនួន ០៣ (បី) គឺ៖

- អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី (ACLEDA Securities Plc.)
- ខេប ស៊ីឃ្យូរីធី លីមីធីត (CAB Securities Limited.)
- ខេមបូឌាវៀតណាម ស៊ីឃ្យូរីធី ភីអិលស៊ី- (Cambodia-Vietnam Securities Plc.)

#### ២.២.២.៤. ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ

ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ មាននាទីជាអ្នកផ្តល់ប្រឹក្សាអំពីការវិនិយោគលើមូលបត្រ និងបោះផ្សាយការវិភាគការវិនិយោគលើមូលបត្រ សម្រាប់វិនិយោគិនសាធារណៈ។ ចំពោះក្រុមហ៊ុនទីប្រឹក្សាវិនិយោគ មិនតម្រូវឲ្យមានអាជ្ញាប័ណ្ណពីគណៈកម្មការមូលបត្រកម្ពុជាទេ តែក្រុមហ៊ុននេះត្រូវតែមានភ្នាក់ផ្តល់ប្រឹក្សាវិនិយោគ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាប័ណ្ណពីគណៈកម្មការមូលបត្រកម្ពុជា យ៉ាងតិចមួយរូប។ ក្នុងនាមជាក្រុមហ៊ុនទីប្រឹក្សាវិនិយោគ អាចមានសិទ្ធិតែធ្វើអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគប៉ុណ្ណោះ។

បច្ចុប្បន្ន ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ដែលកំពុងដំណើរការនៅកម្ពុជាមានចំនួន ០២ (ពីរ) គឺ៖

- អង្គរ ឃែភីថល អ៊ែតវ៉ាយហ្ស៊ើរ (Angkor Capital Advisors Co., Ltd.)
- អេហ្វ.យូ.ជី.អាយ. ហ្គោល (F.U.G.I GOLD Co., Ltd.)

### ២.២.៣. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ គឺជាក្រុមហ៊ុនដែលធ្វើការបោះផ្សាយ (លក់) ជាសាធារណៈនូវមូលបត្ររបស់ខ្លួនដែលអាចជា មូលបត្រកម្មសិទ្ធិ ឬមូលបត្របំណុល។ យោងទៅតាមក្របខណ្ឌច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រមហាជនទទួលខុសត្រូវមានកំរិត ឬនីតិបុគ្គលប្រតិស្រុតដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា ដើម្បីបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ក្នុងន័យសេដ្ឋកិច្ចក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ គឺជា

អ្នកផ្គត់ផ្គង់មូលបត្រនៅក្នុងទីផ្សារ។ ប្រសិនបើគ្មានក្រុមហ៊ុនបោះផ្សាយលក់មូលបត្រនោះទេ ក៏ពុំមានមូលបត្រសម្រាប់ដាក់លក់មូលបត្រនៅលើទីផ្សារមូលបត្រនោះដែរ ដូច្នេះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ គឺជាតួអង្គយ៉ាងសំខាន់មួយដែលមិនអាចខ្វះបាននៅក្នុងទីផ្សារមូលបត្រ។ ការបោះ-ផ្សាយលក់មូលបត្រជាសាធារណៈដោយក្រុមហ៊ុនបោះផ្សាយ ត្រូវបានធ្វើឡើងក្នុងបំណងកៀរគរមូលធន ឬដើមទុនពីសាធារណជន ឬពីវិនិយោគិនមូលបត្រ ដើម្បីពង្រីកការវិនិយោគ ឬដើម្បីបង្កើតការវិនិយោគថ្មីរបស់ក្រុមហ៊ុន។ ក្នុងន័យនេះ ការដាក់លក់មូលបត្រនៅលើទីផ្សារមូលបត្រ គឺជាមធ្យោបាយថ្មីមួយទៀតដែលនឹងត្រូវផ្តល់ឲ្យក្រុមហ៊ុនក្នុងការប្រមូលទុនវិនិយោគ ក្រៅពីការខ្ចីឥណ-ទានពីធានាគារ ឬពីដៃគូរពាណិជ្ជផ្សេងទៀត។

បច្ចុប្បន្ន មានក្រុមហ៊ុនរដ្ឋ និង ឯកជនដែលកំពុងបោះផ្សាយនៅកម្ពុជាមានចំនួន ០៥ (ប្រាំ) គឺ[4]៖

- កំពង់ផែស្វយ័តភ្នំពេញ(ក.ស.ភ.) គឺប្រតិបត្តិករកំពង់ផែកុងតឺន័រអន្តរជាតិមួយក្នុងចំណោម២នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក.ស.ភ. គឺជាប្រតិបត្តិករកំពង់ផែទន្លេ ធំជាងគេបំផុត និងជាអាជ្ញាធរគ្រប់គ្រងផែនៅក្នុងមណ្ឌលអាជីវកម្មផែ ស្របតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩។ មណ្ឌលអាជីវកម្មផែមានប្រវែង ១៦០ គីឡូម៉ែត្រ លាតសន្ធឹតពីខេត្តត្បូងឃ្មុំទៅដល់ព្រំប្រទល់កម្ពុជា-វៀតណាមនៅឯក្អមសំណ។ ក.ស.ភ. ទទួលសិទ្ធផ្តាច់មុខជាប្រតិបត្តិករកំពង់ផែនៅក្នុងមណ្ឌលអាជីវកម្មផែ ស្របតាមសេចក្តីជូនដំណឹងលេខ ៦០០ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ដែលចេញពីទីស្តីការគណៈរដ្ឋមន្ត្រី។ ក.ស.ភ. មានចំណតផែចម្បងៗចំនួន៤ នៅក្នុងមណ្ឌលអាជីវកម្មផែ គឺ៖ ទី១ ចំណតផែកុងតែន័រ LM១៧ ទី២ ចំណតផែពហុបំណង TS៣ ទី៣ ចំណតផែអ្នកដំណើរ និងទេសចរណ៍ TS១ ទី៤ ចំណតផែទន្លេបិទ UM២។
- ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ ក្រុមហ៊ុនទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាដើម្បីក្លាយខ្លួនជាអ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសដែលអាចធ្វើប្រតិបត្តិការអាជីវកម្មច្រើនប្រភេទ ហើយបច្ចុប្បន្ន PPSEZ កំពុងធ្វើប្រតិបត្តិការ និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសនៅទីប្រជុំជននៃរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា

[4] ផ្សារមូលបត្រកម្ពុជា

ដែលមានអាជីវកម្មចម្បងក្នុងការអភិវឌ្ឍដីឧស្សាហកម្មសម្រាប់លក់ និង/ឬជួល។ បន្ថែមពីលើនេះ ក្នុងនាមជាប្រតិបត្តិករ ក្រុមហ៊ុនក៏មានផ្គត់ផ្គង់សេវាកម្មដែលពាក់ព័ន្ធ ព្រមជាមួយបរិក្ខារចាំបាច់នានា នៅក្នុងបរិវេណ PPSEZ ដែលរួមមាន ប្រព្រឹត្តកម្មទឹកសំណល់ ការផ្គត់ផ្គង់ និងចែកចាយទឹកស្អាត សេវាជួល ការថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សេវាផ្តល់ប្រឹក្សាយោបល់ និងជំនួយកិច្ចការរដ្ឋបាល សេវាសន្តិសុខ ការផលិត និងចែកចាយថាមពលអគ្គីសនី ព្រមទាំងសេវាដែស្ទូត ជូនដល់អ្នកដែលបានជួលនិងវិនិយោគិនតំបន់ដទៃទៀតក្នុង PPSEZ។ PPSEZ រក្សាបាននូវចំនួនវិនិយោគិនតំបន់ច្រើនជាងគេក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសទាំង ៣៤ ហើយជាតំបន់សេដ្ឋកិច្ចពិសេសធំមួយ បើគិតតាមទំហំផ្ទៃដីរបស់ PPSEZ ដែលមានប្រមាណ ៣៥៧.៣២ ហិចតា។

- ក្រុមហ៊ុន ប្រេ្គនធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី គឺជាក្រុមហ៊ុនផលិត សំលៀកបំពាក់ដែលបានបង្កើតឡើងក្នុងឆ្នាំ ២០០៧។ នៅឆ្នាំ២០០៨ ក្រុមហ៊ុន ប្រេ្គនធ្វីន បានទិញយកក្រុមហ៊ុន QMI Industrial Co., Ltd ដែលជារោងចក្រកាត់ដេរដ៏ធំមួយក្នុង ចំណោមរោងចក្រកាត់ដេរធំៗដំបូងបង្អស់ដែលបានធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជាក្នុងកំឡុងទសវត្សរ៍ឆ្នាំ១៩៩០។ ក្រុមហ៊ុន ប្រេ្គនធ្វីន គឺជារោងចក្រម៉ៅការបន្ត និងជារោងចក្រ ផលិតសម្លៀកបំពាក់ផ្ទាល់សម្រាប់នាំចេញ។សព្វថ្ងៃ ផលិតផលរបស់ក្រុមហ៊ុន ប្រេ្គនធ្វីនរួមមានម៉ាកសម្លៀកបំពាក់កីឡាល្បីៗដូចជាម៉ាក Adidas, Reebok, Taylor Made, Salomon, New Balance (NB), Kohl's, Nautica, North Face, Russell Athletic។ល។ គោលដៅនាំចេញរបស់ក្រុមហ៊ុន ប្រេ្គនធ្វីន មានដូចជា បណ្តាប្រទេសក្នុងតំបន់អឺរ៉ុប (៦៣%នៃប្រាក់ចំណូលសរុបឆ្នាំ២០១៥) សហរដ្ឋអាមេរិក(១៧%នៃប្រាក់ចំណូលសរុបឆ្នាំ២០១៥) តំបន់អាស៊ីនិងបណ្តាប្រទេសដទៃទៀត(២០% នៃប្រាក់ចំណូលសរុបឆ្នាំ២០១៥)។
- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) ត្រូវបានបង្កើតឡើងក្នុងទម្រង់ជាគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ស្ថិតក្រោមច្បាប់ស្តីពីសហគ្រាសសាធារណៈ។ នៅថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១២ រ.ទ.ស.ភ បានចុះបញ្ជីជាផ្លូវការនៅផ្សារមូលបត្រកម្ពុជា ដោយបានបោះផ្សាយលក់ភាគហ៊ុនធម្មតាចំនួន ១៣.០៤៥.៩៧៥ ភាគហ៊ុន ដែលស្មើនឹង១៥%នៃចំនួនភាគហ៊ុនធម្មតាសរុប។ រ.ទ.ស.ភ. បានប្តេជ្ញាចិត្តបន្តធ្វើឲ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកបដោយចេរភាព ព្រមទាំងធ្វើជាអ្នកប្រឹក្សា ជាអ្នកសម្របសម្រួល ដើម្បីឲ្យប្រជាពលរដ្ឋនៅក្នុងទីក្រុងនិងបណ្តាខេត្តផ្សេងទៀតក្នុងប្រទេសកម្ពុជាទទួលបានទឹកស្អាតប្រើប្រាស់។ រ.ទ.ស.ភ. ក៏បាន

ប្តេជ្ញាចិត្ត ជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀតក្នុងការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋរបស់ពួកគេផងដែរ។បេសកកម្មរបស់រ.ទ.ស.ក. គឺជានាឱ្យបាននូវការផ្គត់ផ្គង់ទឹកស្អាតគ្មានមេរោគ ២៤ ម៉ោងក្នុងមួយថ្ងៃ និង ៧ ថ្ងៃក្នុងមួយសប្តាហ៍ មានសម្ពាធគ្រប់គ្រាន់ និងក្នុង តម្លៃសមស្រប ជូនប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្តកណ្តាលដែលជាប់នឹងរាជធានីភ្នំពេញ ដោយមិនមើលរំលងប្រជាពលរដ្ឋក្រីក្រឡើយ។ ក្រៅពីនេះ រ.ទ.ស.ក. បាននិងកំពុងចែករំលែកនូវបទពិសោធន៍របស់ខ្លួនដល់ បណ្តារដ្ឋាករទឹកខេត្តក្រុងមួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបណ្តា អង្គភាពទឹកស្អាតក្នុងតំបន់ និងក្នុងពិភពលោក។ រ.ទ.ស.ក. បានបូមទឹកពីទន្លេសាប ទន្លេបាសាក់ ទន្លេមេគង្គលើ និងទន្លេមេគង្គក្រោម ទៅចម្រោះនិងផលិតជាទឹកស្អាតនៅរោងចក្រផលិតទឹកស្អាតភូមិព្រែក ចំការមន ជ្រោយចង្វារ និងនិរោធ។

- កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស.) ថ្មីៗនេះ មានក្រុមហ៊ុនរដ្ឋចំនួន ០១ (មួយ) បន្ថែមទៀត ដែលទើបតែត្រូវបានអនុញ្ញាតឲ្យបោះផ្សាយមូលបត្រជាសាធារណៈនៅលើទីផ្សារមូលបត្រកម្ពុជា គឺកំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០១៧។ ក.ស.ស ជាក្រុមហ៊ុនរដ្ឋដែលបានបង្កើតឡើងដើម្បីធ្វើអាជីវកម្មសេវាកម្មមូលដ្ឋានលើកាងារៈ កណ្ឌធារកិច្ចនាំនាវាចេញ-ចូល និងផ្តល់ភស្តុភារដល់នាវា លើកដាក់ ផ្ទេរ ផ្ទុកទំនិញ ស្តុកទំនិញនៅឃ្លាំង និងទីលាន ព្រមទាំងដឹកជញ្ជូនទំនិញ។ បច្ចុប្បន្ន ក.ស.ស. ក៏កំពុងផ្តល់សេវាផ្សេងទៀត៖ សេវាក្នុងតំបន់សេដ្ឋកិច្ចពិសេសដូចជាជួលឃ្លាំងនិងថែរក្សាទំនិញលើកដាក់ និងដឹកជញ្ជូនទំនិញរួមទាំងសេវាសន្តិសុខក្នុងកំពង់ផែនិងតំបន់សេដ្ឋកិច្ចពិសេស។ ក.ស.ស. ជាកំពង់ផែរអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់នៅកម្ពុជា ដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីប្រមាណ ១២៥ ហិចតា នៅខេត្តព្រះសីហនុ ហើយត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះរួមមាន បណ្តាញផ្លូវគោក (ផ្លូវជាតិលេខ៣ និងលេខ៤) បណ្តាញផ្លូវរថភ្លើង(តភ្ជាប់ទៅរាជធានីភ្នំពេញនិងខេត្តកំពត) និងបណ្តាញផ្លូវអាកាស (តភ្ជាប់ទៅខេត្តសៀមរាប និងរាជធានីភ្នំពេញ)។

មូលបត្រដែលធ្វើសំណើលក់នេះ ត្រូវបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដោយនីតិបុគ្គលប្រតិស្រុតដែលត្រូវបានកំណត់ស្របច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

### ២.២.៣.១. ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាតដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដើម្បីបោះផ្សាយមូលបត្រដែលអាចលក់បានជាសាធារណៈ[5]។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ជាប្រភេទក្រុមហ៊ុនមូលធនដែលភាគហ៊ុននៃក្រុមហ៊ុនអាចផ្ទេរបាន ហើយការចូលរួមជាសមាជិកក្រុមហ៊ុនមិនត្រូវបានរឹតត្បិតទេ។ យោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម មានតែក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតប៉ុណ្ណោះ ដែលអាចធ្វើការបោះផ្សាយមូលបត្រជាសាធារណៈ ប៉ុន្តែការរឹតត្បិតនេះត្រូវបានកែប្រែដោយច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន ដែលបានអនុញ្ញាតឲ្យប្រភេទក្រុមហ៊ុននីតិបុគ្គលប្រតិស្រុតធ្វើការបោះផ្សាយមូលបត្រ។ ការអនុញ្ញាតនេះ មានគោលបំណងឲ្យទីផ្សារអាចដំណើរការដោយមានការចូលរួមពីក្រុមហ៊ុនបោះផ្សាយជាច្រើន និងជាឱកាសសម្រាប់ក្រុមហ៊ុនដទៃទៀតក្រៅពីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត អាចមានសិទ្ធិបោះផ្សាយមូលបត្រជាសាធារណៈ។

### ២.២.៣.២. នីតិបុគ្គលប្រតិស្រុត

នីតិបុគ្គលប្រតិស្រុត សំដៅដល់នីតិបុគ្គលដែលត្រូវបានអនុញ្ញាតឲ្យបោះផ្សាយ និងធ្វើសំណើលក់មូលបត្រជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។ នីតិបុគ្គលនេះមិនមែនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតទេ។ នីតិបុគ្គលប្រតិស្រុតនេះ អាចជាក្រុមហ៊ុនពាណិជ្ជកម្មដូចជាក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀត។ ដើម្បីអាចបោះផ្សាយលក់មូលបត្រជាសាធារណៈ នីតិបុគ្គលប្រតិស្រុតទាំងនេះ ត្រូវធ្វើការសុំអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា ដែលនេះជាអំណាចឆន្ទានុសិទ្ធិរបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ក្នុងការសម្រេចអាស្រ័យនឹងតម្រូវការទីផ្សារ។ ការផ្តល់សិទ្ធិឲ្យនីតិបុគ្គលប្រតិស្រុតក្នុងការបោះផ្សាយមូលបត្រ គឺដើម្បីឲ្យដំណើរការទីផ្សារមូលបត្រមានការចូលរួមពីក្រុមហ៊ុនបោះផ្សាយមូលបត្រច្រើន។

[5] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

### ២.២.៤. វិនិយោគិនមូលបត្រ

វិនិយោគិនមូលបត្រ គឺជាតួអង្គដែលមិនអាចខ្វះបាន។ វិនិយោគិនមូលបត្រ គឺជាអ្នកវិនិយោគទៅលើមូលបត្រដើម្បីស្វែងរកប្រាក់ចំណេញ ហើយបើការនិយាយឲ្យចំ វិនិយោគិនមូលបត្រ គឺជាអ្នកដែលទិញ-លក់មូលបត្រ។ វិនិយោគិនមូលបត្រ ត្រូវបានចែកចេញជាពីរប្រភេទ គឺវិនិយោគិនជារូបវន្តបុគ្គល និងវិនិយោគិនជាស្ថាប័ន។ វិនិយោគិនជារូបវន្តបុគ្គល សំដៅដល់សាធារណជនទូទៅ ឬប្រជាពលរដ្ឋទាំងអស់ដែលមានសាច់ប្រាក់នៅទំនេរ ហើយមានបំណងទិញ-លក់មូលបត្រនៅលើទីផ្សារ។ ដោយឡែក វិនិយោគិនជាស្ថាប័ន សំដៅដល់នីតិបុគ្គលដែលមាននៅសល់ទុនទំនេរសម្រាប់វិនិយោគលើមូលបត្រ ដែលក្នុងនោះរួមមានដូចជា គ្រឹះស្ថានធនាគារ ក្រុមហ៊ុនធានារ៉ាប់រងឬមូលនិធិសោធនិវត្តន៍ជាដើម។ វត្តមាននៃទីផ្សារមូលបត្រនៅកម្ពុជានឹងអនុញ្ញាតឲ្យវិនិយោគិនមូលបត្រទាំងអស់ដែលមាននៅសល់ទុនទំនេរ អាចយកសាច់ប្រាក់ទាំងនោះទៅឲ្យអ្នកជំនាញដែលបទពិសោធខ្ពស់ក្នុងការធ្វើធុរកិច្ច ឬអាជីវកម្មអ្វីមួយ (ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ) ដើម្បីធ្វើការវិនិយោគជំនួសខ្លួន តាមរយៈការទិញយកមូលបត្រដែលក្រុមហ៊ុនបោះផ្សាយបានដាក់លក់នៅលើទីផ្សារ។ ក្នុងករណីដែលវិនិយោគិនមូលបត្រសម្រេចទិញមូលបត្របំណុល (សញ្ញាបណ្ណ) ពីក្រុមហ៊ុនបោះផ្សាយ នោះវិនិយោគិនមូលបត្រ នឹងទទួលបានផលចំណេញជាការប្រាក់ពីក្រុមហ៊ុនបោះផ្សាយ និងនៅឥណទានប្រតិទាន ទទួលមកវិញនូវប្រាក់ដើម (Capital) ក៏ដូចជាផលចំណេញដែលបានមកពីការកើនឡើងនៃតម្លៃមូលបត្របំណុលផងដែរ។ ដោយឡែក ក្នុងករណីដែលវិនិយោគិនមូលបត្រ សម្រេចចិត្តទិញមូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ពីក្រុមហ៊ុនបោះផ្សាយ នោះវិនិយោគិនមូលបត្រ នឹងអាចទទួលបាននូវផលចំណេញដែលកើតចេញពីការឡើងថ្លៃនៃតម្លៃភាគហ៊ុននៅក្នុងទីផ្សារ និងភាគលាភដែលទទួលបានពីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ដែលជាការបែងចែកប្រាក់ចំណេញបានមកពីការវិនិយោគរបស់ក្រុមហ៊ុន។

# ជំពូកទី ៣
# ដំណើរការវិនិយោគនៅកម្ពុជា

## ៣.១. និយមន័យ

ការវិនិយោគ គឺជាការផ្តល់ប្រភពធនធាននាពេលបច្ចុប្បន្នដោយសង្ឃឹមថានឹងទទួលបានមកវិញនូវប្រភពធនធានកើនឡើង ឬធ្វើឲ្យដំណើរការរបស់ក្រុមហ៊ុនកាន់តែប្រសើរឡើងនាពេលអនាគត។ ការវិនិយោគ គឺជាការប្រើប្រាស់ ឬការចំណាយមូលនិធិដោយរំពឹងថានឹងទទួលបានចំណូល ឬការកើនឡើងជាទុន(Increase in capital) អំពីវិនិយោគនោះនៅពេលអនា គត។ ការវិនិ-យោគ គឺជាការប្រើប្រាស់សាច់ប្រាក់ដើម្បីបង្កើនសាច់ប្រាក់ (The use of money for making more money)។

អ្នកវិនិយោគសាធារណៈ (Public Investor) : សំដៅដល់សាធារណៈជននៅក្នុងព្រះរាជាណា-ចក្រកម្ពុជា រួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដែលមានសិទ្ធិទិញ ឬ លក់មូលបត្រដែលបានបោះ-ផ្សាយ និងធ្វើសំណើលក់ជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជាដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមិនមែនជាសមាការី ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬនីតិបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតនោះ[6]។

បុគ្គលទាំងឡាយណាដែលមានបំណងធ្វើការវិនិយោគ នៅក្នុងទីផ្សារមូលបត្រកម្ពុជាត្រូវចុះឈ្មោះនៅ គ.ម.ក. ដើម្បីទទួលបានលេខអត្តសញ្ញាណវិនិយោគិនពី គ.ម.ក. មុននឹងធ្វើសកម្មភាពជួញដូរមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងការចុះឈ្មោះដើម្បីទទួលបានលេខអត្ត-សញ្ញាណវិនិយោគិន វិនិយោគិនមានជម្រើសពីរគឺដាក់ពាក្យស្នើសុំមក គ.ម.ក. ដោយផ្ទាល់ ឬដាក់ពាក្យស្នើសុំតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាប័ណ្ណពី គ.ម.ក.[7]។ វិនិយោគិនមានពីរប្រភេទ គឺវិនិយោគិនជារូបវន្តបុគ្គល និងវិនិយោគិនជានីតិបុគ្គល។

[6] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

[7] ប្រកាសស្តីពីការកំណត់កម្រៃសេវាសម្រាប់ការផ្តល់លេខអត្តសញ្ញាណវិនិយោគិននៅក្នុងវិស័យមូលបត្រ

## ៣.២ ដំណើរការនៃការវិនិយោគលើទីផ្សារមូលបត្រកម្ពុជា

ដំណើរការទិញ-លក់លើទីផ្សារមូលបត្រ ពិតជាសំខាន់ណាស់សំរាប់វិនិយោគិនដែលមានបំណងចូលរួមវិនិយោគក្នុងទីផ្សារមូលបត្រកម្ពុជា។ ដើម្បីចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជានេះតម្រូវឲ្យវិនិយោគិនយល់ដឹងអំពី លក្ខខណ្ឌក្នុងការចូលរួម និងដំណាក់កាលសំខាន់ៗ។

### ៣.២.១. ប្រតិបត្តិការទីផ្សារ

#### ៣.២.១.១. ការចាប់ផ្តើមការជួញដូរ

មុននឹងចាប់ផ្តើមការជួញដូរ វិនិយោគិនទាំងអស់ត្រូវអនុវត្តជំហ៊ានងាយៗដូចខាងក្រោម៖




ក. ជ្រើសរើសក្រុមហ៊ុនមូលបត្រ

វិនិយោគិនត្រូវជ្រើសរើសក្រុមហ៊ុនមូលបត្រដែលជាសមាជិករបស់ ផ.ម.ក. ដើម្បីធ្វើជាអ្នកតំណាងរបស់ខ្លួនក្នុងការជួញដូរមូលបត្រ។

ខ. បើកគណនីជួញដូរ

នៅពេលជ្រើសរើសក្រុមហ៊ុនមូលបត្ររួចហើយ វិនិយោគិននឹងត្រូវបើកគណនីជួញដូរមួយនៅក្រុមហ៊ុនមូលបត្រនោះ។ ប៉ុន្តែ មុននឹងបើកគណនីបាន វិនិយោគិនត្រូវមានលេខអត្តសញ្ញាណវិនិយោគិន ដែលផ្តល់ដោយគណៈកម្មការមូលបត្រកម្ពុជា ។ ជាការអនុវត្ត ក្រុមហ៊ុនមូលបត្រជាអ្នកធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិននេះជូនអតិថិជនរបស់ខ្លួន ដោយយកឬមិនយកកម្រៃបន្ថែមលើ ២០.០០០រៀល ដែលតម្រូវដោយគណៈកម្មការមូលបត្រកម្ពុជា។ នៅពេលបើកគណនីរួចហើយ វិនិយោគិនត្រូវរងចាំដល់ថ្ងៃស្អែក(ថ្ងៃធ្វើការ) ទើបអាចដាក់បញ្ជាជួញដូរបាន។

*សូមបញ្ជាក់ជូនថាវិនិយោគិនម្នាក់ អាចបើកគណនីជួញដូរតែមួយគត់នៅក្រុមហ៊ុនមូលបត្រនីមួយ-ៗដែលគាត់ជ្រើសរើស ហើយការបើកគណនីជួញដូរសម្រាប់វិនិយោគិន សញ្ជាតិខ្មែរ និងសញ្ជាតិបរទេសគឺមានដំណើរការដូចគ្នា។

គ. ដាក់បញ្ជា

o វិនិយោគិនបង្គាប់ឲ្យក្រុមហ៊ុនមូលបត្ររបស់ខ្លួនដាក់បញ្ជាមកកាន់ ផ.ម.ក. ដោយបញ្ជាក់ប្រាប់យ៉ាងហោចនូវព័ត៌មានសំខាន់ៗដូចខាងក្រោម៖

- ឈ្មោះមូលបត្រ
- បរិមាណ
- ថ្លៃ
- ប្រភេទនៃបញ្ជាទិញ ឬបញ្ជាលក់។

o វិនិយោគិនអាចបង្គាប់ទៅក្រុមហ៊ុនមូលបត្រឲ្យដាក់បញ្ជា ដោយប្រើប្រាស់មធ្យោបាយទំនាក់ទំនងណាមួយខាងក្រោម៖

- ឯកសារជាលាយលក្ខណ៍អក្សរ
- ពាក្យសំដី
- សារអេឡិចត្រូនិក
- មធ្យោបាយអេឡិចត្រូនិចដទៃទៀត

### ៣.២.១.២. នីតិវិធីមូលដ្ឋាននៃការជួញដូរ

ក. ការបើកគណនី និងការដាក់បញ្ជា

ដើម្បីអាចធ្វើការជួញដូរនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) វិនិយោគិនទាំងឡាយត្រូវបើកគណនីជួញដូរមួយជាមុនសិន នៅក្រុមហ៊ុនមូលបត្រណាមួយដែលជាសមាជិករបស់ ផ.ម.ក.។ មួយថ្ងៃក្រោយមក ទើបវិនិយោគិនអាចបង្គាប់ឲ្យក្រុមហ៊ុនមូលបត្រនោះ (ដែលដើរតួនាទីជាអន្តរការី) ដាក់បញ្ជាមកកាន់ផ.ម.ក.។ វិនិយោគិនអាចដាក់បញ្ជាបានលុះត្រាមានសាច់ប្រាក់យ៉ាងហោចណាស់មួយរយភាគរយ (សម្រាប់បញ្ជាទិញ) ឬបរិមាណមូលបត្រយ៉ាងហោចណាស់មួយរយភាគរយ (សម្រាប់បញ្ជាលក់)។ នៅពេលបញ្ជាត្រូវបានបញ្ជូន សាច់ប្រាក់និងមូលបត្រទាំងនេះនឹងត្រូវបានបង្កកទុកដោយក្រុមហ៊ុនមូលបត្រ ក្នុងគោលបំណងដើម្បីទុកទូទាត់ ឬបង្កកទុករហូតដល់បញ្ជានោះអស់សុពលភាព។

ខ. ការអនុវត្តការជួញដូរ និងការជូនដំណឹង

ប្រព័ន្ធជួញដូររបស់ ផ.ម.ក.ធ្វើការផ្គូផ្គង និងអនុវត្តបញ្ជានានាដែលត្រូវបានបញ្ជូនមក ដោយយោងទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន ហើយបន្ទាប់មកជូនដំណឹងអំពី

លទ្ធផលនៃការជួញដូរនោះទៅកាន់ក្រុមហ៊ុនមូលបត្រ ជាសមាជិកដែលពាក់ព័ន្ធ និង ក្រោយមក ក្រុមហ៊ុនមូលបត្រនោះជូនដំណឹងបន្តទៅអតិថិជនរបស់ខ្លួន (ដែលជាវិនិយោគិន)។

គ. ការទូទាត់

o នៅពេលព័ត៌មានជួញដូរត្រូវបានបញ្ជាក់ដោយអតិថិជនពាក់ព័ន្ធរួចហើយ សមាជិកទាំងអស់ដែលតាងនាមឲ្យអតិថិជនរបស់ខ្លួនត្រូវបង់ប្រាក់សម្រាប់មូលបត្រដែលបានទិញ ឬបញ្ជូនមូល-បត្រដែលបានលក់ទៅកាន់ភាគីម្ខាងទៀត (ដែលជាសមាជិកដែរ) ដោយប្រើប្រាស់សាច់ប្រាក់ ឬមូលបត្រដែលត្រូវបានបង្កកទុកកន្លងមកនោះ។




(១) វិនិយោគិនបើកគណនីជួញដូរ (គណនីសាច់ប្រាក់និងគណនីមូលបត្រ) នៅក្រុមហ៊ុនមូលបត្រមួយ នៅមួយថ្ងៃមុនថ្ងៃជួញដូរ។

(២) វិនិយោគិនផ្តល់សេចក្តីបង្គាប់ឲ្យដាក់បញ្ជា (ទិញឬលក់) ទៅកាន់ក្រុមហ៊ុនមូលបត្រជាលាយលក្ខណ៍អក្សរ ពាក្យសំដី (ថតទុក) ឬមធ្យោបាយអេឡិចត្រូនិចនានា។

(៣) ក្រុមហ៊ុនមូលបត្រដាក់បញ្ជាទៅតាមការបង្គាប់មកកាន់ ផ.ម.ក. ប៉ុន្តែមុននឹងដាក់បញ្ជា ក្រុមហ៊ុនមូលបត្របានបង្កកទុករួចហើយនូវសាច់ប្រាក់ ឬបរិមាណមូលបត្រយ៉ាងហោចមួយរយភាគរយនៃបញ្ជានីមួយៗ។

(៤) បញ្ជាទាំងឡាយត្រូវបានផ្គូផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន។

(៥) ផ.ម.ក. ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រ នៅថ្ងៃ T+0។

(៦)ក្រុមហ៊ុនមូលបត្របញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗរបស់ខ្លួន (នៅ T+0)។

(៧) ក្នុងករណីមានកំហុសឆ្គងប្រតិបត្តិការបង្កឡើងដោយក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់ ផ.ម.ក. ដើម្បីកែតម្រូវមុនពេលថ្ងៃត្រង់នៃថ្ងៃ T+1។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយ ដំណើរការក្នុងចំនុចទី៥ និងទី៦ នឹងត្រូវអនុវត្តម្តងទៀត។

(៨) វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រ។ ប៉ុន្តែជាក់ស្តែង គឺក្រុមហ៊ុនមូលបត្រប្រើប្រាស់សាច់ប្រាក់ឬ មូលបត្ររបស់អតិថិជន ដែលបានបង្កកទុកដើម្បីទូទាត់ ដោយសុំឬមិនបាច់សុំការអនុញ្ញាតពីអតិថិជនឡើយ។

(៩) ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមវិនិយោគិននៅ ផ.ម.ក។

### ៣.២.១.៣. ប្រតិបត្តិការទីផ្សារ

ក. ម៉ោងជួញដូរ




- ផ្សារហ៊ុនចាប់បើកទទួលបញ្ជាទិញ/លក់ពីវិនិយោគិនពីម៉ោង ០៨:០០ ព្រឹក និងបិទនៅម៉ោង ១១:៣០ ព្រឹក។ ប៉ុន្តែ ការជួញដូរចាប់ធ្វើឡើងពីម៉ោង ០៩:០០ ដល់ម៉ោង ១១:០០ ព្រឹក និងនៅម៉ោង ១១:៣០ ព្រឹក ម្តងទៀតមុនពេលបិទផ្សារ។

ខ. ថ្ងៃជួញដូរ

o ថ្ងៃជួញដូរចាប់ផ្តើមពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ។

គ. ប្រភេទនៃបញ្ជា

o បច្ចុប្បន្ន យើងមានបញ្ជាតែមួយប្រភេទប៉ុណ្ណោះនៅផ.ម.ក. គឺ "បញ្ជាមានកំណត់"។ បញ្ជាមានកំណត់៖ បញ្ជាដែលថ្លៃទិញគឺជាថ្លៃហ៊ានទិញខ្ពស់បំផុត ឬបញ្ជាដែលថ្លៃលក់គឺជាថ្លៃហ៊ានលក់ទាបបំផុត។

ឧទាហរណ៍៖ បញ្ជាទិញមានកំណត់មួយដែលមានថ្លៃ៥០,០០០រៀល អាចនឹងត្រូវបានជួញដូរនៅថ្លៃ ៥០,០០០រៀលឬថោកជាងនេះ ហើយចំណែកឯបញ្ជាលក់មានកំណត់ដែលមានថ្លៃ៥០,០០០រៀល អាចនឹងត្រូវបានជួញដូរនៅថ្លៃ ៥០,០០០រៀលឬខ្ពស់ជាងនេះ។

ឃ. ថ្លៃមូលដ្ឋាន

o ជាទូទៅ ថ្លៃមូលដ្ឋានគឺជាថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ។ ថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ដំបូងត្រូវស្ថិតនៅចន្លោះ ៩០%និង១៥០% នៃថ្លៃមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ជាលើកដំបូង (ថ្លៃ IPO ដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីនៅ គ.ម.ក.)។ ក្នុងករណីដែលមានសិទ្ធិកម្មសិទ្ធិករមូលបត្រដូចជា ការបង្កើនឬបន្ថយមូលធន ការបែងចែកភាគលាភជាភាគហ៊ុន ការបំបែកភាគហ៊ុន ។ល ។ នោះថ្លៃមូលដ្ឋាននឹងត្រូវបានគណនាដោយស្វ័យប្រវត្តិ ដោយប្រព័ន្ធរបស់ ផ.ម.ក.តាមរយៈការប្រើប្រាស់នូវរូបមន្តមួយជាក់លាក់។ ក្នុងករណីថ្លៃមូលបត្រដែលបានគណនា ទាបជាងឯកតាគម្លាតថ្លៃ នោះថ្លៃមូលដ្ឋានត្រូវបង្គត់ឡើងឲ្យស្មើនឹងឯកតាគម្លាតថ្លៃ។

ង. ឯកតាជួញដូរ និង ឯកតាគម្លាតថ្លៃ

o ឯកតាបញ្ជាមូលបត្រកម្មសិទ្ធិនៅផ.ម.ក. គឺ ០១ (មួយ)ឯកតាមូលបត្រ។

o បរិមាណជួញដូរមូលបត្រកម្មសិទ្ធិអប្បបរមាក្នុងមួយប្រតិបត្តិការ នៅផ.ម.ក. គឺ ០១(មួយ) ឯកតាមូលបត្រ។ ថ្លៃប្រែប្រួលទៅតាមឯកតាថ្លៃ (ឯកតាគម្លាតថ្លៃ) ដែលត្រូវបានកំណត់ដូចខាងក្រោម(ទឹកប្រាក់ទាំងអស់គិតជារៀល)៖

| ថ្លៃ (P) | ឯកតាគម្លាតថ្លៃ | ឧទាហរណ៍ថ្លៃបញ្ញាដែលខុស | ឧទាហរណ៍ថ្លៃបញ្ញាដែលត្រឹមត្រូវ |
|---|---|---|---|
| ]0 – ៩.000[ | ១0 | ២.៥៥៥; ៣.0១២; ៣.៩៩៩ | ២.៥៥0; ២.៥៦0; ៣.0១0; ៣.0២0; ៣.៩៩0 |
| [៩.000 – ២0.000[ | ២0 | ៩.២១0; ១៩.៥២៥ | ៩.២00; ៩.២២0; ១៩.៥២0; ១៩.៥៤0 |
| [២0.000 – ៤0.000[ | ៥0 | ២0.១១0; ៣៥.៥៣0 | ២0.១00; ២0.១៥0; ៣៥.៥00; ៣៥.៥៥0 |
| [៤0.000 – ១00,000[ | ១00 | ៥0.៧២0; ៩0.៤៥0 | ៥0.៧00; ៥0.៨00; ៩0.៤00; ៩0.៥00 |
| [១00.000 – ២00.000[ | ២00 | ១៥0.៥00; ១២៥.៣00 | ១៥0.៤00; ១៥0.៦00; ១២៥.២00; ១២៥.៤00 |
| [២00.000 – ៤00.000[ | ៥00 | ៣00.១00; ៣៥0.២00 | ៣00.000; ៣00.៥00; ៣៥0.000; ៣៥0.៥00 |
| [៤00.000 – [ | ១.000 | ៦២0.៥00; ៨៥២.១00 | ៦២0.000; ៦២១.000; ៨៥២.000; ៨៥៣.000 |

## ច. ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃ

- ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃត្រូវស្មើនឹង ±៥% (បូក/ដកប្រាំភាគរយ)នៃថ្លៃមូលដ្ឋាន។

o ករណីទី ១ ថ្លៃមូលដ្ឋាន = ១២.០០០ ៛




o ករណីទី 2 ថ្លៃមូលដ្ឋាន = ៤.០០០ ៛



o ករណីទី ៣ ថ្លៃមូលដ្ឋានទាបជាង ២០០ ៛

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| ដែនកំណត់ថ្លៃខាងលើ (+៥%) | ១៦០ | ឯកតាគម្លាតថ្លៃ ១០៛ |
| ថ្លៃមូលដ្ឋាន | ១៥០ | |
| ដែនកំណត់ថ្លៃខាងក្រោម (-៥%) | ១៤០ | |

១៥០ x ៥% = ៧.៥ => ១០៛
១៥០ + ១០ = ១៦០ ដែនកំណត់ថ្លៃខាងលើ
១៥០ - ១០ = ១៤០ ដែនកំណត់ថ្លៃខាងក្រោម

o ករណីទី ៤ ថ្លៃមូលដ្ឋាន= ១៩.៥៨០ ៛

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | ២០.៤៤០ | |
| ដែនកំណត់ថ្លៃខាងលើ | ២០.៤០០ | ឯកតាគម្លាតថ្លៃ ៥០៛ |
| | ២០.៤៥០ | |
| | . | |
| | ២០.០៥០ | |
| | ២០.០០០ | |
| | ១៩.៩៥០ | ឯកតាគម្លាតថ្លៃ ២០៛ |
| | . | |
| | ១៩.៦០០ | |
| ថ្លៃមូលដ្ឋាន | ១៩.៤៨០ | |
| | ១៩.៤៦០ | |
| | . | |
| | ១៨.៦៤០ | |
| ដែនកំណត់ថ្លៃខាងក្រោម | ១៨.៦២០ | |

១៩.៤៨០ x ៥% = ៩៧៤ => ៩៦០៛
១៩.៤៨០ + ៩៦០ = ២០.៤៤០
១៩.៤៨០ - ៩៦០ = ១៨.៦២០

o ករណីទី ៥ ថ្លៃមូលដ្ឋាន= ២០.៨៥០ ៛

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| ដែនកំណត់ថ្លៃខាងលើ | ២១.៨៥០ | |
| | ២១.៨០០ | |
| | : | |
| | ២០.៩០០ | |
| ថ្លៃមូលដ្ឋាន | ២០.៨៥០ | ឯកតាគម្លាតថ្លៃ ៥០៛ |
| | ២០.៨០០ | |
| | : | |
| | ២០.០៥០ | |
| | ២០.០០០ | |
| | ១៩.៩៥០ | |
| | : | ឯកតាគម្លាតថ្លៃ ២០៛ |
| | ១៩.៩០០ | |
| ដែនកំណត់ថ្លៃខាងក្រោម | ១៩.៨៥០ | |
| | ១៩.៨០០ | |

២០.៨៥០ x ៥% = ១.០៤៣ => ១.០០០៛
២០.៨៥០ + ១.០០០ = ២១.៨៥០
២០.៨៥០ - ១.០០០ = ១៩.៨៥០

ឆ. សុពលភាពនៃបញ្ជា

បញ្ជានីមួយៗមានសុពលភាព ចាប់ពីពេលដែលទទួលបាននៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. រហូតដល់ពេលដែលបញ្ជានោះត្រូវបានអនុវត្តនៅអំឡុងវគ្គជួញដូរនៃថ្ងៃតែមួយ។

ជ. ការកែប្រែ និងការលុបចោលបញ្ជាដែលបានបញ្ជូន

ការកែប្រែឬការលុបចោលបញ្ជាអាចធ្វើទៅបាន ដរាបណាបញ្ជានោះមិនទាន់ត្រូវបានអនុវត្ត។ ពេលវេលាបញ្ជាក់ពីការទទួលបញ្ជានៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ត្រូវកំណត់សាជាថ្មី នៅពេលដែលមានការកែប្រែថ្លៃឬ ការបង្កើនបរិមាណនៃបញ្ជា។

ឈ. គោលការណ៍ដេញថ្លៃ

រាល់ការជួញដូរទាំងអស់ត្រូវបានអនុវត្តតាមរយៈការប្រើប្រាស់វិធីសាស្ត្រដេញថ្លៃ ដោយយកថ្លៃតែមួយ។

អាទិភាពនៃបញ្ជាទិញ និងបញ្ជាលក់៖

១. ថ្លៃ

- បញ្ជាលក់ដែលមានថ្លៃទាបជាង មានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង។
- បញ្ជាទិញដែលមានថ្លៃខ្ពស់ជាង មានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។

២. ពេលវេលា

- ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា បញ្ជាដែលទទួលបានមុនមានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

  - ឧទាហរណ៍

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | : | |
| | ៦.៥២០ | ៥០០① |
| | ៦.៥០០ | ១០០② ២០០③ |
| : | ៦.៤៨០ | : |
| : | ៦.៤៦០ | : |
| ៣០០③ ២០០② | ៦.៤២០ | |
| (ថ្លៃលក់ទាបបំផុត) ៤៥០① | ៦.៤០០ | |
| | : | |

ដូចដែលបានបង្ហាញនៅក្នុងតារាងខាងលើ បញ្ជាទិញ(១) និងបញ្ជាលក់(១) ត្រូវបានអនុវត្តមុន ស្របទៅតាមអាទិភាពថ្លៃ។ ហើយក្នុងចំណោមបញ្ជាដែលមានថ្លៃស្មើគ្នា បញ្ជា(២) ដែលទទួលបានមុន ត្រូវបានអនុវត្តមុនបញ្ជា(៣)។

ញ. វិធីសាស្ត្រនិងយន្តការនៃការអនុវត្តការជួញដូរ

- រាល់ការជួញដូរ ត្រូវអនុវត្តតាមរយៈការប្រើប្រាស់វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ឬ វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន ។
- ឧទាហរណ៍៖ វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | 10,500 | |
| ❶ ~~300~~ | 10,400 | ❸ ~~700~~ 100 |
| ❷ ~~200~~ | 10,300 | |
| ❹ ~~100~~ | 10,200 | |
| | 10,100 | |
| 600 | សរុប | 700 |

ដល់ម៉ោងជួញដូរ (ម៉ោង ០៩:០០ ឬ ១១:៣០)÷
600 x 10,400 ៛ = 6,240,000 ៛

- ឧទាហរណ៍៖ វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | 10,500 | |
| ❶ ~~300~~ | 10,400 | ❸ ~~700~~ 100 |
| ❷ ~~200~~ | 10,300 | |
| ❹ ~~100~~ | 10,200 | |
| | 10,100 | |
| 600 | សរុប | 700 |

ម៉ោងជួញដូរ(09:00-11:00 ព្រឹក)

1. 200 x 10,300 ៛ = 2,060,000 ៛ (ភ្នាមៗ)
2. 300 x 10,400 ៛ = 3,120,000 ៛ (ភ្នាមៗ)
3. 100 x 10,400 ៛ = 1,040,000 ៛ (ភ្នាមៗ)

6,220,000 ៛

ញ. កាលបរិច្ឆេទអិចឌីវីដឹនដ៍ ឬអិចរាយថ៍

កាលបរិច្ឆេទអិចឌីវីដឹនដ៍ (Ex-Dividend) ឬអិចរាយថ៍ (Ex-Right) គឺជាកាលបរិច្ឆេទជួញដូរនៅ ០១ (មួយ) ថ្ងៃ មុនកាលបរិច្ឆេទកំណត់ទុក (Record Date) ដែលជាកាលបរិច្ឆេទកំណត់បញ្ជីឈ្មោះភាគហ៊ុននិកដែលត្រូវទទួលបានភាគលាភ ឬសិទ្ធិ។

### ៣.២.១.៤. ការផ្សាយជាសាធារណៈនូវព័ត៌មានទីផ្សារ

ផ.ម.ក. ផ្តល់ជូននូវទិន្នន័យទីផ្សារដ៏មានប្រសិទ្ធិភាព នៅក្នុងបរិស្ថានមួយដែលផ្អែកលើភាពយុត្តិធម៌ តម្លាភាព ភាពមានសណ្តាប់ធ្នាប់ និងវិធានជាគោល។ វិនិយោគិននិងអ្នកចូលរួមទាំងអស់អាចទទួលបាននូវអត្ថប្រយោជន៍ពីព័ត៌មានទីផ្សារដែលងាយស្រួលយល់និងត្រឹមត្រូវ ដែលបានផ្តល់ឲ្យគ្រប់ភាគីទាំងអស់ក្នុងពេលដំណាលគ្នា។ ក្នុងន័យនេះ ផ.ម.ក. ផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យទីផ្សារដូចខាងក្រោម៖

- ថ្លៃបើក និង ថ្លៃបិទ
- បរិមាណ និង តម្លៃសរុបនៃការជួញដូរ
- ថ្លៃ និង បរិមាណរំពឹងទុក
- ថ្លៃមូលដ្ឋាន
- សន្ទស្សន៍
- ព័ត៌មានដែលមានប្រយោជន៍ដទៃទៀត។

#### ៣.២.១.៥. ការត្រួតពិនិត្យនិង ឃ្លាំមើលទីផ្សារ

ដើម្បីធានាបាននូវសុច្ចរិតភាពទីផ្សារ និងការការពារវិនិយោគិន ផ.ម.ក. ការឃ្លាំមើលទីផ្សារ ដើម្បីកំណត់អត្តសញ្ញាណមូលបត្រដែលជាប់សង្ស័យថា មានការជួញដូរមិនប្រក្រតីតាមរយៈការតាមដានឥរិយាបថនៃការជួញដូរ បម្រែបម្រួលថ្លៃ ទំហំជួញដូរ កម្រិតនៃទំនាក់ទំនងរវាងថ្លៃនិងការជួញដូរ និងព័ត៌មានលម្អិតនៃពាក្យចចាមអារ៉ាម។ បុគ្គលណាដែលត្រូវបានរកឃើញថាបានប្រព្រឹត្តដោយចេតនានូវការជួញដូរផ្ទៃក្នុងឬឧបាយកលទីផ្សារ នឹងត្រូវទទួលទោសចំពោះមុខច្បាប់ និងបទ-បញ្ញត្តិនានាដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ៣.២.២. ការផាត់ទាត់ និងការទូទាត់

ក. ការផាត់ទាត់




ការផាត់ទាត់គឺជាលំដាប់នៃដំណើរការដែល Central Counter-party (CCP)ចាត់ចែងធានាលើការទូទាត់ដោយការបន្សុទ្ធ ឬកាត់កង netting ឥណទាន និងបំណុលទាំងឡាយរវាងអ្នកលក់ និងអ្នកទិញ។

- Central Counter- party (CCP)

សំដៅលើអង្គភាពដែលទទួលយក កាតព្វកិច្ចជាអ្នកទិញចំពោះអ្នកលក់ទាំងអស់ និងជាអ្នកលក់ចំពោះអ្នកទិញទាំងអស់។ តាមវិធីនេះ អ្នកទិញ និងអ្នកលក់មិនមានកាតព្វកិច្ចហិរញ្ញវត្ថុចំពោះគ្នាទៅវិញទៅមកទេ ផ្ទុយទៅវិញត្រូវមានកាតព្វកិច្ចហិរញ្ញវត្ថុចំពោះCCP។ ក្នុងករណីនេះផ្សារមូល-បត្រកម្ពុជា (ផ.ម.ក)មានតួនាទីជា CCPនៅក្នុងផ្សារមូលបត្រកម្ពុជា។




- ការបន្សុទ្ធ ឬការកាត់កង (Netting): គឺជាដំណើរការនៃការកាត់បន្ថយកាតព្វកិច្ចឥណទាន ឬឥណពន្ធរបស់អ្នកជួញដូរជាច្រើន ពីចំនួនច្រើនទៅចំនួនតិច។ តាមរយៈការបន្សុទ្ធ ផ.ម.ក. គណនាទំហំដែលត្រូវទូទាត់ចុងក្រោយ។ បន្ទាប់ពីការបន្សុទ្ធ កាតព្វកិច្ចឥណទាន ឬឥណពន្ធដើមត្រូវបានជំនួសដោយកាតព្វកិច្ចឥណទាន ឬឥណពន្ធតែមួយ។ ទំហំដែលត្រូវទូទាត់ចុងក្រោយ ត្រូវបានគណនាតាមរបៀបដូចខាងក្រោម៖
    - ករណីមូលបត្រ៖ ទទួលបានដោយធ្វើការបន្សុទ្ធបរិមាណបានលក់សរុប និងបរិមាណបានទិញសរុប ចំពោះប្រភេទមូលបត្រមួយ និងចំពោះសមាជិកនីមួយៗ។
    - ករណីសាច់ប្រាក់៖ ទទួលបានដោយធ្វើការផាត់ទាត់តម្លៃបានទិញសរុប និងតម្លៃបានលក់សរុបចំពោះសមាជិកនីមួយៗ។

ខ. ការទូទាត់




ការទូទាត់គឺជាការបញ្ចប់ប្រតិបត្តិការ ដែលអ្នកលក់ផ្ទេរមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុទៅឲ្យអ្នកទិញ ហើយអ្នកទិញផ្ទេរសាច់ប្រាក់ទៅឲ្យអ្នកលក់។ លក្ខណៈនៃការទូទាត់របស់ ផ.ម.ក.៖

- វិធីសាស្ត្រនៃការទូទាត់៖ DVP3 (ការប្រគល់មូលបត្រ ផ្ទួរនឹងសាច់ប្រាក់គំរូទី៣) DVP3 ជាដំណើរការនៃការប្រគល់មូលបត្រ ដែលត្រូវបានធ្វើឡើងក្នុងពេលដំណាលគ្នានៃការ

ប្រគល់សាច់ប្រាក់ ដោយផ្អែកលើមូលដ្ឋានបន្សុទ្ធ (បន្សុទ្ធមូលបត្រ និង បន្សុទ្ធសាច់ប្រាក់) ។វាត្រូវបានកើតឡើងនៅចុងគ្រានៃវដ្តដំណើរការប្រតិបត្តិការ។

- ពេលវេលានៃការទូទាត់៖ ម៉ោង៨និង៣០នាទីព្រឹក(T+2)សមាជិកត្រូវផ្ទេរមូលបត្រនិងសាច់ប្រាក់ដែលត្រូវទូទាត់ទៅគណនីរបស់ ផ.ម.ក. នៅមុនម៉ោង ៨:៣០ព្រឹក នៅកាលបរិច្ឆេទទូទាត់ ហើយផ.ម.ក. ត្រូវទូទាត់មូលបត្រ និងសាច់ប្រាក់បន្តទៅឲ្យសមាជិកដែលត្រូវទទួលការទូទាត់ បន្ទាប់ពីម៉ោង ៨:៣០ព្រឹក នៅថ្ងៃដដែលនៃកាលបរិច្ឆេទទូទាត់។
- ភ្នាក់ងារទូទាត់សាច់ប្រាក់ (ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា និង ធនាគារ BIDC) មានតួនាទីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

### ៣.២.៣. ការរក្សាទុកមូលបត្រ

ប្រតិបត្តិកររក្សាទុកមូលបត្រសំដៅដល់កន្លែងសម្រាប់ដាក់ផ្ញើមូលបត្រ។ ការដាក់ផ្ញើមូល-បត្រ គឺជាដំណើរការនៃការផ្ទេរកម្មសិទ្ធិករមូលបត្រ តាមរយៈការផ្ទេររវាងគណនី (Book Entry) (ការកត់ត្រាឥណទាន/ឥណពន្ធ ក្នុងសៀវភៅគណនីរបស់សមាជិក និងអ្នកចូលរួម) ដោយគ្មានចរន្តនៃការផ្ទេរមូលបត្ររូបវន្ត។

ក. អត្ថប្រយោជន៍

នៅពេលមូលបត្រមានការជួញដូររវាងវិនិយោគិន ប្រតិបត្តិកររក្សាទុកមូលបត្រធ្វើការទូទាត់នូវប្រតិបត្តិការទាំងនោះតាមរយៈការផ្ទេររវាងគណនី (Book Entry)ដោយគ្មានការផ្ទេរមូលបត្ររូប-វន្ត។ ដូច្នេះហានិភ័យចំពោះការបាត់ និងការលួចមូលបត្រត្រូវបានជៀសវាងទាំងស្រុង។ សមាជិក អ្នកចូលរួម និងអតិថិជន ដែលបានដាក់ផ្ញើមូលបត្រនៅ ផ.ម.ក. មិនចាំបាច់ដកមូលបត្រទៅវិញ នៅពេលដែលត្រូវអនុវត្តសិទ្ធិកម្មសិទ្ធិករឡើយ។

ខ. ការបើកគណនី

បុគ្គលដែលអាចបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្ររួមមាន ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។ បុគ្គលដែលមានបំណងបើកគណនីមូលបត្រត្រូវបំពេញបែបបទបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។ គ្រប់គណនីមូលបត្រទាំងអស់ រួមមានគណនីមូលបត្ររបស់សមាជិក ឬ អតិថិជនត្រូវបានបង្កើតឡើងក្នុង ប្រព័ន្ធ Ledger (ledger

system) របស់ ផ.ម.ក. ដែលផ្ទុកផងដែរនូវទិន្នន័យលម្អិតនៃប្រតិបត្តិការរបស់សមាជិក និងអតិថិជន ព្រមទាំងទិន្នន័យលម្អិតនៃបញ្ជីភាគហ៊ុនិក។

គ. ការដាក់ផ្ញើមូលបត្រ

ដើម្បីដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ បុគ្គលដែលដាក់ផ្ញើត្រូវផ្តល់ព័ត៌មានដូចខាងក្រោមដល់ប្រតិបត្តិកររក្សាទុកមូលបត្រ :

- ប្រភេទមូលបត្រ
- ចំនួននៃការបោះផ្សាយ
- ឈ្មោះមូលបត្រ
- អក្សរកូដ
- ចំនួនមូលបត្រសរុប
- កាលបរិច្ឆេទបោះផ្សាយ
- កាលបរិច្ឆេទចុះបញ្ជី
- ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងកម្មសិទ្ធិភាពមូលបត្រ

## ៣.៣. ដំណើរការនៃការវិនិយោគលើឧបករណ៍និស្សន្ទ

### ៣.៣.១. និយមន័យឧបករណ៍និស្សន្ទ

ឧបករណ៍និស្សន្ទ (Derivative Instrument)៖ សំដៅដល់កិច្ចសន្យាលើគំលាតថ្លៃនៃឧបករណ៍ហិរញ្ញវត្ថុដើមដែលចេញពីមូលបត្រកម្មសិទ្ធិ មូលបត្របំណុល សន្ទស្សន៍លោហៈធាតុមានតម្លៃ ប្រេងឆៅ ឧស្ម័នធម្មជាតិ កសិផល រូបិយបណ្ណ រួមទាំងគម្រោងការពារថ្លៃដើម ជាដើម និងដែលត្រូវបានជួញដូរក្នុងទីផ្សារ[៨]។ ឧបករណ៍និស្សន្ទទាំងនេះ គឺជាឧបករណ៍ហិរញ្ញវត្ថុ ដែលជាប្រភេទមួយនៃមូលបត្រ។ ឧបករណ៍និស្សន្ទ គឺជាឧបករណ៍វិនិយោគក្នុងវិស័យមូលបត្រ។ ការជួញដូរឧបករណ៍និស្សន្ទ គឺជាការជួញដូរកិច្ចសន្យាអនាគត ដែលក្នុងនោះមានដូចជា រូបិយប័ណ្ណអន្តរជាតិ (ការជួញដូរហាងឆេងលុយ ឬ Forex) ការជួញដូរមាស ប្រាក់ ប្រេងឆៅ... ឬជាការជួញដូរសន្ទស្សន៍ភាគហ៊ុនបរទេស។ ការជួញដូរឧបករណ៍និស្សន្ទត្រូវបានធ្វើឡើងនៅទីផ្សារបរទេស។ នៅក្នុងការជួញដូរ

[៨] ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ

រូបិយប័ណ្ណអន្តរជាតិគេប្រើប្រាស់ប្រាក់ដុល្លាក្នុងការជួញដូរ។ Forex គឺជាការជួញដូរតំលៃផលធៀបនៃរូបិយប័ណ្ណពីរ។ ឧទាហរណ៍ USD/CHF, GBP/USD, EUR/USD, USD/JPY,...ឬហាងឆេងមាស។ ប្រភេទឧបករណ៍និស្សន្ទដែលយើងពេញនិយមនៅកម្ពុជាមានដូចជា រូបិយប័ណ្ណអន្តរជាតិ (Forex) និង ការជួញដូរមាស។

### ៣.៣.២. យន្តការនៃការជួញដូរអត្រាប្តូរប្រាក់បរទេស(Forex) និងហាងឆេងមាស




ឧបករណ៍និស្សន្ទធ្វើការជួញដូរពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ជួញដូរ ២៤ម៉ោង លើកលែងថ្ងៃបុណ្យអន្តរជាតិ។ ឯកតាជួញដូររបស់ឧបករណ៍និស្សន្ទគិតជា Lot ការជួញដូរអប្បរមាចាប់ពី 0,1 Lot ឬ (0,01 Lot)។ បើយើងប្រៀបធៀប ភាគហ៊ុន និង ឧបករណ៍និស្សន្ទ គឺឧបករណ៍និស្សន្ទមានហានិភ័យខ្ពស់ជាង និងទទួលបានប្រាក់ចំណេញខ្ពស់ជាង។

អ្នកវិនិយោគត្រូវបើកគណនី នៅក្រុមហ៊ុនឈ្មួញជើងសារ(Broker)ណាមួយដែលមានដូចជា (ហ្គោលដេន អេហ្វអិកស៍លីង (ខេមបូឌា)/ ភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី/ រ៉ូយ៉ាល់ ហ្វាយនែនសល ឧប-

ភើរេសិន/ ហ្គោល ហ្វាយនេនសល គ្លូប៊ល អ៊ិនវេសម៉ិន/ ហ្គោលអេហ្វអិកស៍ អ៊ិនវេសម៉ិន/ អេហ្វ.យូ.-ជី.អាយ. ហ្គោល) ដោយដំកល់ប្រាក់ដំបូងក្នុងគណនីចំនួន ៤.០០០.០០០(បួនលាន) រៀល ឬ១០០០ (មួយពាន់) ដុល្លាអាមេរិក។ វិនិយោគិនអាចបើកគណនីជួញដូរឧបករណ៍និស្សន្ទបានមួយនៅឈ្មួញជើងសាឧបករណ៍និស្សន្ទមួយ ដោយគណនីជួញដូរនោះមានទំហំសាច់ប្រាក់មិនលើសពី ៤០.០០០.០០០ (សែសិបលាន) រៀល ឬ ១០.០០០ (ដប់ពាន់) ដុល្លាអាមេរិក[៩]។ វិនិយោគិនអាចបើកគណនីជួញដូរមានទំហំសាច់ប្រាក់លើសពីការកំណត់ខាងលើ ដោយត្រូវមានការអនុញ្ញាតដោយឡែពីអគ្គនាយកនៃ គ.ម.ក.។ យោងតាមក្របខណ្ឌច្បាប់ ឈ្មួញជើងសារឧបករណ៍និស្សន្ទ សំដៅដល់ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ ឬក្រុមហ៊ុនមូលបត្រដែលទទួលបានការអនុញ្ញាតពីអគ្គ-នាយកនៃគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ដើម្បីធ្វើអាជីវកម្មជើងសារឧបករណ៍និស្សន្ទ។ បន្ទាប់ពីវិនិយោគិនបានបើកគណនីនៅក្រុមហ៊ុនឈ្មួញជើងសាររួច ពួកគេអាចធ្វើការបញ្ជាទិញទៅក្រុមហ៊ុនឈ្មួញជើងសារដែលគេបានបើកគណនី។ ចំណែកឯភ្នាក់ងារជើងសាឧបករណ៍និស្សន្ទសំដៅដល់រូបវន្តបុគ្គលដែលត្រូវទទួលអាជ្ញាបណ្ណពីអគ្គនាយកនៃ គ.ម.ក. ដើម្បីបើក និងគ្រប់គ្រងគណនីឲ្យអតិថិជន និង ផ្តល់សេវាផ្សេងទៀតក្នុងនាមឈ្មួញជើងសារឧបករណ៍និស្សន្ទ។ គ្មានបុគ្គលណាមួយអាចធ្វើជាភ្នាក់ងារជើងសារ និងតាំងខ្លួនជាឈ្មួញជើងសារបានទេលើកលែងតែបុគ្គលនិងក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណអគ្គនាយកនៃ គ.ម.ក.។ ក្រុមហ៊ុនឈ្មួញជើងសារបញ្ជូនបញ្ជា ទៅកាន់ក្រុមហ៊ុនសមភាគីកណ្តាល (Central Counter Party) បន្ទាប់មក CCP ធ្វើការផ្គូរផ្គងបញ្ជារវាងអ្នកលក់និងអ្នកទិញ។ បន្ទាប់ពីផ្គូផ្គងបញ្ជារួច តម្លៃនៃផលិតផលប្រែប្រួល (Fluctuate) រហូតទាល់តែវិនិយោគិនធ្វើការ Close Position ហើយទូទាត់ថាតើចំណេញឬ ខាត ទើបធ្វើការទូទាត់សាច់ប្រាក់ តាមរយៈភ្នាក់ងារទូទាត់សាច់ប្រាក់ (Cash Settlement Agent) ពាក់ព័ន្ធនឹងមូលបត្រ ដែលមានការទទួលស្គាល់ពី គ.ម.ក.។ ឈ្មួញជើងសាឧបករណ៍និស្សន្ទនៃភាគីអ្នកលក់ និងឈ្មួញជើងសារឧបករណ៍និស្សន្ទនៃភាគីអ្នកទិញត្រូវបង់ថ្លៃសេវាលើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទជូនគ.ម.ក តាមរយៈក្រុមហ៊ុនសមភាគីកណ្តាលដែលបានទទួលអាជ្ញាបណ្ណ\ការអនុញ្ញាតពី គ.ម.ក. ក្នុងអត្រា ០,៣ (សូន្យក្បៀសបី) ភាគរយ នៃទំហំសាច់ប្រាក់វិនិយោគដើមនៅរាល់ពេលមានការបើក និងបិទ

[៩] ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ

ស្ថានភាពជួញដូរនីមួយៗ។ សព្វថ្ងៃនៅប្រទេសកម្ពុជា មានក្រុមហ៊ុនសមភាគីកណ្តាលចំនួនបួន (ហ្គោលដេន អេហ្វអិកស៍លីង (ខេមបូឌា)/ ភ្នំពេញ ដេរីវ៉េទីវ អ៊ិចឆេង ភីអិលស៊ី/ រ៉ូយ៉ាល់ ហ្វាយនែនសល ខបភើរេសិន/ ហ្គោល ហ្វាយនែនសល គ្លូប៊ល អិនវេសម៉ិន) ដែលមានតួនាទីផ្គូរផ្គងបញ្ជា មានប្រភេទផលិតផលផ្សេងៗពីគ្នា ដែលត្រូវសុំការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជាលើប្រភេទផលិតផលមួយចំនួន។ ក្រុមហ៊ុនសមភាគីកណ្តាល សំដៅដល់ក្រុមហ៊ុនដែលជាដៃគូរផ្ទាល់ចំពោះរាល់កិច្ចសន្យាជួញដូរលើឧបករណ៍និស្សន្ទមួយ ឬច្រើន ពោលគឺក្លាយជាភាគីអ្នកទិញចំពោះរាល់អ្នកលក់និងក្លាយជាភាគីអ្នកលក់ចំពោះរាល់អ្នកទិញ។ CCP ក៏ដើរតួជាអ្នកលក់ផលិតផលតាមរយៈ Broker ដោយផ្តល់នូវតារាងផលិតផលដែលអាចជួញដូរដល់ Broker ។

# ជំពូកទី៤

# ឱកាសវិនិយោគ និងបញ្ហាប្រឈម

## ៤.១. ឱកាសវិនិយោគ

### ៤.១.១. ឱកាសវិនិយោគសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រ

វត្តមាននៃទីផ្សារមូលបត្រ ផ្តល់ឱកាសសម្រាប់ក្រុមហ៊ុនដែលមានបំណងបោះផ្សាយមូលបត្រជាសាធារណៈ នូវសក្តានុពលនៃការវិនិយោគរបស់ខ្លួន ក្នុងការពង្រីកអាជីវកម្ម និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឲ្យកាន់តែល្បីល្បាញ។

#### ៤.១.១.១. ហិរញ្ញប្បទានសម្រាប់ពង្រីកការវិនិយោគ

ការចុះបញ្ជីលក់មូលបត្រជាសាធារណៈ ផ្តល់លទ្ធភាពឲ្យក្រុមហ៊ុនបោះផ្សាយមូលបត្រទទួលបាននូវប្រភពហិរញ្ញប្បទានថ្មីមួយទៀត ដែលអនុញ្ញាតឲ្យក្រុមហ៊ុននេះ អាចប្រមូលបានមូលធនពីអ្នកវិនិយោគសាធារណៈសម្រាប់ពង្រីកការវិនិយោគ។ គោលបំណងរបស់ក្រុមហ៊ុនបោះផ្សាយ គឺការកៀរគរមូលធនដោយចំណាយតិច និងដើម្បីជៀសវៀងហានិភ័យទាំងឡាយដែលកើតចេញពីការផ្តល់ហិរញ្ញប្បទានដោយធនាគារ។ ក្រុមហ៊ុននឹងប្រមូលមូលធនពីវិនិយោគិនសាធារណៈ ដែលអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល។ ដូចនេះ ទើបគេហៅទីផ្សារមូលបត្រថាជាទីផ្សារមូលធនទំនេរ ដែលមានន័យថាមូលធនដែលផ្តល់ដោយវិនិយោគិនសាធារណៈដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមហ៊ុន។ ហេតុដូចនេះ សហគ្រាសជាច្រើនទាំងសហគ្រាសសាធារណៈ និងសហគ្រាសឯកជន ចង់បោះផ្សាយលក់មូលបត្រជាសាធារណៈក្នុងទៅផ្សារមូលបត្រ ដើម្បីទទួលបានហិរញ្ញប្បទាន។

- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ(រ.ទ.ស.ភ) ដែលជាក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈដំបូងបំផុតនៅប្រទេសកម្ពុជា និងប្រើប្រាស់ហិរញ្ញប្បទានដែលទទួលបានពីការបោះផ្សាយមូលបត្រកម្មសិទ្ធិរបស់ខ្លួន ទៅលើគម្រោងវិនិយោគដូចខាងក្រោម៖
    - គម្រោងសាងសង់រោងចក្រផលិតទឹកស្អាតនិរោធន៍ ដែលចែកជាពីរជំហាន។
    - គម្រោងពង្រីកបណ្តាញមេនាំទឹក និងបណ្តាញចែកចាយទឹកនៅទូទាំងរាជធានីភ្នំពេញ។
    - គម្រោងផ្តួចផ្តើមប្រើប្រាស់ថាមពលស្អាតក្នុងការផលិតអគ្គីសនីដោយប្រើពន្លឺព្រះអាទិត្យ

នៅឆ្នាំ២០១៤ រ.ទ.ស.ក. បានផលិតទឹកស្អាតចំនួន ១៥៩.៥៥២.០៩៤ ម៉ែត្រគូប ហើយគោរព តាមស្តង់ដារ របស់អង្គការសុខភាពពិភពលោក ហើយបានដាក់បណ្តាញចែកចាយ ទឹកទៅកាន់ អតិថិជនរបស់ខ្លួនចំនួន ១៨.៤៩៧ បណ្តាញ។ នៅចុងឆ្នាំ២០១៤ នេះរ.ទ.ស.ក មានបណ្តាញចែក ចាយសរុបចំនួន ២.៣១២ គីឡូម៉ែត្រសំរាប់ការផ្គត់ផ្គង់បណ្តាញចែកចាយបន្តចំនួន ២៧០.៨១២ នៅ រាជធានីភ្នំពេញ។

- ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី(ហ្គ្រេន ធ្វីន)

ក្រុមហ៊ុន ហ្គ្រេនធ្វីន គឺជារោងចក្រមៅការបន្ត និងជារោងចក្រ ផលិតសម្លៀកបំពាក់ផ្ទាល់ សម្រាប់នាំចេញ។ សព្វថ្ងៃផលិតផលរបស់ក្រុមហ៊ុន ហ្គ្រេនធ្វីនរួមមានម៉ាកសម្លៀកបំពាក់កីឡា ល្បីៗដូចជាម៉ាក Adidas, Reebok, Taylor Made, Salomon, New Balance (NB), Kohl's, Nautica, North Face, Russell Athletic។ល។ គោលដៅនាំចេញរបស់ក្រុមហ៊ុន ហ្គ្រេនធ្វីន មានដូចជា បណ្តា ប្រទេសក្នុងតំបន់អឺរ៉ុប(៦៣%នៃប្រាក់ចំណូលសរុបក្នុងឆ្នាំ២០១៥) សហរដ្ឋអាមេរិក(១៧%នៃប្រាក់ ចំណូល សរុបក្នុងឆ្នាំ២០១៥) តំបន់អាស៊ីនិងបណ្តាប្រទេសដទៃទៀត(២០%នៃប្រាក់ចំណូលសរុប ក្នុងឆ្នាំ២០១៥)។ ក្រុមហ៊ុន ហ្គ្រេនធ្វីន ទទួលបានការលើកលែងពន្ធពីប្រទេសកាណាដានិងសហ- ភាពអឺរ៉ុប។ បច្ចុប្បន្ននេះក្រុមហ៊ុន ហ្គ្រេនធ្វីន ស្ថិតនៅលើផ្ទៃដីទំហំ ៣២.៣៤១ ម៉ែត្រការ៉េ ក្នុងប្រទេស កម្ពុជា ជាមួយនឹងរោងចក្រទំហំ១១.៦៨២ម៉ែត្រការ៉េ។ ក្រុមហ៊ុន ហ្គ្រេនធ្វីន មានគម្រោងប្រើប្រាស់ ប្រាក់២៦.០០០លានរៀលដែលបានមកពីការលក់ភាគហ៊ុនដើម្បីពង្រីករោងចក្របន្ថែមជាពិសេសគឺ ដើម្បីបញ្ចប់ការសាងសង់ខ្សែសង្វាក់ផលិតកម្មថ្មីចំនួនពីរ។ ចំនូល៨០%របស់ក្រុមហ៊ុនគឺបានមកពី ក្រុមហ៊ុនAdidas។

- កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ)

ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ក.ស.ភ មិនត្រឹមតែបានបង្ហាញពីភាពរីកចម្រើនប៉ុណ្ណោះទេតែ ក៏បានបង្ហាញពីភាពរឹងមាំខ្លាំងក្នុងការប្រកបអាជីវកម្មរបស់ខ្លួនផងដែរ។ ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ ២០១៥ បរិមាណកុងតឺន័រ បានកើនឡើងទ្វេដងពី ៨១,៦៣១ TEUs ដល់ ១៤៥,៨១៣ TEUsដែល អត្រាកំណើនជាមធ្យមប្រចាំឆ្នាំ(CAGR)ស្មើនឹង១៥.៩១%។ ចំណូលសរុបរបស់ ក.ស.ភ កើន ឡើងទ្វេដង ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយគិតចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៤ ដែលអត្រាកំណើន ជាមធ្យមប្រចាំឆ្នាំ ២១,២០% ពី ៦,១៦លានដុល្លារអាមេរិក ដល់ ១៣,២៩លានដុល្លារអាមេរិក។

កំណើននេះ បានមកពីសេវាកម្មសំខាន់ៗដូចជា សេវាកម្មលើកដាក់ក្រោមដងយោង (Stevedore) សេវាកម្មលើកដាក់នៅលើទីលានកុងតឺន័រ (LOLO) និងសេវាកម្មផែដទៃទៀត ដូចជាសេវាកម្មចូលចតនាវា និងសេវាកម្មកណ្ណធារកិច្ច ដែលមានចំនួនប្រហែល ៩៣.៦៣%នៃចំណូលសរុបរបស់ ក.ស.ភក្នុងឆ្នាំ២០១៥។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ក.ស.ភ មានទ្រព្យសកម្មសរុបតម្លៃ ១៥៩.៥៨ លានដុល្លារអាមេរិក (៦៤៧,៩០៩.៤៤លានរៀល) និងមូលធនសរុបចំនួន១២៦.៤៦លានដុល្លារអាមេរិក(៥១៣,៤០៨.០៧លានរៀល)។ ដើម្បីឆ្លើយតបនឹងការរីកចម្រើនសេដ្ឋកិច្ចយ៉ាងលឿនរបស់ប្រទេសកម្ពុជា ក.ស.ភ ក៏មានផែនការពង្រីកសមត្ថភាពរបស់ខ្លួនក្នុងការផ្ដល់សេវាកម្មលើកដាក់ទំនិញ ការបំពាក់គ្រឿងចក្រលើកដាក់ទំនិញទូទៅ ការអភិវឌ្ឍន៍ចំណតផែសម្រាប់ទំនិញចាក់-ធារ ការធ្វើទំនើបកម្មចំណតផែអ្នកដំណើរ និងទេសចរណ៍។

- ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (ភីភីអេសភី)

ក្រោយការបង្កើតឡើងនៅឆ្នាំ ២០០៦ ក្រុមហ៊ុនបានទិញដីទំហំប្រមាណ ៣៥២.៤៦ហិចតា ក្នុងនោះដីទំហំ ១៣៧.៩៤ហិចតា ត្រូវបានប្រើប្រាស់ក្នុងការសាងសង់សំណង់ហេដ្ឋារចនាសម្ព័ន្ធធំៗ ក្នុងដំណាក់កាលទី១ ជាមួយនឹង ដីឡូត៍សំរាប់រោងចក្រ និងដីឡូតិ៍សំរាប់ពាណិជ្ជកម្មសរុបចំនួន ៧៨ កន្លែង។ ក្នុងឆ្នាំ ២០១០ ក្រុមហ៊ុនយើងទទួលបានវិញ្ញានបត្របញ្ជាក់បទដ្ឋានអន្តរជាតិ ISO:៩០០១ សម្រាប់ការប្ដេជ្ញាក្នុងការគ្រប់គ្រងប្រកបដោយគុណភាព និង ISO: ១៤០០១ សម្រាប់ការត្រួតពិនិត្យបរិស្ថាន។នាឆ្នាំ ២០១១ ក្នុងដំណាក់កាលទី២ ក្រុមហ៊ុនបានសាងសង់ទីតាំងសម្រាប់រោងចក្រ និង ហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត សម្រាប់ធានាដល់វិនិយោគិនថ្មី។ ក្នុងឆ្នាំ ២០១៤ ក្រុមហ៊ុនបានទិញដីទំនេរទំហំប្រមាណ ៥២.៩៥ ហិចតាបន្ថែមទៀតដែលមានទីតាំងនៅក្នុងខេត្តបន្ទាយ-មានជ័យ ដើម្បីប្រែក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេស។ PPSEZ មានវិនិយោគិនចម្រុះជាតិសាសន៍ចំនួន ៧៧ ដែលវិនិយោគិនភាគច្រើនមកពីប្រទេសជប៉ុន ម៉ាឡេស៊ី តៃវ៉ាន់ ចិន សហរដ្ឋអាមេរិក និងកូរ៉េ ដែលវិនិយោគលើឧស្សាហកម្មផ្សេងៗគ្នា ដូចជា គ្រឿងបន្លាស់យានយន្ត កាត់ដេរ អាហារ និងភេសជ្ជៈ ជាដើម។ ដើម្បីបន្តជាតំបន់សេដ្ឋកិច្ចពិសេសដែលឈានមុខគេនៅកម្ពុជា ក្រុមហ៊ុនបានរៀបចំផែនការអនាគតដូចខាងក្រោម៖

- បន្តទិញដីនៅតំបន់ជុំវិញ PPSEZ។

- បន្តការធ្វើឱ្យមានភាពចម្រុះគ្នានៃវិនិយោគិនក្នុងតំបន់ ដោយផ្តោតសំខាន់លើវិនិយោគិនដែលអនុវត្តដំណើរការផលិតមានលក្ខណៈពេញលេញ និងផ្នែកផ្សេងៗទៀតនៃខ្សែសង្វាក់តម្លៃនៃសកម្មភាពផលិត និងដំឡើង។
- ពង្រីកខ្លួនទៅកាន់ផ្នែកដទៃទៀតនៃកម្ពុជា និងបណ្តារប្រទេសក្នុងតំបន់មេគង្គ។
- ពង្រីកការផ្តល់សេវាកម្មដែលពាក់ព័ន្ធ ពិសេសសមត្ថភាពក្នុងការផ្គត់ផ្គង់ទឹកនៅក្នុង PPSEZ។

• កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស.)

ក.ស.ស ស្ថិតនៅឈូងសមុទ្រថៃ ដែលជាទីតាំងយុទ្ធសាស្ត្រងាយស្រួលដឹកជញ្ជូនទៅទីផ្សារក្នុងតំបន់អាស៊ាន និងតំបន់អាស៊ីប៉ាស៊ីហ្វិចដោយពុំចាំបាច់ឆ្លងកាត់កំពង់ផែក្នុងតំបន់។ គិតត្រឹម ៦ខែដំបូងឆ្នាំ ២០១៦ ក.ស.ស. រកចំណូលបាន ១០២,០៦ ពាន់លានរៀល។

- រវាងឆ្នាំ ២០១០ និង ២០១៤ បរិមាណកុងតឺន័រដែលឆ្លងកាត់ ក.ស.ស មានការកើនឡើងជាលំដាប់ក្នុងអត្រាកំណើន ៩,៣៦%ប្រចាំឆ្នាំ ពី ២២២.៩២៨ TEUs ទៅ ៣៣៣.៩០៤ TEUs។
- ក្នុងឆ្នាំ ២០១៥ បរិមាណទំនិញឆ្លងកាត់ ក.ស.ស មានចំនួន ៣៩១.៨១៩ ពោលគឺឡើង ១៧,៣៤%ធៀបនឹងឆ្នាំ ២០១៤។ សម្រាប់ ៦ខែដំបូងឆ្នាំ ២០១៦ បរិមាណទំនិញឆ្លងកាត់មានចំនួន ១៩៦.០២៦ TEUs។
- ក្នុងឆ្នាំ ២០១៥ ក.ស.ស បានស្រូបយកប្រមាណ ៧៣,០១% នៃចំនួនកុងតឺន័រ ដែលឆ្លងកាត់កំពង់ផែនៃប្រទេសកម្ពុជា ដែលធ្វើឱ្យ ក.ស.ស. ក្លាយជាកំពង់ផែដែលមមាញឹកជាងគេរបស់កម្ពុជា។

**៤.១.១.២. កេរ្តិ៍ឈ្មោះ**

កេរ្តិ៍ឈ្មោះនៃក្រុមហ៊ុន ពិតជាសំខាន់ក្នុងការធ្វើអាជីវកម្ម។ ការបោះផ្សាយលក់មូលបត្រជាសាធារណៈ គឺជាមធ្យោបាយមួយសម្រាប់បង្កើននូវកិត្តិនាមរបស់ក្រុមហ៊ុនទាំងក្នុងប្រទេស និងក្រៅប្រទេស។ កេរ្តិ៍ឈ្មោះនៃក្រុមហ៊ុន អាចពង្រឹងនូវទំនុកចិត្តរបស់អតិថិជន និងអនុញ្ញាតឲ្យក្រុមហ៊ុនទទួលបាននូវសហប្រតិបត្តិការល្អជាមួយដៃគូរពាណិជ្ជកម្មកាន់តែប្រសើរ។ ការបោះផ្សាយមូលបត្រក៏ជាមធ្យោបាយមួយផងដែរ ក្នុងការផ្សព្វផ្សាយអំពីក្រុមហ៊ុន គុណភាពរបស់ផលិតផល ឬសេវាកម្ម

របស់ក្រុមហ៊ុនទៅសាធារណៈជន និងផ្សព្វផ្សាយពីប្រសិទ្ធភាពរបស់ក្រុមហ៊ុន ពីព្រោះថាក្រុមហ៊ុនគោរពនូវលក្ខខណ្ឌទាំងឡាយសម្រាប់បោះផ្សាយលក់មូលបត្រជាសាធារណៈ។ ការស្រាវជ្រាវទៅលើក្រុមហ៊ុនអាមេរិចជាច្រើនបង្ហាញថា ការចុះឈ្មោះបោះផ្សាយមូលបត្រលើទីផ្សារមូលបត្រ បានបង្កើនចំនួនចំនួនចូលទស្សនាគេហទំព័ររបស់ក្រុមហ៊ុន នេះបង្ហាញថាសាធារណជនមានការចាប់អារម្មណ៍ជាខ្លាំងលើក្រុមហ៊ុនបោះផ្សាយមូលបត្រ។ លើពីនេះទៅទៀត កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនកាន់តែល្បីល្បាញប្រសិនបើបណ្តាញសារពត៌មានឯកទេសផ្នែកហិរញ្ញវត្ថុ ផ្តោតការយកចិត្តទុកដាក់ចំពោះក្រុមហ៊ុន។ ការចុះបញ្ជីលក់មូលបត្រ បង្កើតការបរិយាយអំពីក្រុមហ៊ុន នៅតាមបណ្តាញសារពត៌មានឯកទេសជាច្រើន។ ការចុះបញ្ជីលក់មូលបត្រ គឺផ្សព្វផ្សាយជាសាធារណៈអំពីក្រុមហ៊ុនដូចជាមធ្យោបាយក្នុងការផ្សព្វផ្សាយផ្សេងៗទៀតផងដែរ។

**៤.១.១.៣. លទ្ធភាពទទួលបានឥណទានពីធនាគារ**

ក្រុមហ៊ុនដែលបានចុះបញ្ជីបោះផ្សាយមូលបត្រ មានកេរ្តិ៍ឈ្មោះល្អ ហើយទទួលបានការគាំទ្រពីច្បាប់ ដូចនេះក្រុមហ៊ុនអាចពង្រឹងនូវអំណាចក្នុងការចរចាជាមួយធនាគារពីលទ្ធភាពក្នុងការទទួលបានឥណទាន។ ប្រតិបត្តិការឥណទាន ជាប្រតិបត្តិការមានហានិភ័យ។ ហានិភ័យសំខាន់ៗមានពីរប្រភេទ គឺការមិនសងប្រាក់ពីអ្នកខ្ចី និងកង្វះសាច់ប្រាក់របស់ធនាគារ។ ដើម្បីគ្រប់គ្រងលើហានិភ័យនេះ ធនាគារត្រូវវិភាគឲ្យបានច្បាស់លាស់ អំពីស្ថានភាពរបស់ក្រុមហ៊ុនដែលធ្វើការស្នើរសុំឥណទានពីធនាគារ។ ការវិភាគហានិភ័យនេះ អាចធ្វើឡើងដោយជោគជ័យដរាបណា ធនាគារទទួលបានពត៌មានគ្រប់គ្រាន់ពីក្រុមហ៊ុនស្នើសុំ។ ការស្វែងរកពត៌មានអាចចំណាយពេលវេលា និងថវិការច្រើន។ រាល់ការចំណាយទាំងនេះជាបន្ទុករបស់អ្នកខ្ចី ព្រោះបើចំណាយពេលនិងថវិការកាន់តែច្រើន អត្រាការប្រាក់ដែលកំណត់ដោយធនាគារកាន់តែខ្ពស់។ ប៉ុន្តែនៅពេលក្រុមហ៊ុនមួយចុះបញ្ជីបោះផ្សាយមូលបត្រជាសាធារណៈ ក្រុមហ៊ុនត្រូវផ្សព្វផ្សាយពត៌មានរបស់ខ្លួន តាមរយៈឯកសារផ្តល់ពត៌មានដែលបានអនុញ្ញាតឲ្យផ្សព្វ ផ្សាយជាសាធារណៈដោយគណៈកម្មការមូលបត្រកម្ពុជា។ លើសពីនេះក្រុមហ៊ុនត្រូវបោះផ្សាយរាល់ពត៌មានដែលកើតក្រោយពីការបោះផ្សាយមូលបត្រដែលអាចមានឥទ្ធិពលដល់តម្លៃមូលបត្រ។ ក្នុងករណីនេះ ធនាគារអាចទទួលបាននូវពត៌មានរបស់ក្រុមហ៊ុនបោះផ្សាយយ៉ាងងាយស្រួល ដូចនេះចំណាយក្នុងការស្វែងរកពត៌មានត្រូវបានកាត់បន្ថយនាំឲ្យអត្រាការប្រាក់នៃកម្ចីក៏បានកាត់បន្ថយដែរ។ លើសពីនេះទៀតពត៌មានទាំងនេះ អាចទទួល

បានដោយធនាគារផ្សេងៗទៀត។ ក្នុងករណីនេះក្រុមហ៊ុនមានលទ្ធភាពច្រើនក្នុងការចរចាជាមួយធនាគារ ។ ការប្រកួតប្រជែងរបស់ធនាគារដែលមានបំណងចង់ផ្តល់ឥណទានឲ្យក្រុមហ៊ុននឹងធ្វើឲ្យអត្រាការប្រាក់កម្ចីថយចុះ។

#### ៤.១.១.៤. ផលចំណេញផ្នែកពន្ធដារ

ដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា រាជរដ្ឋាភិបាលមានការលើកទឹកចិត្តផ្នែកពន្ធដារចំពោះក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ ដែលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។ រដ្ឋាភិបាលមានគោលនយោបាយ ជំរុញឲ្យមានការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយមានការលើកទឹកចិត្តផ្នែកពន្ធលើប្រាក់ចំណេញ ហើយជាពិសេសក្នុងដំណាក់កាលដំបូងនៃការបើកដំណើរការទីផ្សារមូលបត្រ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ទទួលបាននូវការលើកទឹកចិត្តផ្នែកពន្ធ ដោយបន្ថយពន្ធលើប្រាក់ចំណេញ ១០(ដប់) ភាគរយ នៃពន្ធលើប្រាក់ចំណេញត្រូវបង់ក្នុងរយៈពេល ៣(បី) ឆ្នាំ។ ដើម្បីទទួលបាននូវការលើកទឹកចិត្តនេះក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវបំពេញបែបបទជូនអគ្គនាយកដ្ឋានពន្ធដារ តាមរយៈគណៈកម្មការមូលបត្រកម្ពុជា[10]។

### ៤.១.២. ឱកាសវិនិយោគសម្រាប់វិនិយោគិនសាធារណៈ

មុនពេល និងក្រោយពេលមានទីផ្សារមូលបត្រនៅកម្ពុជា មានមតិមួយបានលើកឡើងថាការជួញដូរមូលបត្រប្រៀបដូចជាការលេងល្បែងស៊ីសង ចំណែកឯមតិមួយទៀតក៏បានលើកឡើងដែលថា ការជួញដូរមូលបត្រគឺជាការវិនិយោគ។ ជាការពិតបើគេគិតវិភាគឲ្យបានច្បាស់លាស់ទៅការលេងល្បែង និងការវិនិយោគ គឺខុសគ្នាទាំងស្រុង។ ការលេងល្បែង គឺពឹងផ្អែកទៅលើព្រេងសំណាងគ្មានអ្វីអាចយកមកបញ្ជាក់ថាឈ្នះ ឬអាចមើលឃើញថាឈ្នះនោះទេ។ ឧទាហរណ៍ដូចជាការលេងឆ្នោត នៅពេលដែលគេលេងឆ្នោត២ខ្ទង់ គេបានជ្រើសរើសយកមួយលេខក្នុងចំណោមមួយរយលេខ ដូចនេះឱកាសឈ្នះគឺ មួយក្នុងចំណោយមួយរយ ហើយបើគេលេងឆ្នោត៣ខ្ទង់ ៤ខ្ទង់ ៥ខ្ទង់ ៦ខ្ទង់ នោះឱកាសឈ្នះរបស់គេគឺកាន់តែតិចទៅៗគឺ មួយក្នុងចំណោមមួយពាន់ មួយម៉ឺន មួយសែន មួយលានសំណាង។ ដូចនេះការលេងល្បែងមិនអាចមានសង្ឃឹមឈ្នះក្នុងភាគរយដ៏ច្រើន

[10] អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

នោះទេ ហើយការលេងល្បែងតែងតែវិនាស។ ចំណែកឯការវិនិយោគលើវិស័យមូលបត្រវិញ គឺអាស្រ័យទៅលើការរកស៊ីរបស់ក្រុមហ៊ុននៅពេលក្រុមហ៊ុនបានចំណេញច្រើន ធ្វើឲ្យគេទទួលបានភាគលាភច្រើន ហើយក្រុមហ៊ុនណាក៏ចង់បានចំណេញ និងចង់ឲ្យក្រុមហ៊ុនគេមានការរីកចម្រើនផងដែរ។ ហើយនៅមុនពេលជ្រើសរើសទិញមូលបត្ររបស់ក្រុមហ៊ុនណាមួយគឺ គេបានមើលពីស្ថានភាពហិរញ្ញវត្ថុ សកម្មភាពរបស់ក្រុមហ៊ុន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហើយរបាយការណ៍នេះបង្ហាញពីបំណុល មូលធន ទ្រព្យសកម្ម ចំណូល ចំណាយ ចំណេញ ខាត ពត៌មានទាំងនេះគឺត្រូវបានត្រួតពិនិត្យនិងអនុញ្ញាតឲ្យផ្សព្វផ្សាយដោយ គ.ម.ក.។ ពេលខ្លះបើគេបានសំរេចចិត្តទិញមូលបត្ររបស់ក្រុមហ៊ុនណាមួយខុស គេមានសិទ្ធិលក់មូលបត្រនោះវិញ បើគេលក់បានលឿនគេខាតតិចតួចតែប៉ុណ្ណោះ តែបើការលេងល្បែងបើសិនគេភ្នាល់ខុសនោះគឺគេនឹងបាត់បង់ប្រាក់ទាំងអស់។ ដូចនេះការលេងល្បែង គឺមិនអាចធ្វើឲ្យស្ថានភាពហិរញ្ញវត្ថុរបស់គេមានភាពរីកចម្រើនបានទេប៉ុន្តែបើគេវិនិយោគលើទីផ្សារមូលបត្រ គឺជាប្រភពផ្តល់ប្រាក់ចំណូលច្បាស់លាស់ ហើយសម្រាប់វិនិយោគិនណាដែលយល់ច្បាស់ ពីការរកស៊ីរបស់ក្រុមហ៊ុនអំពីនីតិវិធីនៃការជួញដូរ គាត់នឹងមានឱកាសក្លាយជាអ្នកជាមិនខាន។

វត្តមាននៃទីផ្សារមូលបត្រ ផ្តល់ឱកាសសម្រាប់វិនិយោគិនសាធារណៈ នូវជម្រើសថ្មីមួយទៀតក្នុងការវិនិយោគ។ ទីផ្សារមូលបត្រ គឺជាទីផ្សារដែលមានហានិភ័យ តែផលចំណេញក៏ក្រាស់ក្រែលផងដែរ។ នេះជាឱកាសល្អ សម្រាប់អ្នកដែលមានមូលធននៅទំនេរ ហើយមានបំណងវិនិ-យោគលើទីផ្សារមូលបត្រ ដើម្បីទទួលបានប្រាក់ចំណេញ។ ការវិនិយោគលើមូលបត្រទទួលបានផលប្រយោជន៍ដូចខាងក្រោម៖

### ៤.១.២.១. ផលចំណេញ

នៅពេលដែលក្រុមហ៊ុនបោះផ្សាយ ទទួលបានជោគជ័យក្នុងការវិនិយោគ ម្ចាស់កាន់មូលបត្រកម្មសិទ្ធិនឹងទទួលបាននូវចំណែកភាគលាភ ទៅតាមសមាមាត្រនៃសិទ្ធិដែលខ្លួនមាននៅក្នុងក្រុមហ៊ុន។ ចំណែកឯវិនិយោគិនដែលកាន់កាប់មូលបត្របំណុល នឹងទទួលបានការប្រាក់ថេរ ទោះបីជាក្រុមហ៊ុនបោះផ្សាយទទួលបានផលចំណេញ ឬខាតបង់ក៏ដោយ។ ការវិនិយោគលើមូលបត្របំណុល ជាទូទៅទទួលបានប្រាក់ចំណេញតិចជាងការវិនិយោគលើមូលបត្រកម្មសិទ្ធិ ប៉ុន្តែការ

ប្រឈមមុខនឹងហានិភ័យក៏មានកម្រិតតិចជាងការវិនិយោគលើមូលបត្រកម្មសិទ្ធិដែរ។ ជាទូទៅ វិនិយោគិនទទួលបាននូវប្រាក់ចំណេញតាមរយៈភាគលាភ ឬការប្រាក់ ដែលខ្ពស់ជាងអត្រាការប្រាក់បញ្ញើនៅធនាគារ។ នេះជាមូលហេតុមួយ ជំរុញឲ្យវិនិយោគិនសាធារណៈ ហ៊ានវិនិយោគលើមូលបត្រ។ ដើម្បីទទួលបាននូវទំនុកចិត្តពីវិនិយោគិនសាធារណៈ ច្បាប់បានកំណត់នូវបទប្បញ្ញត្តិដ៏តឹងរឹង ដើម្បីធានាបាននូវពត៌មានសម្រាប់វិនិយោគិនសាធារណៈទាំងអស់ស្មើៗគ្នា។ ក្រុមហ៊ុនមានកាតព្វ កិច្ចផ្សព្វផ្សាយនូវពត៌មានទាំងឡាយដែលអាចជះឥទ្ធិពលទៅលើតម្លៃនៃមូលបត្រ។

### ៤.១.២.២. ផលចំណេញមូលធន

វិនិយោគិន នឹងទទួលបានផលចំណេញផ្នែកមូលធន នៅពេលដែលតម្លៃមូលបត្ររបស់ខ្លួនឡើងថ្លៃក្នុងទីផ្សារមូលបត្រ។ ផលចំណេញមូលធន ជាភាពខុសគ្នារវាងតម្លៃទិញ ពោលគឺតម្លៃលក់ខ្ពស់ជាងតម្លៃទិញ ដែលភាពលើសហិរញ្ញវត្ថុនេះត្រូវវិនិយោគិនទទួលបាន។ វិនិយោគិន តែងចង់បានផលចំណេញពីការជួញដូរមូលបត្រនៅលើទីផ្សារ ដោយលក់មូលបត្រទៅវិញក្នុងតម្លៃខ្ពស់ជាងតម្លៃដែលបានទិញ។ វិនិយោគិនសាធារណៈសង្ឃឹមថា នៅពេលសំណើទិញមានការកើនឡើង នោះតម្លៃមូលបត្រក៏កើនឡើងដែរ។ ផ្អែកទៅលើការវិវត្តន៍របស់ទីផ្សារមូលបត្រលើពិភពលោក នាពេលបច្ចុប្បន្នការស្វែងរកប្រាក់ចំណេញពីការជួញដូរមូលបត្រនៅលើទីផ្សារ គឺជាមូលហេតុចម្បងដែលទាក់ទាញការវិនិយោគលើទីផ្សារមូលបត្រ។ សេដ្ឋកិច្ចរបស់បុគ្គលម្នាក់អាចត្រូវបានផ្លាស់ប្តូរទាំងស្រុង ប្រសិនបើការជួញដូរទទួលបានជោគជ័យ។ តែទោះជាយ៉ាងណាក៏ដោយ ទីផ្សារមូលបត្រគឺជាទីផ្សារមានហានិភ័យនិងមានភាពមិនទៀងទាត់។ ដូចនេះក្នុងការសម្រេចចិត្តក្នុងការវិនិយោគលើមូលបត្រ ត្រូវទាមទារការពិចារណាឲ្យបានច្បាស់លាស់ ដោយផ្អែកចម្បងទៅលើពត៌មានដែលទាក់ទងនឹងក្រុមហ៊ុនបោះផ្សាយនិងកត្តាជះឥទ្ធិពលផ្សេងៗទៀត។

### ៤.១.២.៣. ផលចំណេញផ្នែកពន្ធដារ

ដើម្បីទាក់ទាញការវិនិយោគលើមូលបត្រ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះវិនិយោគិនសាធារណៈ ជាពិសេសក្នុងដំណាក់កាលដំបូងនៃការបើកដំណើរការមូលបត្រ។ នេះជាឱកាសដ៏ល្អមួយសម្រាប់វិនិយោគិនសាធារណៈ ទទួលបាននូវការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយ លើការប្រាក់និង/ឬភាគលាភ ដែលបានមកពីការកាន់កាប់ និង/ឬការទិញ-

លក់ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលសម្រាប់រយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីមានដំណើរការទីផ្សារមូលបត្រ[11]។

### ៤.១.៣. ទីផ្សារមូលបត្រជំរុញវិស័យសេដ្ឋកិច្ច

ទីផ្សារមូលកម្ពុជា គឺជាកត្តាសំខាន់សម្រាប់សេដ្ឋកិច្ចជាតិគេតែងតែនិយាយថាទីផ្សារមូល-បត្រគឺជានិមិត្តរូបនៃសេដ្ឋកិច្ចទាំងមូល។ ជាការពិតណាស់ដោយគ្រាន់តែមើលទៅសន្ទស្សន៍ហ៊ុនគេនឹងឃើញពីឥទ្ធិពលរបស់ទីផ្សារមូលបត្រលើសេដ្ឋកិច្ចយ៉ាងណា ពីព្រោះសន្ទស្សន៍ហ៊ុនរបស់ផ្សារមូលបត្រ វាបានឆ្លុះបញ្ជាំងពីស្ថានភាពសេដ្ឋកិច្ចជាតិ។ ហេតុនេះហើយ ស្ទើរតែគ្រប់ប្រទេសដែលជឿនលឿន មានទីផ្សារមូលបត្រនេះហើយវាបានដើរតួនាទីយ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចជាតិ។

ទីផ្សារមូលបត្រ ជាមធ្យោបាយមួយដើម្បីកៀរគរនូវប្រភពមូលធនដែលនៅទំនេរតូចៗមិនទាន់មានតម្រូវការប្រើប្រាស់ ពូនផ្តុំជាមូលធនធំមួយដើម្បីវិនិយោគក្នុងវិស័យផលិតកម្ម ហើយទីផ្សារនេះនឹងផ្តល់នូវជម្រើសមួយទៀតដល់ធុរជន ដើម្បីរកហិរញ្ញប្បទានក្រៅពីកម្ចីធនាគារ។ ហើយទីផ្សារមូលបត្រជួយជំរុញឲ្យមហាជនបង្កើននូវការសន្សំ និងកៀរគរមូលធនដែលនៅសេសសល់ មិនមានតម្រូវការប្រើប្រាស់យកទៅវិនិយោគក្នុងសេដ្ឋកិច្ច ហើយការកៀរគរប្រភពហិរញ្ញវត្ថុនេះអាចបានមកពីគ្រប់ផ្នែកពីទីជិតទីឆ្ងាយ ទាំងទំហំតូចនិងធំ រយៈពេលវែង មធ្យម និងរយៈពេលខ្លី ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងថ្មីៗ និងជាឧបករណ៍មួយជួយសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តន៍នូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជាតិ។ ការករកើតនៃទីផ្សារមូលបត្រកម្ពុជាអាចធ្វើឲ្យមានការទាក់ទាញវិនិយោគិនមកកាន់ប្រទេសកម្ពុជា ពីព្រោះថាក្រុមហ៊ុនបរទេសធំៗដែលមានបំណងមកវិនិយោគនៅកម្ពុជា គេអាចបោះផ្សាយលក់មូលបត្រនៅទីផ្សារនៅទីផ្សារមូលបត្រកម្ពុជាហើយវិនិយោគិននៅកម្ពុជាតែម្តង។ ម្យ៉ាងទៀតនៅពេលមានទីផ្សារនេះអាចជួយជំរុញឲ្យក្រុមហ៊ុនត្រូវប្រកាន់ភ្ជាប់នូវអភិបាលកិច្ចល្អ តម្លាភាពដោយផ្តល់នូវទំនុកចិត្តដល់សាធារណជន ដែលករណីនេះបង្កើតមានបរិយាកាសប្រកួតប្រជែងរវាងក្រុមហ៊ុនដែលមានអភិបាលកិច្ចល្អ មានតម្លាភាព និងក្រុមហ៊ុនដែលមិនមានអភិបាលកិច្ចល្អ និងគ្មានតម្លាភាព។ ដូចនេះទីផ្សារមូលបត្រ មានសារៈ

[11] អនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ

សំខាន់សម្រាប់ជួយជំរុញឲ្យប្រភពមូលធនក្នុងស្រុកមានចលនារស់រវើក និងជាការពង្រីកនូវប្រភពហិរញ្ញវត្ថុផ្សេងៗសម្រាប់កំណើនសេដ្ឋកិច្ចដ៏រឹងមាំរបស់ប្រទេសកម្ពុជា។

### ៤.១.៤. យុទ្ធសាស្ត្រទាក់ទាញការវិនិយោគក្នុងវិស័យមូលបត្រ

ទីផ្សារមូលបត្រកម្ពុជា គឺជាទីផ្សារដ៏ថ្មីស្រឡាងសម្រាប់សាធារណជននៅកម្ពុជា ដូចនេះ ទីផ្សារនេះពុំទាន់ផ្តល់នូវទំនុកចិត្តដល់វិនិយោគិនមូលបត្រទេ។ ដើម្បីពង្រឹង និងអភិវឌ្ឍទីផ្សារមូល-បត្រនេះរាជរដ្ឋាភិបាលកម្ពុជា ប្រើប្រាស់នូវយុទ្ធសាស្ត្រផ្សេងៗសម្រាប់ កសាងទំនុកចិត្តពីវិនិយោ-គិន និងទាក់ទាញការវិនិយោគលើវិស័យមូលបត្រ។

#### ៤.១.៤.១. ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

ដើម្បីទាក់ទាញការវិនិយោគ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ ដល់ការវិនិយោគលើវិស័យមូលបត្រ។ ការលើកទឹកចិត្តនេះ គឺសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា និងវិនិយោគិនមូលបត្រសាធារណៈ[12] ។

#### ក. ពន្ធលើប្រាក់ចំណេញចំពោះក្រុមហ៊ុនបោះផ្សាយមូលបត្រ

ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ទទួលបាននូវការលើកទឹកចិត្តផ្នែកពន្ធដោយបន្ថយពន្ធលើប្រាក់ចំណេញ ១០(ដប់) ភាគរយ នៃពន្ធលើប្រាក់ចំណេញត្រូវបង់ក្នុងរយៈពេល ៣ (បី) ឆ្នាំ។ ដើម្បីទទួលបាននូវការលើកទឹកចិត្តនេះ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវបំពេញបែងបទជូនអគ្គនាយកដ្ឋានពន្ធដារ តាមរយៈគណៈកម្មការមូលបត្រកម្ពុជា។

រយៈពេលនៃការលើកទឹកចិត្ត ៣ (បី) ឆ្នាំខាងលើនេះត្រូវគិតចាប់ផ្តើមពី៖

- ដើមឆ្នាំជាប់ពន្ធ ដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុង ករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ដើម ឆ្នាំជាប់ពន្ធ

[12] អនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ

- ដើមឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែល មូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែចុងឆ្នាំជាប់ពន្ធ

### ខ. ពន្ធកាត់ទុកចំពោះវិនិយោគិនមូលបត្រ

រាជរដ្ឋាភិបាលក៏បានធ្វើការលើកទឹកចិត្តដល់វិនិយោគិនមូលបត្រ ដោយទទួលបាននូវការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយ លើការប្រាក់ និង/ឬភាគលាភ ដែលបានមកពីការកាន់កាប់ និង/ឬការទិញ-លក់ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលសម្រាប់រយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីមានដំណើរការទីផ្សារមូលបត្រ។

បុគ្គលជាភ្នាក់ងារកាត់ទុកដែលធ្វើការបើកការប្រាក់ និង/ឬភាគលាភ ត្រូវធ្វើការគណនាប្រាក់ពន្ធកាត់ទុក មុនការបើកប្រាក់និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធកាត់ទុក ជូនរដ្ឋបាលសារពើពន្ធ ទៅតាមតម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ (ដប់ប្រាំ) នៃខែបន្ទាប់ពីខែដែលធ្វើការកាត់ទុក។

### ៤.១.៤.២. ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ

ទីផ្សារមូលបត្រកម្ពុជា នឹងមិនអាចឈានទៅមុខបានទេប្រសិនបើគ្មានការចូលរួមពីសំណាក់សាធារណជន។ ការអភិវឌ្ឍរបស់ទីផ្សារមូលបត្រកម្ពុជា អាស្រ័យដោយមានការគាំទ្រនិងទំនុកចិត្តដ៏រឹងមាំពីសាធារណជនគ្រប់ស្រទាប់វណ្ណៈជាពិសេសវិនិយោគិនសាធារណៈ។ ដូចជារដ្ឋាភិបាលកម្ពុជាក៏ដូចជាគណៈកម្មការមូលបត្រកម្ពុជា ខិតខំយកចិត្តទុកដាក់ក្នុងការរៀបចំនូវការបណ្តុះបណ្តាលនានា និងធ្វើការផ្សព្វផ្សាយឲ្យបានកាន់តែទូលំទូលាយទៅដល់សាធារណជន អំពីវិស័យមូលបត្រ សារៈប្រយោជន៍ និងសារៈសំខាន់របស់ទីផ្សារមូលបត្រ និងជាពិសេស កាលានុវត្តភាពនៃការវិនិយោគនៅក្នុងទីផ្សារមូលធននេះ។ ទន្ទឹមនឹងនេះផងដែរ ការបណ្តុះបណ្តាលមន្ត្រីជំនាញរបស់ គ.ម.ក. ក៏ជាការងារអាទិភាពមួយយ៉ាងសំខាន់ផងដែរ ក្នុងគោលបំណងកសាងធនធានមនុស្ស ដើម្បីអាចទ្រទ្រង់ក៏ដូចជា គ្រប់គ្រងទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធភាពខ្ពស់ និងជាពិសេសធានាបាននូវកិច្ចការពារដ៏ប្រសើរសម្រាប់អ្នកវិនិយោគសាធារណៈ។

គ.ម.ក. បានរៀបចំ នូវសិក្ខាសាលាថ្នាក់ជាតិជាច្រើន ស្តីពីវិស័យមូលបត្រដែលបើកទូលាយដល់សាធារណជនទូទៅ។ សិក្ខាសាលាទាំងនេះ មានទិសដៅផ្តល់នូវចំណេះដឹងបន្ថែមសម្រាប់មន្ត្រីរបស់ខ្លួនផ្ទាល់ និងផ្តល់នូវការបណ្តុះបណ្តាលដល់អ្នកចូលរួមដទៃទៀត ពាក់ព័ន្ធនឹងវិស័យមូលបត្រថ្មីនេះ។ សិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយ គ.ម.ក. មានអ្នកចូលរួមពីសាធារណជនជាច្រើន មានជាអាទ៍ប្រធាន ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនពាណិជ្ជកម្ម វិនិយោគិនជាតិ និងបរទេស មន្ត្រីរាជការ សាស្ត្រាចារ្យ សិស្សនិស្សិតដែលភាគច្រើនធ្វើការស្វែងយល់អំពីវិស័យមូលបត្រថ្មីនេះ និងមានបំណងធ្វើការវិនិយោគ ឬប្រកបអាជីវកម្មក្នុងវិស័យមូលបត្រ។

ដោយស្របទៅតាមភាពរីកចម្រើននៃបច្ចេកវិទ្យា គណៈកម្មការមូលបត្រកម្ពុជា បានធ្វើការផ្សព្វផ្សាយនូវច្បាប់ និងបទប្បញ្ញត្តិ និងពត៌មាននានាពាក់ព័ន្ធនឹងវិស័យមូលបត្រ តាមរយៈគេហទំព័ររបស់ គ.ម.ក. (www.secc.gov.kh) សារពត៌មាន វិទ្យុ និងទូរទស្សន៍ជាតិ និង អន្តរជាតិទាំងភាសាខ្មែរ និង ភាសាអង់គ្លេស។ ចំណែកឯក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក៏បានផ្សព្វផ្សាយនូវពត៌មានដែលទាក់ទងនឹងមូលបត្រដូចជា តម្លៃមូលបត្រ ទំហំនៃការជួញដូរ និងដំណើរការទិញ-លក់មូលបត្រជាដើម តាមរយៈគេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រ (www.csx.com.kh) ។

ការផ្សព្វផ្សាយ នឹងធ្វើឲ្យសាធារណជនយល់ដឹងពីហានិភ័យដែលអាចកើតមាននៅក្នុងវិស័យមូលបត្រ ដូចជាហានិភ័យអត្រាប្តូរប្រាក់ ហានិភ័យទីផ្សារ ហានិភ័យកត្តាសេដ្ឋកិច្ច និងហានិភ័យជាប្រព័ន្ធដទៃទៀត។ល។ ជាងនេះទៅទៀត ការផ្សព្វផ្សាយនឹងជួយបង្ការ និងបញ្ចៀសឬកាត់បន្ថយនូវហានិភ័យខាងលើ ក៏ដូចជាកាត់បន្ថយនូវការខាតបង់នានាដែល អាចកើតមានឡើងជាយថាហេតុ ឬដោយការគៃបន្លំ និងបោកបញ្ឆោតក្នុងទីផ្សារមូលបត្រ។

### ៤.១.៤.៣. ទំនាក់ទំនងអន្តរជាតិ

នៅក្នុងសម័យសកលភាវូបនីយកម្មនេះ ទំនាក់ទំនងអន្តរជាតិ និងកិច្ចសហប្រតិបត្តិការ គឺជាមាគ៌ាមួយនាំឆ្ពោះទៅរកការបង្កើននូវទំនាក់ទំនងយ៉ាងទូលំទូលាយ និងចែករំលែកនូវបទពិសោធន៍ល្អៗ ក៏ដូចជាជួយកែលម្អនូវចំណុចខ្វះខាតគ្នាទៅវិញទៅមក ព្រមទាំងជាចលករមួយដែលជួយជំរុញដល់សន្ទុះការងារឲ្យមានល្បឿនលឿន និងប្រកបដោយប្រសិទ្ធភាព និងសមស្របតាមបរិបទនៃការអភិវឌ្ឍក្នុងវិស័យមូលបត្រ។ អាស្រ័យដោយសម្លឹងឃើញពីភាពចាំបាច់នៃកិច្ចសហប្រតិបត្តិ-

ការ និងទំនាក់ទំនងអន្តរជាតិបែបនេះហើយរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាគណៈកម្មការមូលបត្រកម្ពុជា ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើកិច្ចការនេះ ដោយខិតខំពង្រឹងនូវកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងអន្តរជាតិជាមួយស្ថាប័នអន្តរជាតិពាក់ព័ន្ធ។

កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងល្អជាមួយស្ថាប័នខាងក្រៅ បានរួមចំណែកផងដែរក្នុងការធ្វើឲ្យមានប្រសិទ្ធភាពដល់ការតាក់តែងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ ព្រោះថារាល់ការរៀបចំនូវបទប្បញ្ញត្តិនានា ត្រូវបានទទួលធាតុចូលបន្ថែមពីស្ថាប័នពាក់ព័ន្ធ ក៏ដូចជាអ្នកជំនាញផ្សេងៗ ដើម្បីទទួលបាននូវបទប្បញ្ញត្តិមួយដែលអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព និងស្របតាមបរិបទប្រទេសកម្ពុជា។

### ៤.១.៤.៤. កសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទីផ្សារមូលបត្រ

ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទីផ្សារមូលបត្រសំដៅដល់ ក្របខណ្ឌច្បាប់សម្រាប់គ្រប់គ្រងទីផ្សារមូលបត្រ និយ័តករមូលបត្រ ទីកន្លែងសម្រាប់ជួញដូរមូលបត្រ ប្រព័ន្ធសម្រាប់ធ្វើការជួញដូរមូលបត្រ និងធនធានមនុស្សក្នុងវិស័យមូលបត្រជាដើម។ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធគតិយុត្តគឺអាទិភាពចំពោះមុខមួយយ៉ាងសំខាន់ដើម្បីធានាឲ្យដំណើរការទីផ្សារមូលបត្រ អាចប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ភាពត្រឹមត្រូវ តម្លាភាព ស្ថេរភាព ការអភិវឌ្ឍ និងផ្តល់នូវការការពារយ៉ាងប្រសើរទៅដល់សាធារណជនជាពិសេសអ្នកវិនិយោគសាធារណៈ។ បេសកម្មមួយសម្រាប់និយ័តករមូលបត្រដែលសំដៅដល់គណៈកម្មការមូលបត្រកម្ពុជា គឺការបង្កើតនូវបទប្បញ្ញត្តិដែលមានលក្ខណៈពេញលេញប្រសិទ្ធភាព និងគោរពតាមស្តង់ដារបទដ្ឋានអន្តរជាតិ។ គណៈកម្មការមូលបត្រកម្ពុជានៅមានសេចក្តីព្រាងបទប្បញ្ញត្តិគតិយុត្តជាច្រើនទៀត ដែលនឹងត្រូវប្រកាសឲ្យប្រើជាផ្លូវការនាពេលអនាគត ដើម្បីធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធគតិយុត្តក្នុងវិស័យមូលបត្រកាន់តែមានលក្ខណៈរឹងមាំ និងពេញលេញ។ ច្បាប់ស្តីពីមូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយនិងជួញដូរមូលបត្រមហាជន គឺជាគ្រឹះយ៉ាងសំខាន់សម្រាប់វិស័យមូលបត្រនៃប្រទេសកម្ពុជា និងជាវិធានគោលក្នុងការបង្កើត និងរៀបចំបទដ្ឋានគតិយុត្តផ្សេងៗទៀត។ ដោយផ្តើមចេញពីច្បាប់មូលបត្រទាំងពីរខាងលើនេះ គណៈកម្មការមូលបត្រកម្ពុជាបានរៀបចំអនុក្រឹត្យ និងប្រកាសនានាពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងជួញដូរមូលបត្រមហាជន ដើម្បីធានាបាននូវស្ថេរភាពនៃទីផ្សារមូលបត្រកម្ពុជា។

ដើម្បីឲ្យទីផ្សារមូលបត្រមួយអាចដំណើរការបាន ចាំបាច់ត្រូវមានច្បាប់សម្រាប់គ្រប់គ្រងទីផ្សារមូលបត្រ អ្នកផ្គត់ផ្គង់មូលបត្រសម្រាប់ដាក់លក់ (ក្រុមហ៊ុនបោះផ្សាយ) អ្នកទិញ-លក់មូលបត្រ (វិនិយោគិនមូលបត្រ) អ្នកជួយសម្រួលក្នុងការទិញ-លក់មូលបត្រ (ក្រុមហ៊ុនមូលបត្រ) ទីកន្លែងនិងប្រព័ន្ធសម្រាប់ធ្វើការជួញដូរមូលបត្រ និងធនធានមនុស្សជាដើម។

## ៤.២. បញ្ហាប្រឈម

ក្រៅពីឱកាស វិនិយោគិនគួរតែស្វែងយល់អំពីបញ្ហាប្រឈមមួយចំនួនដែលធ្វើឲ្យប៉ះពាល់ដល់ដំណើរការវិនិយោគផងដែរ។ កត្តាធំៗមួយចំនួនដែលវិនិយោគិនគួរយកចិត្តទុកដាក់នោះមានដូចជា៖

### ៤.២.១. អាយុកាល និងទំហំទីផ្សារ

ទីផ្សារនៅក្នុងប្រទេសកម្ពុជា ជាទីផ្សារដ៏ក្មេងខ្ចីមួយដែលទើបតែចាប់បដិសន្ធិនៅឆ្នាំ ២០១១ ប៉ុណ្ណោះ។ កត្តានេះទើបធ្វើឲ្យមានប្រជាជនកម្ពុជាចំនួនតិចតួចប៉ុណ្ណោះដែលមានចំណេះដឹង និងយល់ច្បាស់ទៅលើវិស័យនេះ។ ចំណែកឯវិនិយោគិនក៏មិនទាន់យកចិត្តទុកដាក់ខ្លាំងទៅលើការ វិនិ-យោគដែលធ្វើឲ្យការវិនិយោគក្នុងវិស័យនេះនៅមានចំនួនតិចតួច។ ចំណែកឯទំហំទីផ្សារក៏នៅមានទំហំតូចនៅឡើយ ជាក់ស្តែងមានតែក្រុមហ៊ុនចំនួន៥ប៉ុណ្ណោះបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនៅលើទីផ្សារ។ ហេតុដូច្នេះហើយ ទើបធ្វើឲ្យដំណើរការនៃការជួញដូរមិនមានភាពងាយស្រួលដល់វិនិយោគិនក្នុងការទិញ-លក់។ ពេលខ្លះមានការខ្វះខាតផលិតផលលក់នៅលើទីផ្សារ ចង់ទិញ ចង់លក់មានការលំបាក។ ដោយសារអាយុកាល និងទំហំនៅមានកម្រិត នាំឲ្យទីផ្សារមិនសូវមានលំនឹងហើយវាក៏អាចធ្វើឱ្យវិនិយោគិនមានការរារែកទៅលើការវិនិយោគផងដែរ។

### ៤.២.២. ស្ថានភាពនយោបាយ និងសេដ្ឋកិច្ច

ផ្សារមូលបត្រនៅក្នុងប្រទេសមួយអាចរីកចម្រើនលឿនទៅបាន លុះត្រាតែស្ថានភាពនយោបាយនៅក្នុងប្រទេសនោះមានស្ថេរភាពពេញលេញ។ កាលណាសង្គមមួយមិនមានការធានាច្បាស់លាស់នូវស្ថេរភាពនយោបាយផ្សារមូលបត្រមិនអាចដំណើរការទៅបាននោះទេ។ នយោបាយគ្មានស្ថេរភាពនាំឲ្យសង្គមច្របូកច្របល់ ពេលនោះវិនិយោគិននឹងបាត់បង់ទំនុកចិត្តក្នុងការវិនិយោគ

លើវិស័យមូលបត្រ ហើយការទិញ-លក់ត្រូវបានកាត់បន្ថយស្ទើរទាំងស្រុង។ ចំណែកឯកត្តាសេដ្ឋកិច្ចក៏មានឥទ្ធិពលយ៉ាងធំទៅលើ ដំណើរការលើការវិនិយោគក្នុងវិស័យមូលបត្រ ព្រោះនៅពេលដែលសេដ្ឋកិច្ចរីកចម្រើនតម្រូវការដើមទុនមានការកើនឡើង ផ្ទុយទៅវិញនៅពេលសេដ្ឋកិច្ចធ្លាក់ចុះធ្វើឲ្យវិនិយោគិនមិនមានចំណាប់អារម្មណ៍លើការវិនិយោគលើវិស័យនេះទេ ដោយសារកង្វះនូវទំនុកចិត្ត។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីការធ្វើការសិក្សាស្រាវជ្រាវ និងខិតខំប្រឹងប្រែងស្វែងយល់តាមរយៈប្រភពឯកសារនានាជាច្រើន ជាពិសេសឯកសារដែលពាក់ព័ន្ធទៅនឹងដំណើរការវិនិយោគលើផ្សារមូលបត្រនៅប្រទេសកម្ពុជាយ៉ាងយកចិត្តទុកដាក់រួចមក ក្រុមយើងខ្ញុំទទួលបានលទ្ធផលជាច្រើនដែលបញ្ជាក់ថា វិនិយោគិនមានឱកាសខ្ពស់ក្នុងការវិនិយោគលើវិស័យនេះ។ ប៉ុន្តែដោយសារវិស័យមូលបត្រជាវិស័យថ្មីមួយសម្រាប់ប្រទេសកម្ពុជា ទើបធ្វើឲ្យប្រជាជន សាធារណជន ជាពិសេសវិនិយោគិនមិនទាន់ចាប់អារម្មណ៍ខ្លាំងនៅឡើយទៅលើដំណើរការវិនិយោគទៅលើវិស័យមូលបត្រនេះ។ ដើម្បីធ្វើការវិនិយោគលើវិស័យនេះ វិនិយោគិនគប្បីយល់ឲ្យបានកាន់តែច្បាស់ទៅលើប្រតិបត្តិការនៃការវិនិយោគ និងបញ្ហាប្រឈមដើម្បីកាត់បន្ថយហានិភ័យឲ្យបានខ្ពស់បំផុត។

វិស័យមូលបត្រជាវិស័យមួយដែលអាចជួយជម្រុញសេដ្ឋកិច្ចកម្ពុជា ហើយវិស័យនេះអាចដំណើរការទៅបានអាស្រ័យដោយមានការចូលរួមយ៉ាងសកម្មពីតួអង្គសំខាន់ៗ ដែលមានដូចជានិយ័តករមូលបត្រសំដៅដល់គណៈកម្មការមូលបត្រកម្ពុជា ប្រតិបត្តិករមូលបត្រសំដៅដល់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយមូលបត្រ ក្រុមហ៊ុនមូលបត្រ វិនិយោគិនមូលបត្រ ជាពិសេសការជួយជ្រោមជ្រែងរបស់រាជរដ្ឋាភិបាល។ ដើម្បីធានាបាននូវសណ្តាប់ធ្នាប់ ការអភិវឌ្ឍន៍ប្រសិទ្ធភាព តម្លាភាព ស្ថេរភាព និងទំនុកចិត្តដល់វិនិយោគិនសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាបានចេញនូវគោលនយោបាយ បទប្បញ្ញត្តិ ក៏ដូចជាបន្តការពង្រឹងនូវហេដ្ឋារចនាសម្ព័ន្ធគតិយុទ្ធដែលជាគ្រឹះមួយដ៏រឹងមាំ។ រាជរដ្ឋាភិបាលកម្ពុជាបានចេញនូវ ច្បាប់ស្តីពីមូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនដែលជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់សម្រាប់វិស័យមូលបត្រនៃប្រទេសកម្ពុជា។ គណៈកម្មការមូលបត្រកម្ពុជា ដែលជាអាជ្ញាធរនៃវិស័យមូលបត្រកម្ពុជាមានតួនាទីគ្រប់គ្រង និងរក្សាទីផ្សារមូលបត្រកម្ពុជាប្រកបដោយប្រសិទ្ធភាព តម្លាភាព យុត្តិធម៌ និងសណ្តាប់ធ្នាប់។ ស្ថាប័នមួយនេះត្រូវបានបង្កើតឡើង និងដាក់សម្ពោធឲ្យដំណើរការជាផ្លូវការ នៅថ្ងៃ ២៩ ខែមេសា ឆ្នាំ២០០៨។ រហូតមកដល់សព្វថ្ងៃគណៈកម្មការមូលបត្រកម្ពុជាបានរៀបចំអនុក្រឹត្យ និង

ប្រកាសនានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ ដើម្បីធានាបាននូវស្ថេរភាពជានិរន្តនៃវិស័យមូលបត្រកម្ពុជា។

វត្តមាននៃទីផ្សារមូលបត្រកម្ពុជា បានផ្តល់នូវឱកាសវិនិយោគដ៏ប្រសើរសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងវិនិយោគិនសាធារណៈ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈនឹងអាចទទួលបាននូវហិរញ្ញប្បទានសម្រាប់ពង្រីកការវិនិយោគ ដែលជាឱកាសសម្រាប់ក្រុមហ៊ុនពង្រីកនូវសក្តានុពលរបស់ខ្លួន។ ក្រុមហ៊ុនបោះផ្សាយក៏អាចពង្រីកនូវកេរ្តិ៍ឈ្មោះ ដែលឆ្លុះបញ្ចាំងអំពីគុណភាពនៃទំនិញ ឬសេវាកម្មរបស់ខ្លួន នាំឲ្យមានកំណើនក្នុងការលក់ និងទទួលបានសហប្រតិបត្តិការល្អពីដៃគូវិនិយោគ។ ចំណែកឯ វិនិយោគិនសាធារណៈ អាចយកមូលធនដែលនៅទំនេររបស់ខ្លួនទៅវិនិយោគលើទីផ្សារមូលបត្រដើម្បីទទួលបាននូវភាគលាភ ឬការប្រាក់ និងផលចំណេញមូលធន។ ជាពិសេសវិនិយោគិនដែលចូលរួមក្នុងវិស័យមូលបត្រ គឺរួមចំណែកក្នុងការចូលរួមអភិវឌ្ឍវិស័យសេដ្ឋកិច្ចជាតិ ប្រសើរជាងការយកថវិការទៅផ្សងព្រេងជាមួយល្បែងស៊ីសង ដែលមិននាំមកនូវផលចំណេញសម្រាប់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ។ ក្រៅពីឱកាស បញ្ហាប្រឈមមួយចំនួនក៏អាចប៉ះពាល់ដល់ដំណើរការ ឬក៏ធ្វើឱ្យវិនិយោគិនមានការរារែកក្នុងការវិនិយោគទៅលើវិស័យមូលបត្រផងដែរ។ ជាក់ស្តែងកត្តាទាំងអស់នោះមានដូចជា កត្តាទំហំ និងអាយុកាលរបស់ផ្សារ កត្តាសេដ្ឋកិច្ច និងនយោបាយជាដើម។

សរុបមក វត្តមាននៃទីផ្សារមូលបត្រកម្ពុជា នឹងអាចចូលរួមចំណែកក្នុងការអភិវឌ្ឍលើវិស័យសេដ្ឋកិច្ចប្រទេសកម្ពុជា តាមរយៈការកៀរគរមូលធនតូច ធំដែលនៅទំនេរពីវិនិយោគិនដែលមានទៅកាន់ក្រុមហ៊ុនដែលត្រូវការមូលធនសម្រាប់ការពង្រីកអាជីវកម្មរបស់ខ្លួន។ តាមរយៈលំហូរមូលធននេះ វាបានបង្កើតនូវឱកាសការងារដល់ប្រជាជនកម្ពុជាបន្ថែម និងបានប្រើប្រាស់មូលធនអស់ពីលទ្ធភាព។ បញ្ហាមួយចំនួនក៏បានធ្វើឱ្យមានភាពរអាក់រអួលដល់ដំណើការនៃការគៀងគរនូវមូលធនពីវិនិយោគិន ទោះកាន់ក្រុមហ៊ុនសាជីវកម្ម ម្ចាស់សហគ្រាស និងក្រុមហ៊ុនដទៃទៀតដែលខ្វះខាតទុន។

## ២. ការផ្តល់អនុសាសន៍

វិស័យមូលបត្រ គឺជាវិស័យដ៏ក្មេងខ្ចីមួយសំរាប់វិនិយោគិន សាធារណៈជន និងប្រជាពលរដ្ឋទូទៅ ទើបធ្វើឱ្យពួកគេមិនសូវមានការយល់ដឹងនិងចាប់អារម្មណ៍ ដែលវាជាឧបសគ្គមួយដែលរាំងស្ទះដល់ការអភិវឌ្ឍទៅលើវិស័យនេះ។ ដើម្បីឲ្យទីផ្សារមូលបត្រនេះ អាចដំណើរការដោយមានតម្លាភាព ប្រសិទ្ធភាព និងការអភិវឌ្ឍទាមទារការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលកម្ពុជា និងការចូលរួមពីតួអង្គដែលពាក់ព័ន្ធ។ ដូចនេះក្រុមយើងខ្ញុំសូមចូលរួមផ្តល់អនុសាសន៍មួយចំនួនដូចជា៖

- គណៈកម្មការមូលបត្រកម្ពុជា គួរតែបន្ថែមការផ្សព្វផ្សាយអំពីវិស័យមូលបត្រឲ្យបានកាន់តែច្រើននិង ទូលំទូលាយជាងមុនបន្ថែមទៀតតាមរយៈ ប្រព័ន្ធផ្សព្វ ផ្សាយនានាដូចជា ទូរទស្សន៍ វិទ្យុ ទស្សនាវដ្តី កាសែត និងគេហទំព័រដើម្បីឲ្យសាធារណជនបានជ្រាបកាន់តែច្បាស់លើវិស័យនេះ។
- គណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាគួរតែរៀបចំឯកសារដែលពាក់ព័ន្ធនឹងប្រតិបត្តិការទីផ្សារជាពិសេសវិធាន យន្តការ នីតិវិធីនៃការជួញដូរ និងការកំណត់ថ្លៃមូលបត្រដោយរួមបញ្ចូលទាំងការពន្យល់លំអិត ដើម្បីបង្ហាញដល់វិនិ-យោគិនដែលបំណងចូលរួមវិនិយោគ។
- ក្រុមហ៊ុនផ្សារមូលបត្រគួរតែបង្កើតនូវកម្មវិធី វគ្គបណ្តុះបណ្តាល និងសិក្ខាសិលាឲ្យបានច្រើនបន្ថែមទៀត ហើយឲ្យបានទូលំទូលាយដល់វិនិយោគិនទាំងក្នុង និងក្រៅប្រទេសជាពិសេសសាធារណជន ប្រជាពលរដ្ឋ សិស្សានុសិស្ស និស្សិតឲ្យបានស្គាល់នឹងយល់អំពីប្រតិបត្តិការជួញដូររបស់មូលបត្រ។
- រាជរដ្ឋាភិបាលកម្ពុជា គួរតែយកចិត្តទុកដាក់នៅក្នុងការគាំទ្រនិងលើកទឹកចិត្តឲ្យមានក្រុមហ៊ុនបោះផ្សាយមូលបត្រសាធារណៈបន្ថែមទៀត ដើម្បីផ្តល់ឲ្យវិនិយោ គិនសាធា-រណៈនូវជម្រើសថ្មីបន្ថែមទៀតក្នុងការវិនិយោគលើមូលបត្រ។
- រាជរដ្ឋាភិបាលគួរតែពង្រឹងនូវនយោបាយកាត់បន្ថយអំពើពុករលួយ ជាពិសេសទៅលើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ ដែលសព្វថ្ងៃវាជាបញ្ហាចោទមួយដែលធ្វើឱ្យបណ្តាក្រុម

ហ៊ុនមានការរាំងរែកក្នុងការបោះផ្សាយលក់មូលបត្រ ទោះជាមានកិច្ចខិតខំគាំទ្រ និង លើកទឹកចិត្តខ្លាំងពីសំណាក់រាជរដ្ឋាភិបាលក៏ដោយ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងបទប្បញ្ញត្តិ


- ច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧
- ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥
- អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ ៥៤ អនក្រ/បក ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០០៩
- អនុក្រឹត្យស្តីពី ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ លេខ ០០៩ គ.ម.ក. ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩
- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា លេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨
- ប្រកាសស្តីពី វិសោធនកម្មប្រការ ២ នៃប្រកាសលេខ ០០១/១២ គ.ម.ក./ប្រ.ក ស្តីពីការកំណត់កម្រៃសេវាសម្រាប់ការផ្តល់លេខអត្តសញ្ញាណវិនិយោគិននៅក្នុងវិស័យមូលបត្រ


## ២. សៀវភៅ និងអត្ថបទស្រាវជ្រាវ


- ឈាង ហ៊ុយ (២០១៦), *មូលដ្ឋានគ្រឹះនៃការវិនិយោគ*, ភ្នំពេញ៖សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- Madura J. (1995) Financial Markets and Institutions, 3rd edition, West Publishing.


## ៣. គេហទំព័រ


- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា , ប្រវត្តិ ផ.ម.ក., (ចូលមើល ថ្ងៃទី០២ ខែ មិថុនា ឆ្នាំ ២០១៧) http://www.csx.com.kh/kh/about/profile.jsp?MNCD=10301
- គណៈកម្មការមូលបត្រកម្ពុជា, អង្គការចាត់តាំង, http://www.secc.gov.kh/khmer/m14.php?pn=1

- គណៈកម្មការមូលបត្រកម្ពុជា, អន្តរការីទីផ្សារ, http://www.secc.gov.kh/khmer/m52.php?pn=6
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, បញ្ជីឈ្មោះក្រុមហ៊ុន (ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី), http://www.csx.com.kh/jsp/data/lstppspkh_view.jsp?MNCD=5010
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, បញ្ជីឈ្មោះក្រុមហ៊ុន (កំពង់ផែស្វយ័តភ្នំពេញ), http://www.csx.com.kh/jsp/data/lstppapkh_view.jsp?MNCD=5010
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, បញ្ជីឈ្មោះក្រុមហ៊ុន (ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល), http://www.csx.om.kh/jsp/data/lstgtikh_view.jsp?MNCD=5010
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, បញ្ជីឈ្មោះក្រុមហ៊ុន (រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ), http://www.csx.com.kh/jsp/data/lstpwsakh_view.jsp?MNCD=5010
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ប្រតិបត្តិការទីផ្សារ, http://www.csx.com.kh/operation/market/listPosts.do?MNCD=3020
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ការជាត់ទាត់និងទូទាត់, http://www.csx.com.kh/operation/clearing/listPosts.do?MNCD=3030
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ការរក្សាទុកមូលបត្រ, http://www.csx.com.kh/operation/depository/listPosts.do?MNCD=3040
- KhmerForex (២០១៤), ការជួញដូរឧបករណ៍និស្សន្ទ, https://www.khmerforex.com/education/27-08-2016/1779

## ៤. សុន្ទរកថា និងបទបង្ហាញទាក់ទងនឹងវិស័យមូលបត្រ

- ទ្រី តៃហ៊ី (២០១៧), បទបង្ហាញស្តីអំពី ការយល់ដឹងពីការជួញដូរមូលបត្រនៅកម្ពុជា, https://www.facebook.com/cambodia.csx/?ref=br_tf

# ឧបសម្ព័នទី ១

# អនុក្រឹត្យស្តីពី
# ការលើកទឹកចិត្តពន្ធដារ
# ក្នុងវិស័យមូលបត្រ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០១ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែង-តាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះ-ផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្ដីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលដៅ**

អនុក្រឹត្យនេះមានគោលដៅកំណត់ពីប្រភេទ សកម្មភាព និងលក្ខខណ្ឌនានា ដែលជាកម្មវត្ថុនៃការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ។

**មាត្រា ២.- គោលបំណង**

អនុក្រឹត្យនេះមានគោលបំណងលើកទឹកចិត្តពន្ធដារ ដើម្បីអភិវឌ្ឍវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.- វិសាលភាព**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះ ÷

១. ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា គ.ម.ក.) និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ។

២. អ្នកវិនិយោគសាធារណៈ ដែលកាន់កាប់ និង/ ឬទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលដែលបានបោះផ្សាយលក់ជាសាធារណៈ និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ។ សម្រាប់គោលដៅនៃអនុក្រឹត្យនេះ អ្នកវិនិយោគសាធារណៈរួមបញ្ចូលទាំងអ្នកវិនិយោគនិវាសនជន និងអនិវាសនជន ។

## ជំពូកទី ២
## សកម្មភាព និងលក្ខខណ្ឌ នៃការលើកទឹកចិត្តពន្ធដារ

### មាត្រា ៤.- ការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញចំពោះក្រុមហ៊ុន/សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលជាសាធារណៈ

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក. និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបំពេញបែបបទជូនអគ្គនាយកដ្ឋានពន្ធដារ តាមរយៈ គ.ម.ក. ដើម្បីទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០ (ហាសិប) ភាគរយ នៃពន្ធលើប្រាក់ចំណេញត្រូវបង់ សម្រាប់រយៈពេល ៣ (បី) ឆ្នាំ ។

រយៈពេលនៃការលើកទឹកចិត្ត ៣ (បី) ឆ្នាំខាងលើនេះ ត្រូវគិតចាប់ផ្តើមពី ÷

១- ដើមឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ដើមឆ្នាំជាប់ពន្ធនោះ ។

២- ដើមឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ចុងឆ្នាំជាប់ពន្ធ ។

### មាត្រា ៥.- ការអនុគ្រោះបំណុលពន្ធលើប្រាក់ចំណេញចំពោះក្រុមហ៊ុន/សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលជាសាធារណៈ

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក. និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ត្រូវទទួលបានការអនុគ្រោះបំណុលពន្ធលើប្រាក់ចំណេញទាំងស្រុងក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ចំពោះ÷

១- បំណុលពន្ធលើប្រាក់ចំណេញដែលរកឃើញដោយស្វងការសវនកម្មឯករាជ្យ ក្រោយពេលដែលអគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មពេញលេញ (បានបិទបញ្ជី និងចេញលិខិតបញ្ជាក់សារពើពន្ធសម្រាប់កាលបរិច្ឆេទ N-1, N-2 និង N-3) ។

២- បំណុលពន្ធលើប្រាក់ចំណេញដែលរកឃើញពីកម្មវត្ថុនៃការធ្វើសវនកម្មឡើងវិញ ដោយអគ្គនាយកដ្ឋានពន្ធដារ ក្រោយពេលដែលអគ្គនាយកដ្ឋានពន្ធដារនេះបានធ្វើសវនកម្មពេញលេញ ពោលគឺនៅមុនពេលដែលក្រុមហ៊ុន/សហគ្រាស ធ្វើការបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈ ក្នុងរយៈពេល ៧ (ប្រាំពីរ) ឆ្នាំថយក្រោយ រាប់បន្ទាប់ពីឆ្នាំ N-3 ដែលបានធ្វើសវនកម្មដោយស្នងការសវនកម្មឯករាជ្យ ។ ឆ្នាំ N គឺជាឆ្នាំដែលក្រុមហ៊ុន/សហគ្រាសធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូង ។

ការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រានេះ មិនអនុវត្តចំពោះបំណុលពន្ធប្រយោលដែលជាបន្ទុករបស់អ្នកប្រើប្រាស់មានជាអាទិ៍ដូចជា អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ និងពន្ធកាត់ទុកជាដើម ។

**មាត្រា ៦.- ការលើកទឹកចិត្តពន្ធកាត់ទុកដល់អ្នកវិនិយោគមូលបត្រ**

អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយ លើការប្រាក់ និង/ឬភាគលាភ ដែលបានមកពីការកាន់កាប់ និង/ឬការទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ។

បុគ្គលជាភ្នាក់ងារកាត់ទុកដែលធ្វើការបើកការប្រាក់ និង/ឬភាគលាភ ត្រូវធ្វើការគណនាប្រាក់ពន្ធកាត់ទុកដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ មុនការបើកប្រាក់ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធកាត់ទុក ជូនរដ្ឋបាលសារពើពន្ធ ទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ (ដប់ប្រាំ) នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក ។

**មាត្រា ៧.- ក្រុមហ៊ុន/សហគ្រាសដែលមិនត្រូវបានទទួលការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញ**

ក្រុមហ៊ុន/សហគ្រាសមិនត្រូវទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុននោះជាសហគ្រាសវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលកំពុងស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨.- ការបញ្ឈប់ការលើកទឹកចិត្តពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារអាចស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈ គ.ម.ក. ដើម្បីបញ្ឈប់ការលើកទឹកចិត្តពន្ធដារ ដូចមានចែងក្នុងមាត្រា ៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ក្នុងករណីក្រុមហ៊ុន/សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក. និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ÷

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ និងបង់ប្រាក់ពន្ធ តាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ ។

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធ និងបង់ប្រាក់ពន្ធតាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ ។ លិខិតប្រកាសពន្ធសារពើពន្ធប្រចាំឆ្នាំ ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រ រួមមាន តារាងតុល្យការ គណនីលទ្ធផល តារាងចលនាសាច់ប្រាក់ និងកំណត់សម្គាល់ដោយមិនឱ្យហួសពីរយៈពេល ៣ (បី) ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ ។
- មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើសវនកម្មលើបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ ។
- មិនបានបង់ពន្ធអាករទាំងអស់ ពន្ធបន្ថែម និងការប្រាក់ ដែលបានកំណត់សម្រាប់រយៈពេលជាប់ពន្ធដែលបានធ្វើសវនកម្មរួចដោយរដ្ឋបាលសារពើពន្ធ ។

ក្នុងករណីក្រុមហ៊ុន/ សហគ្រាសដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងអនុក្រឹត្យនេះ មិនបានអនុវត្តតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យមូលបត្រ គ.ម.ក. អាចស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបញ្ឈប់ការលើកទឹកចិត្ត ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ។

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក. និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត មិនត្រូវទទួលបាននូវការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញដូចមានចែងក្នុងអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុន/សហគ្រាសនោះបានដកខ្លួនចេញពីការចុះបញ្ជីជួញដូរមូលបត្រ ឬត្រូវបានដកពីការចុះបញ្ជីជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រប្រតិស្រុត ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

### មាត្រា ៩.- ការលើកទឹកចិត្តពន្ធដារចំពោះក្រុមហ៊ុន/សហគ្រាសបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលជាសាធារណៈរួច

ក្រុមហ៊ុន/សហគ្រាសដែលទទួលបានការអនុញ្ញាតពី គ.ម.ក. ធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលជាសាធារណៈ និងដែលបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុតរួចហើយ តែមិនទាន់ទទួលបាននូវការលើកទឹកចិត្តពន្ធដារនោះ ត្រូវបានផ្តល់ការលើកទឹកចិត្តពន្ធដារ ដូចមានចែងក្នុងមាត្រា ៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ដោយគិតចាប់ពីកាលបរិច្ឆេទដែលក្រុមហ៊ុន/សហគ្រាសបានបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូង ។

### មាត្រា ១០.- ការជំនួស

អនុក្រឹត្យនេះត្រូវជំនួសអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ ។

**មាត្រា ១១.- ការអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការមូលបត្រកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៥.

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
  នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ១១ "ដើម្បីអនុវត្ត"
- គ្រប់ក្រសួង-ស្ថាប័ន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ២

# ច្បាប់ស្តីពី

# ការបោះផ្សាយ

# និង

# ការជួញដូរមូលបត្រមហាជន

នស/រកម/១០០៧/០២៨

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភានីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

2/43

# ឧបសម្ព័ន្ធទី ៣

# ប្រកាសស្តីពី

# ការបោះផ្សាយមូលបត្រ

# កម្មសិទ្ធជាសាធារណៈ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ: ០០៥/១៥ គ.ម.ក/ប្រ.ក.

# ប្រកាស
## ស្តីពី
## ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

* * * * *

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ០០១/គមក/ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងចែងអំពីបែបបទ យន្តការ នីតិវិធី និងការអនុញ្ញាតពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន÷

១-ច្បាប់ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

២-អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

៣-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចជាការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ឬការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ÷

ក-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មី ឬលើកដំបូងជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

ខ-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលធ្វើឡើងដោយក្រុមហ៊ុនធ្លាប់បានបោះផ្សាយលក់មូលបត្រជាសាធារណៈរួចហើយ។

៤-ក្រុមហ៊ុនសក្តានុពល សំដៅដល់ក្រុមហ៊ុនដែលមានលទ្ធភាពអាចធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចជាសហគ្រាសធុនតូចនិងមធ្យម ក្រុមហ៊ុនដែលទើបបង្កើតថ្មី និងក្រុមហ៊ុនដែលមានកំណើនខ្ពស់ ឬអាចមានកំណើនខ្ពស់។

៥-ក្រុមហ៊ុនហូលឌីង (Holding Company) សំដៅដល់ក្រុមហ៊ុនដែលកាន់កាប់បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ឬក្រុមហ៊ុនសម្ព័ន្ធ ដោយមានភាពជាម្ចាស់កម្មសិទ្ធិដោយកាន់កាប់ភាគហ៊ុនចំនួនច្រើន

ឬចំនួនតិចដែលមានសិទ្ធិបោះឆ្នោតគ្រប់គ្រាន់លើក្រុមហ៊ុនដែលកាន់កាប់។

៦-ភាគហ៊ុនបុរិមា (Preference share) សំដៅដល់ភាគហ៊ុនដែលអ្នកកាន់កាប់គ្មានសិទ្ធិបោះឆ្នោត និងមានសិទ្ធិជាអាទិភាពក្នុងការទទួលភាគលាភ។

៧-ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការកត់ត្រាមូលបត្រដែលបានបោះផ្សាយលក់ជាសាធារណៈដោយក្រុមហ៊ុនបោះផ្សាយ។

៨-ភ្នាក់ងារវាយតម្លៃ សំដៅដល់ក្រុមហ៊ុនដែលមានសកម្មភាពធុរកិច្ចក្នុងការវាយតម្លៃទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៩-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Securities Transfer Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការផ្ទេរមូលបត្រ។

១០-ភ្នាក់ងារទូទាត់ (Paying Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការទូទាត់ជំនួសឱ្យក្រុមហ៊ុនបោះផ្សាយ។

១១-មូលបត្រកម្មសិទ្ធិ សំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត រួមទាំងនីតិបុគ្គលបរទេសប្រហាក់ប្រហែល ហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា។

១២-សិទ្ធិបរិវត្តន៍ (Conversion Rights) សំដៅដល់សិទ្ធិក្នុងការផ្ទេរពីភាគហ៊ុនបុរិមាទៅជាមូលបត្រកម្មសិទ្ធិធម្មតា។

**ប្រការ ៣.-**

សំណើលក់មូលបត្រកម្មសិទ្ធិ អាចជាសំណើលក់ជាឯកជន ឬសំណើលក់ជាសាធារណៈ។

សំណើលក់មូលបត្រកម្មសិទ្ធិដែលបំពេញលក្ខខណ្ឌដូចខាងក្រោម ត្រូវចាត់ទុកថាជាសំណើលក់មូល-បត្រកម្មសិទ្ធិជាឯកជន÷

១-សំណើលក់មូលបត្រដែលធ្វើឡើងចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០ (សាមសិប) រូប និង

២-សំណើលក់មូលបត្រមិនត្រូវផ្សព្វផ្សាយជាសាធារណៈ ទោះបីតាមមធ្យោបាយណាក៏ដោយ រួមទាំងការផ្សព្វផ្សាយក្នុងគោលបំណងគ្រាន់តែឱ្យមកសាកសួរព័ត៌មាន ឬសុំពិគ្រោះយោបល់អំពីការធ្វើវិនិយោគលើមូលបត្រ។

បុគ្គលដែលមានបំណងធ្វើសំណើលក់មូលបត្រជាឯកជន ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងសំណើលក់នោះមក **គ.ម.ក.** ហើយនៅពេលដែលសំណើលក់ជាឯកជននោះបានបញ្ចប់ បុគ្គលត្រូវរាយការណ៍ពីលទ្ធផល

ឱ្យបានឆាប់ជូន **គ.ម.ក.**។ ចំពោះបុគ្គលដែលបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈ ហើយមានសំណើធ្វើប្រតិបត្តិការដាក់លក់ជាឯកជន បុគ្គលត្រូវរាយការណ៍ពីលទ្ធផលភ្លាមជូន **គ.ម.ក.**។

សំណើលក់មូលបត្រកម្មសិទ្ធិទាំងឡាយណាដែលខុសពីលក្ខខណ្ឌខាងលើ គឺជាសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលតម្រូវឱ្យអនុវត្តតាមនីតិវិធីដូចមានចែងក្នុងច្បាប់ អនុក្រឹត្យ និងក្នុងប្រកាសនេះ។

## ជំពូកទី ២
## ការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

### ប្រការ ៤.-

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១-ត្រូវអនុវត្តតាមលក្ខខណ្ឌអភិបាលកិច្ចសាជីវកម្មដែលកំណត់ដោយ **គ.ម.ក.**។

២-ត្រូវមានសកម្មភាពធុរកិច្ចសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច សង្គម និងធានានិរន្តរភាពប្រតិបត្តិការធុរកិច្ច។

៣-ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ (Historical Financial Statements) និង/ឬរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម (Consolidated Historical Financial Statements) រយៈពេល ២ (ពីរ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត និងរយៈពេល ១ (មួយ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត ដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ករណីបុគ្គលដាក់ពាក្យស្នើសុំដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ នៅក្រោយរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស បុគ្គលដាក់ពាក្យស្នើសុំនោះត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា។

៤-ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

៥-ត្រូវមានឯកសារផ្តល់ព័ត៌មានដូចមានកំណត់ក្នុងប្រការ ៧ នៃប្រកាសនេះ។

### ប្រការ ៥.-

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវ÷

១- ដាក់ពាក្យស្នើសុំតាមទម្រង់កំណត់ដោយ **គ.ម.ក.**។

២- ដាក់ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ **គ.ម.ក.**។

៣- ដាក់ឯកសារភ្ជាប់ដូចមានកំណត់ក្នុងប្រកាសនេះ។

**ប្រការ ៦.-**

ក្រុមហ៊ុនបោះផ្សាយត្រូវសុំការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅ **គ.ម.ក.** ដោយអនុលោមតាមមាត្រា១២ នៃច្បាប់ និងមាត្រា ៩ មាត្រា ១០ មាត្រា ១១ និងមាត្រា ១៣ នៃអនុក្រឹត្យ។

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចមានកំណត់ពីប្រការ ៧ ដល់ប្រការ ២៦ នៃប្រកាសនេះ។ ឯកសារផ្តល់ព័ត៌មានត្រូវមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល នាយកប្រតិបត្តិរបស់ក្រុមហ៊ុនបោះផ្សាយ និងនាយកហិរញ្ញវត្ថុ។

**ប្រការ ៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចខាងក្រោម÷

១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងសំណើបោះផ្សាយ

២- ព័ត៌មានស្តីពីកត្តាហានិភ័យ

៣- ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

៤- ផែនការវិនិយោគ

៥- ការពិពណ៌នាអំពីធុរកិច្ច

៦- ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ

៧- ការពិពណ៌នាអំពីអចលកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

៨- ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ

៩- ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក

១០- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

១១- ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

១២- ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

១៣- សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅឱ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

១៤- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក

១៥- ទ្រព្យសកម្មសុទ្ធ និងប្រាក់ចំណេញក្នុងមួយឯកតានៃមូលបត្រកម្មសិទ្ធិ

១៦- កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

១៧- ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់

១៨- សិទ្ធិរបស់កម្មសិទ្ធិករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់

១៩- ព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម។

**ប្រការ ៨.-**

ឯកសារផ្តល់ព័ត៌មានត្រូវពណ៌នាអំពីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ រួមទាំងព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយដូចខាងក្រោម÷

១- ឈ្មោះក្រុមហ៊ុនបោះផ្សាយ

២- ចំនួន និងប្រភេទមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយ

៣- តម្លៃលក់មូលបត្រកម្មសិទ្ធិក្នុងមួយឯកតា និងតម្លៃសរុប

៤- ឈ្មោះ និងអាសយដ្ឋានក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញ

៥- ថ្ងៃបើក និងថ្ងៃបិទការធ្វើបរិវិសកម្ម

៦- កាលបរិច្ឆេទចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

៧- សេចក្តីបញ្ជាក់ថា “ព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មានត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលពាក់ព័ន្ធ និងបុគ្គលពាក់ព័ន្ធក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាននេះ”។

**ប្រការ ៩.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីកត្តាហានិភ័យដូចខាងក្រោម÷

១- ហានិភ័យហិរញ្ញវត្ថុ

២- ហានិភ័យសេដ្ឋកិច្ច

៣- ហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

៤- ហានិភ័យផ្សេងៗតាមការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១០.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីចំនួនទឹកប្រាក់ដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនីមួយៗ។

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីដំណាក់កាលនានានៃការអនុវត្ត និងការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

ប្រសិនបើសាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវប្រើប្រាស់សម្រាប់ធានាចំណាយលើកិច្ចសន្យានៃសកម្មភាពណាមួយរបស់ក្រុមហ៊ុនបោះផ្សាយ ឯកសារផ្ដល់ព័ត៌មានត្រូវបង្ហាញពីរយៈពេលសុពលភាពនៃកិច្ចសន្យាទាំងនោះ។

**ប្រការ ១១.-**

ករណីសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈពាក់ព័ន្ធនឹងផែនការវិនិយោគ ឬមានពាក់ព័ន្ធនឹងផែនការវិនិយោគលើសពី ១ (មួយ) ផែនការនីមួយៗត្រូវបង្ហាញដាច់ពីគ្នាជាទម្រង់ពេញលេញក្នុងឯកសារផ្ដល់ព័ត៌មាន។

**ប្រការ ១២.-**

ឯកសារផ្ដល់ព័ត៌មានត្រូវមានការពិពណ៌នាអំពីធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ ដូចជា÷

១-កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម និងកាលបរិច្ឆេទចាប់ផ្ដើមប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខណៈនៃធុរកិច្ចដែលក្រុមហ៊ុនបោះផ្សាយ និងសាខាក្រុមហ៊ុនបោះផ្សាយបានចូលរួម ឬនឹងចូលរួម។

២-ផលិតផលដែលជាទំនិញ ឬសេវាស្នូលរបស់ក្រុមហ៊ុនបោះផ្សាយ និងទីផ្សាររបស់ផលិតផលទាំងនោះនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

៣-ទំហំនៃការលក់ផលិតផលផ្សេងទៀតដែលមិនមែនជាផលិតផលស្នូល ហើយទទួលបានប្រាក់ចំណូលលើសពី ១០ (ដប់) ភាគរយនៃប្រាក់ចំណូលសរុបរបស់ក្រុមហ៊ុនបោះផ្សាយ។

៤-ឈ្មោះក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងធុរកិច្ចស្នូលរបស់ក្រុមហ៊ុនទាំងនោះ។

៥-វិធីសាស្ត្រចែកចាយផលិតផល។

៦-ស្ថានភាពប្រកួតប្រជែងនៃធុរកិច្ចក្នុងទីផ្សារ។

៧-វត្ថុធាតុដើម ឬធាតុចូលផ្សេងៗដែលធានាដល់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងប្រភព និងអ្នកផ្គត់ផ្គង់។

៨-តម្រូវការថាមពល ឧស្ម័ន ទឹក ឬសម្ភារៈប្រើប្រាស់ផ្សេងៗទៀតដែលចាំបាច់សម្រាប់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុន ដោយបញ្ជាក់ពីប្រភព។

៩-ឈ្មោះអតិថិជនដែលទិញផលិតផល ឬសេវារបស់ក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃផលិតផល ឬសេវាសរុប ដោយបញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើរួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១០-ឈ្មោះអ្នកផ្គត់ផ្គង់ដែលលក់ផលិតផល ឬសេវាឱ្យក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃចំនួនទឹកប្រាក់សរុបលើផលិតផល ឬសេវាទាំងអស់ដែលបានទិញដោយក្រុមហ៊ុនបោះផ្សាយ ដោយ

បញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើ រួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១១-ការពិពណ៌នាពីប្រកាសនីយបត្រតក្កកម្ម ម៉ាក ពាណិជ្ជនាម សិទ្ធិអាជីវកម្ម ឬកិច្ចព្រមព្រៀងផ្សេងទៀតពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិបញ្ញា។

១២-ចំនួនបុគ្គលិកសរុប និងចំនួនបុគ្គលិកធ្វើការពេញម៉ោង។

១៣-សក្តានុពលនៃសមត្ថភាពផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ និងបញ្ជាក់ពីកម្រិតសមត្ថភាពដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។

១៤-ប្រសិនបើក្រុមហ៊ុនបោះផ្សាយជាក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពេញលេញស្តីពីប្រតិបត្តិការសំខាន់រវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីង ដោយបញ្ជាក់ពីលក្ខណៈនៃប្រតិបត្តិការ និងចំនួនទឹកប្រាក់ដែលបានធ្វើក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

**ប្រការ ១៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវពិពណ៌នាអំពីការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ ដូចខាងក្រោម÷

១-លទ្ធផលប្រតិបត្តិការ។

២-សន្ទនីយភាព និងប្រភពទុន។

៣-ការស្រាវជ្រាវ និងការអភិវឌ្ឍ។

៤-ព័ត៌មាននិន្នាការ និងការព្យាករណ៍ប្រាក់ចំណេញ និងលំហូរសាច់ប្រាក់ សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

**ប្រការ ១៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ពាក់ព័ន្ធនឹងអចលកម្មទ្រព្យរបស់ក្រុមហ៊ុនបោះផ្សាយ ដូចខាងក្រោម÷

១-ទីតាំងប្រតិបត្តិការ និងទីតាំងអចលកម្មទ្រព្យរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខខណ្ឌនៃអចលកម្មទ្រព្យទាំងនោះ។

២-សេចក្តីបញ្ជាក់អំពីកម្មសិទ្ធិលើអចលកម្មទ្រព្យរបស់ក្រុមហ៊ុនបោះផ្សាយ។ ប្រសិនបើអចលកម្មទ្រព្យទាំងនោះទទួលបានមកតាមរយៈការជួល ត្រូវមានការបញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់នៃការជួល ព្រមទាំងឈ្មោះម្ចាស់អចលកម្មទ្រព្យ។

៣-ការវាយតម្លៃលើអចលកម្មទ្រព្យរបស់ក្រុមហ៊ុនបោះផ្សាយធ្វើឡើងដោយភ្នាក់ងារវាយតម្លៃដែលទទួល

បានការទទួលស្គាល់ពី **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ ប្រសិនមាន។

៤-ប្រសិនបើអចលកម្មរូបីដែលក្រុមហ៊ុនបោះផ្សាយកំពុងប្រើប្រាស់ជាប់នូវប្រាតិភោគភណ្ឌិក ក្រុមហ៊ុនបោះផ្សាយត្រូវបញ្ជាក់ពីអត្តសញ្ញាណរបស់ម្ចាស់ទ្រព្យនោះ ព្រមទាំងតម្លៃដើម និងតម្លៃបច្ចុប្បន្នរបស់ប្រាតិភោគភណ្ឌិក។

**ប្រការ ១៥.-**

ករណីមានការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ស្តីពីការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ ដោយបង្ហាញនូវ÷

១-ព័ត៌មានសង្ខេបពីការវាយតម្លៃ ឬការវាយតម្លៃឡើងវិញរួមមានតម្លៃទ្រព្យសកម្មមុនពេលធ្វើការវាយតម្លៃឡើងវិញ សមាសធាតុនៃទ្រព្យដែលបានវាយតម្លៃឡើងវិញ ដោយត្រូវដាក់ដោយឡែកក្នុងលក្ខណៈមួយដែលជួយសម្រួលដល់ការប្រៀបធៀបរវាងតម្លៃចារឹក និងតម្លៃដែលបង្ហាញក្រោយពីបានវាយតម្លៃឡើងវិញ និងត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ។

២-ហេតុផលនៃការវាយតម្លៃ ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ។

៣-អត្តសញ្ញាណ និងគុណវុឌ្ឍិរបស់ភ្នាក់ងារវាយតម្លៃ។

**ប្រការ ១៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក ដូចខាងក្រោម÷

១-ជីវប្រវត្តិសង្ខេប ដោយមានបញ្ជាក់ពីឈ្មោះ អាយុ គុណវុឌ្ឍិ បទពិសោធន៍ និងតំណែងរបស់អភិបាលម្នាក់ៗរបស់ក្រុមហ៊ុនបោះផ្សាយ និងបុគ្គលដែលត្រូវបានតែងតាំងជាអភិបាល ដោយបង្ហាញពីអណត្តិនៃការតែងតាំង និងស្ថាប័នដែលបានតែងតាំងអភិបាលនោះ។

២-កាលបរិច្ឆេទក្លាយជាអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយជាលើកដំបូង និងកាលបរិច្ឆេទបញ្ចប់អណត្តិបច្ចុប្បន្ន។

៣-ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬជាសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត ត្រូវបង្ហាញឈ្មោះក្រុមហ៊ុនពាក់ព័ន្ធទាំងនោះ។

៤-ទំនាក់ទំនងសាច់ញាតិ ក្នុងចំណោមអភិបាល និងបុគ្គលិកជាន់ខ្ពស់។

៥-ឈ្មោះ រួមទាំងតំណែង គុណវុឌ្ឍិអប់រំ កាលបរិច្ឆេទចូលរួមជាមួយក្រុមហ៊ុនបោះផ្សាយ បទពិសោធន៍ ៥ (ប្រាំ) ឆ្នាំចុងក្រោយរបស់អគ្គនាយក អគ្គនាយករង នាយកប្រតិបត្តិ នាយកហិរញ្ញវត្ថុ លេខាធិការក្រុមហ៊ុន អ្នកប្រឹក្សាយោបល់ និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

៦-សេចក្តីបញ្ជាក់អំពីអសាធនភាពរបស់ភាគហ៊ុនិករបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ភាគហ៊ុន ចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ។

ឯកសារផ្តល់ព័ត៌មានត្រូវភ្ជាប់នូវឯកសារដូចខាងក្រោម÷

១-ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ។

២-របាយការណ៍របស់អភិបាលស្តីពីការវាយតម្លៃស្ថានភាពរបស់ក្រុមហ៊ុនបោះផ្សាយ។

**ប្រការ ១៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញអំពីការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់ដែលបានកើតឡើងនៅក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំចុងក្រោយ ដូចខាងក្រោម÷

១-បណ្តឹងពាក់ព័ន្ធនឹងក្ស័យធនធ្វើឡើងចំពោះក្រុមហ៊ុនដែលបុគ្គលិកជាន់ខ្ពស់ ឬអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់ជាអភិបាល បុគ្គលិក ឬជាសហកម្មសិទ្ធិករ។

២-ការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬកំពុងស្ថិតនៅក្នុងនីតិវិធីតុលាការចំពោះអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៣-ការសម្រេចជាស្ថាពរ ឬជាបណ្តោះអាសន្នរបស់តុលាការមានសមត្ថកិច្ចចំពោះអភិបាល បុគ្គលិកជាន់ខ្ពស់ ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះ នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

៤-ការសម្រេចរបស់គណៈកម្មការមូលបត្រកម្ពុជា ឬគណៈកម្មការមូលបត្របរទេស ឬនិយ័តករនៃវិស័យផ្សេងទៀត ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

**ប្រការ ១៨.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញអំពីទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ ដោយពិពណ៌នាអំពីប្រតិបត្តិការសំខាន់ៗ ក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយផ្តល់ឈ្មោះ ទំនាក់ទំនង ទំហំ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងរវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងបុគ្គលជាប់ពាក់ព័ន្ធ ដូចខាងក្រោម÷

១-អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាមួយ រួមទាំងអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀត ក្រៅពីក្រុមហ៊ុនបោះផ្សាយ និងអភិបាលដែលទទួលបានផលប្រយោជន៍ពីក្រុមហ៊ុនបោះផ្សាយ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ។

២-បុគ្គលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរនៅក្នុងទីផ្សារ។

៣-សមាជិកគ្រួសារផ្ទាល់របស់បុគ្គលដែលចែងក្នុងចំណុចទី ១ និងទី ២ ខាងលើ។

៤-បុគ្គលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនេះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយ ដែលបានធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ។

៥-បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលរបស់ក្រុមហ៊ុនបោះ-ផ្សាយ ដែលទំនាក់ទំនងកើតឡើងក្នុងក្របខ័ណ្ឌប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ។

**ប្រការ ១៩.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដូចខាងក្រោម÷

១-ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបានបើកឱ្យបុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ៥ (ប្រាំ) រូបរបស់ក្រុមហ៊ុនបោះផ្សាយ នៅឆ្នាំសារពើពន្ធចុងក្រោយ ដោយមានរាយនាម និងមុខតំណែងរបស់បុគ្គលិកជាន់ខ្ពស់បំផុតនោះ។

២-ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបើកឱ្យអភិបាលមិនប្រតិបត្តិ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៣-ចំនួនប្រាក់បំណាច់ ឬលាភការជាកញ្ចប់ដែលបានបើកឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៤-ចំនួនប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេល ១ (មួយ) ឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៥-ប្រសិនបើក្រុមហ៊ុនបោះផ្សាយមានបំណងបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិករបស់ក្រុមហ៊ុន នៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬអនាគត ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធក្នុងការបង្កើននោះ។

**ប្រការ ២០.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិទិញមូលបត្រកម្មសិទ្ធិរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត ដោយត្រូវបញ្ជាក់នូវ÷

១-កាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

២-ថ្លៃនៃមូលបត្រដែលត្រូវអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៣-ចំនួនមូលបត្រកម្មសិទ្ធិដែលពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៤-ថ្លៃទីផ្សាររបស់មូលបត្រកម្មសិទ្ធិនៅកាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

៥-កាលបរិច្ឆេទអស់សុពលភាពនៃសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

**ប្រការ ២១.-**

ករណីក្រុមហ៊ុនបោះផ្សាយមានប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក ក្រុមហ៊ុនបោះផ្សាយត្រូវពិពណ៌នាក្នុងឯកសារផ្តល់ព័ត៌មាននូវឈ្មោះរបស់អភិបាល និងភាគហ៊ុនិក ប្រភេទ និងតម្លៃនៃទ្រព្យសកម្ម សេវាកម្ម ប្រាក់បំណាច់ ឬលាភការដែលបានទទួល ឬផ្តល់ឱ្យក្រុមហ៊ុនបោះផ្សាយ ដោយផ្ទាល់ ឬដោយប្រយោលក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។

ប្រសិនបើក្រុមហ៊ុនបោះផ្សាយបានទិញ ឬនឹងទិញចលនទ្រព្យ និងអចលនទ្រព្យពីអភិបាល ឬភាគហ៊ុនិក ឯកសារផ្តល់ព័ត៌មានត្រូវមានបញ្ជាក់ពីវិធីសាស្ត្រនៃការកំណត់ថ្លៃ និងចំនួនទឹកប្រាក់ទូទាត់។

**ប្រការ ២២.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមុន និងក្រោយការបោះផ្សាយ និងប្រាក់ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់ នៅកាលបរិច្ឆេទនៃតារាងតុល្យការចុងក្រោយ។

**ប្រការ ២៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញអំពីកម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ក្រោមទម្រង់ជាតារាង នូវឈ្មោះរបស់បុគ្គលដែលកាន់កាប់ចាប់ពី ៥ (ប្រាំ) ភាគរយនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ដោយត្រូវបញ្ជាក់ពីចំនួន និងភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់។

ឯកសារផ្តល់ព័ត៌មានត្រូវមានតារាងដែលបង្ហាញពីចំនួនមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ដោយអភិបាលម្នាក់ៗ បុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ៥ (ប្រាំ) រូប ដោយបញ្ជាក់ឈ្មោះ និងអាសយដ្ឋាន ព្រមទាំងបុគ្គលិកផ្សេងទៀត ក្រោមរូបភាពជាសរុប ដោយត្រូវបញ្ជាក់ជាភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់ធៀបនឹងចំនួនមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរនៅលើទីផ្សារ។

**ប្រការ ២៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានការកំណត់នូវកត្តាដែលយកមកប្រើប្រាស់ ក្នុងការដាក់តម្លៃមូលបត្រកម្មសិទ្ធិ ដើម្បីធ្វើសំណើលក់។

**ប្រការ ២៥.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីសិទ្ធិរបស់កម្មសិទ្ធិករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើ

លក់ ដូចខាងក្រោម៖

១-ពិពណ៌នាពីសិទ្ធិទទួលភាគលាភ និងសិទ្ធិបោះឆ្នោតនៃមូលបត្រកម្មសិទ្ធិដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

២-ពិពណ៌នាសិទ្ធិទទួលភាគលាភ សិទ្ធិបោះឆ្នោត សិទ្ធិបរិវត្តន៍ និងសិទ្ធិជំរះបញ្ជី ព្រមទាំងមូលនិធិសម្រាប់ទូទាត់សងភាគហ៊ុនបុរិមាដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

៣-ប្រសិនបើមានការដាក់កំហិតណាមួយលើការបង់ភាគលាភទៅឱ្យអ្នកកាន់កាប់មូលបត្រកម្មសិទ្ធិដោយសារកិច្ចសន្យាបំណុលពាក់ព័ន្ធ ត្រូវពន្យល់ពីការដាក់កំហិតនោះ។

៤-ពិពណ៌នាពីសិទ្ធិសំខាន់ផ្សេងៗទៀតរបស់អ្នកកាន់កាប់មូលបត្រកម្មសិទ្ធិ។

**ប្រការ ២៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ (Historical Financial Information) និង/ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម (Consolidated Historical Financial Information) ដែលបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.** ហើយត្រូវភ្ជាប់របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំ និងធ្វើសវនកម្មស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២៧.-**

អនុលោមតាមមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យ អ្នកជំនាញ ឬភាគីពាក់ព័ន្ធដែលបានផ្តល់នូវការយល់ព្រមជាលាយលក្ខណ៍អក្សរលើសេចក្តីថ្លែង ឬរបាយការណ៍ ឬយោបល់ឱ្យធ្វើការផ្សព្វផ្សាយនៅក្នុងឯកសារផ្តល់ព័ត៌មាន ត្រូវទទួលខុសត្រូវលើសេចក្តីថ្លែង របាយការណ៍ ឬយោបល់ដែលបានផ្តល់ឱ្យនោះ។

**ប្រការ ២៨.-**

ក្រុមហ៊ុនបោះផ្សាយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះភាពត្រឹមត្រូវ ភាពគ្រប់គ្រាន់ និងភាពអាចជឿជាក់បាន នូវរាល់ព័ត៌មានដែលបានបង្ហាញនៅក្នុងឯកសារផ្តល់ព័ត៌មាន។

ក្រុមហ៊ុនមូលបត្រ និងបុគ្គលពាក់ព័ន្ធដទៃទៀត ដែលផ្តល់យោបល់ ឬព័ត៌មាន និងចូលរួមក្នុងការរៀបចំឯកសារផ្តល់ព័ត៌មានត្រូវទទួលខុសត្រូវចំពោះយោបល់ ឬព័ត៌មាន និងការចូលរួមនោះ។

**ប្រការ ២៩ .-**

ក្រុមហ៊ុនបោះផ្សាយត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំ នូវឯកសារដូចខាងក្រោម៖

១-លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

២-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

៣- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៤- លិខិតប្រគល់សិទ្ធិឱ្យអភិបាល ឬនាយកប្រតិបត្តិនៃក្រុមហ៊ុនបោះផ្សាយ ដែលចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

៥- កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗដែលមាន។

៦- កិច្ចសន្យាដែលត្រូវប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ប្រសិនមាន។

៧- ផែនការធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយសម្រាប់រយៈពេលយ៉ាងតិច ១ (មួយ) ឆ្នាំ។

៨- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ស្តីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៩- កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១០- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence Report) ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១១- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។

១២- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

១៣- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់។

១៤- កិច្ចព្រមព្រៀងសំខាន់ៗវិនិយោគចម្រុះ ប្រសិនមាន។

១៥- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យ ចេញដោយក្រុមហ៊ុនគណនេយ្យជំនាញដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ករណីរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី ៣ នៃប្រការ ៤ ខាងលើ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនគណនេយ្យដែលមិនមានការទទួលស្គាល់ពី **គ.ម.ក.** ។

១៦- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់បំពេញ ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.** ។

១៧- ឯកសារបញ្ជាក់លេខអត្តសញ្ញាណសារពើពន្ធ និងឯកសារបញ្ជាក់ពីការបំពេញកាតព្វកិច្ចបង់ពន្ធ។

**ប្រការ ៣០.-**

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយផ្តល់ឯកសារផ្តល់ព័ត៌មានបន្ថែម ឬឯកសារផ្តល់ព័ត៌មានជំនួស ឬសេចក្តីបញ្ជាក់ ឬសេចក្តីបំភ្លឺ។ ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញតាមសំណើនេះ ក្នុងរយៈ-ពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ឬក្នុងរយៈពេលជាក់លាក់ណាមួយដែលកំណត់ដោយអគ្គនាយកនៃ

**គ.ម.ក.** គិតចាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ករណីក្រុមហ៊ុនបោះផ្សាយមិនបំពេញបានទៅតាមសំណើខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៣១.-**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់ក្រុមហ៊ុនបោះផ្សាយ ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

១-ក្រុមហ៊ុនបោះផ្សាយមិនបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

២-ព័ត៌មាន ឬឯកសារដែលបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

៣-ក្រុមហ៊ុនបោះផ្សាយស្ថិតនៅក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ធុរកិច្ច ឬការរំលាយ។

៤-ការមិនអនុវត្តតាមទាំងស្រុង ឬមួយផ្នែកនូវសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយទូទាត់សងបំណុល។

៥-ក្រុមហ៊ុនបោះផ្សាយ ឬអភិបាលណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយ៖

ក-មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អ ស្របតាមអនុក្រឹត្យ។

ខ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

គ-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ ឬយុត្តិធម៌។

៦-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់កាន់មុខតំណែងទាំងនេះនៅក្នុងក្រុមហ៊ុនដែលត្រូវបានប្រកាសក្ស័យធន នៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-ស្ថានភាពហិរញ្ញវត្ថុ ឬវិធីធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមិនទាន់មានលក្ខណៈគ្រប់គ្រាន់

ដើម្បីធានានូវដំណើរការនៃធុរកិច្ចប្រកបដោយចីរភាព និងភាពទុកចិត្ត។

៨-នៅពេលកើតមានហេតុការណ៍ណាមួយដែលនាំឱ្យ÷

ក-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយមិនអាចដំណើរការអាជីវកម្មបានត្រឹមត្រូវ។

ខ-មានភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៩-ការផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនបោះផ្សាយ នឹងនាំឱ្យមានផលប៉ះពាល់ដល់ប្រយោជន៍សាធារណៈ ដោយត្រូវពិចារណាលើលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់។

**ប្រការ ៣២.-**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនបោះផ្សាយ ពីការមិនយល់ព្រម ឬការយល់ព្រមជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្នុងរយៈពេល ២(ពីរ) ខែគិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។

## ជំពូកទី ៣
## ការដាក់លក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

**ប្រការ ៣៣.-**

ក្រុមហ៊ុនបោះផ្សាយដែលទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចចាប់ផ្តើមធ្វើសំណើលក់មូលបត្រជាសាធារណៈបាន បន្ទាប់ពី÷

១-បានរៀបចំលក្ខខណ្ឌនៃសំណើលក់ រួមទាំងការកំណត់ថ្លៃលក់មូលបត្រដែលការកំណត់ថ្លៃលក់មូលបត្រនេះត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ។

២-បានទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចក្នុងចំណុចទី ១ ខាងលើពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១២ នៃអនុក្រឹត្យ។

៣-បានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានរបស់ក្រុមហ៊ុនបោះផ្សាយពី **គ.ម.ក.**។

**ប្រការ ៣៤.-**

បន្ទាប់ពីបានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិវិសកម្មត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព សម្រាប់រយៈពេលដូចកំណត់ក្នុងចំណុចទី ៣ នៃមាត្រា ៧ នៃអនុក្រឹត្យ។ នៅពេលការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ពេញលេញ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីពីការធ្វើបរិវិសកម្មនោះភ្លាមមក **គ.ម.ក.**។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.** ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃអនុក្រឹត្យ។ ក្រុមហ៊ុនមូលបត្រត្រូវតែរក្សាទុកប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងគណនីដោយឡែកនៅធនាគារពាណិជ្ជដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យ។ ចំនួន និងបញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ។

ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវកំណត់ដោយ **គ.ម.ក.**។ ការធ្វើបរិវិសកម្មនីមួយៗត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកធ្វើបរិវិសកម្មដែលបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្ម បានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។ អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញបានទេ លើកលែងតែករណីដូចមានចែងក្នុងចំណុចទី ៤ "ខ" នៃមាត្រា ៧ និងចំណុចទី ២ នៃមាត្រា ១៨ នៃអនុក្រឹត្យ និងប្រការ ៣៨ និងប្រការ ៣៩ នៃប្រកាសនេះ។

**ប្រការ ៣៥.-**

ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្ម ករណីមូលបត្រកម្មសិទ្ធិធ្វើបរិវិសកម្មមិនអស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចដែលមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យ ឱ្យក្រុមហ៊ុនបោះផ្សាយក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍អំពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់មក **គ.ម.ក.** ភ្លាម។

**ប្រការ ៣៦.-**

ការធ្វើបរិវិសកម្មត្រូវបានកំណត់ដូចខាងក្រោម÷

១-២០ (ម្ភៃ) ភាគរយនៃសំណើលក់ជាសាធារណៈសរុប ត្រូវបានបម្រុងសម្រាប់អ្នកវិនិយោគសញ្ជាតិខ្មែរ។

២-៨០ (ប៉ែតសិប) ភាគរយដែលនៅសល់ត្រូវបើកចំហចំពោះអ្នកវិនិយោគសញ្ជាតិខ្មែរ និងអ្នកវិនិយោគមិនមែនសញ្ជាតិខ្មែរ។

ករណីការធ្វើបរិវិសកម្មមិនអាចសម្រេចបានតាមការកំណត់ខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចធ្វើការកំណត់នូវការបែងចែកឡើងវិញ ដើម្បីធានាភាពជោគជ័យនៃសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ប្រការ ៣៧.-**

ក្រុមហ៊ុនមូលបត្រត្រូវចែកចាយលក់មូលបត្រកម្មសិទ្ធិក្នុងថ្ងៃដែលបានកំណត់នៅក្នុងឯកសារផ្តល់-

ព័ត៌មានដែលបានចុះបញ្ជីរួចនៅ **គ.ម.ក.**។

ក្រុមហ៊ុនបោះផ្សាយ ឬភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវបញ្ជូនមូលបត្រកម្មសិទ្ធិទៅឱ្យអ្នកធ្វើបរិវិសកម្ម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការធ្វើបរិវិសកម្ម។

**ប្រការ ៣៨.-**

អនុលោមតាមមាត្រា ២១ នៃច្បាប់ ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចអាចត្រូវបានព្យួរដោយអគ្គនាយកនៃ **គ.ម.ក.**។ ករណីនេះក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ឈប់ទទួលពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រ និងជូនដំណឹងអំពីការព្យួរនេះភ្លាមដល់អ្នកធ្វើបរិវិសកម្ម និងសាធារណជន។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ជាក់ជូនអ្នកធ្វើបរិវិសកម្មថាអាចមានសិទ្ធិដកស្នើការដែលបានធ្វើចំពោះសំណើលក់មូលបត្រជាសាធារណៈ និងអាចទទួលប្រាក់ដែលបានបង់នោះមកវិញ។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ អាចបន្តទទួលពាក្យស្នើសុំធ្វើបរិវិសកម្មឡើងវិញ បន្ទាប់ពីបញ្ហាដែលបណ្តាលឱ្យមានការព្យួរត្រូវបានដោះស្រាយ និងមានការអនុញ្ញាតឡើងវិញពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៩.-**

ក្រុមហ៊ុនបោះផ្សាយត្រូវផ្សព្វផ្សាយភ្លាមៗអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មានដល់សាធារណជន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបញ្ជាក់នូវចំណុចដូចខាងក្រោម÷

១-លេខស៊េរី និងកាលបរិច្ឆេទនៃការសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

២-មូលហេតុនៃការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៣-ពេលវេលា ទីកន្លែង និងរបៀបទូទាត់នៃការបង្វិលប្រាក់សងដល់អ្នកបានធ្វើបរិវិសកម្មដែលបានបង់ ឬបានតម្កល់សម្រាប់ការធ្វើបរិវិសកម្ម។ ពេលវេលានៃការបង្វិលសងនេះត្រូវធ្វើឡើងយ៉ាងយូរ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៤-ព័ត៌មានផ្សេងទៀតតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤០.-**

ការចុះបញ្ជីឯកសារផ្តល់ព័ត៌មានអាចត្រូវបានលុបចោលផងដែរ ក្នុងករណីដែលការធ្វើបរិវិសកម្មមិនបានជោគជ័យ។

**ប្រការ ៤១.-**

ក្រុមហ៊ុនបោះផ្សាយត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារ-



lyk

ណៈដែលត្រូវធ្វើឡើងក្នុងទម្រង់ដែលកំណត់ដោយ **គ.ម.ក.** ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជ អំពីចំនួនទឹកប្រាក់នៅក្នុងគណនីដោយឡែក ដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះ នៅធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ ៤២.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុត ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៤៣.-**

ក្រុមហ៊ុនបោះផ្សាយត្រូវអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចដូចមានចែងក្នុងជំពូកទី ៦ នៃច្បាប់ និងអនុក្រឹត្យ ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

## ជំពូកទី ៤
## ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ

**ប្រការ ៤៤.-**

ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មាន ឬការផ្សព្វផ្សាយសេចក្តីថ្លែងទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យ និងត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១៥ នៃអនុក្រឹត្យ។

មុននឹងទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្រុមហ៊ុនបោះផ្សាយអាចធ្វើសកម្មភាពទំនាក់ទំនងជាមួយអ្នកវិនិយោគសក្តានុពលដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រ អំពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងត្រូវភ្ជាប់មកជាមួយបញ្ជីឈ្មោះអ្នកវិនិយោគទាំងនោះ ព្រមទាំងឯកសារពាក់ព័ន្ធ។

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្រុមហ៊ុនបោះផ្សាយអាចផ្សាយពាណិជ្ជកម្ម ឬផ្សព្វផ្សាយព័ត៌មាន រួមទាំងរ៉ូដស្ងូ (Road Show) និងប្រកាសផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធនឹងការកំណត់ថ្លៃលក់មូលបត្រ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

ក្រុមហ៊ុនបោះផ្សាយត្រូវត្រៀមឯកសារផ្ដល់ព័ត៌មានសម្រាប់ផ្ដល់ឱ្យសាធារណជន នៅក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ប្រតិបត្តិករទីផ្សារមូលបត្រ និងនៅ **គ.ម.ក.** ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្ដល់ព័ត៌មានពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤៥.-**

រយៈពេលយ៉ាងតិច ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្ដើមធ្វើបរិវិសកម្ម ក្រុមហ៊ុនបោះផ្សាយត្រូវជូនដំណឹងជាផ្លូវការតាមរយៈសារព័ត៌មាន និងឧបករណ៍ផ្សព្វផ្សាយដែលទទួលស្គាល់ដោយអគ្គនាយកនៃ **គ.ម.ក.** ដោយបញ្ជាក់នូវព័ត៌មានដូចខាងក្រោម÷

១- ឈ្មោះ និងប្រទេស ឬស្ថាប័នដទៃទៀត របស់ក្រុមហ៊ុនបោះផ្សាយ។

២- ចំនួន និងឈ្មោះមូលបត្រកម្មសិទ្ធិដែលនឹងត្រូវធ្វើសំណើលក់។

៣- ទីកន្លែងដែលសាធារណជនអាចទទួលបានឯកសារផ្ដល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម។

៤- កាលបរិច្ឆេទនៃការផ្សព្វផ្សាយជាសាធារណៈនៃការជូនដំណឹងអំពីការធ្វើបរិវិសកម្មជាផ្លូវការ។

៥- សេចក្ដីថ្លែង ដើម្បីឱ្យសាធារណជនដឹងថាសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិត្រូវបានទទួលការអនុញ្ញាតពី **គ.ម.ក.** រួចហើយ។

៦- សេចក្ដីថ្លែងដើម្បីឱ្យសាធារណជនដឹងថា ការជូនដំណឹងជាផ្លូវការនេះមានគោលបំណងផ្ដល់ព័ត៌មានតែប៉ុណ្ណោះ មិនមែនដើម្បីអញ្ជើញឱ្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិឡើយ។

៧- កាលបរិច្ឆេទដែលការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនឹងចាប់ផ្ដើម។

៨- សេចក្ដីថ្លែងដែលបញ្ជាក់ថា អ្នកដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវពិចារណាដោយផ្អែកទៅលើឯកសារផ្ដល់ព័ត៌មាន។

ឯកសារផ្ដល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មដែលត្រូវផ្សព្វផ្សាយ ត្រូវធ្វើឡើងក្នុងទម្រង់បោះពុម្ព។ បន្ថែមពីនេះក្រុមហ៊ុនបោះផ្សាយអាចផ្សព្វផ្សាយឯកសារផ្ដល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិច ប៉ុន្តែក្រុមហ៊ុនបោះផ្សាយត្រូវរក្សាខ្លឹមសារនៃឯកសារផ្ដល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិចឱ្យដូចគ្នានឹងឯកសារផ្ដល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់បោះពុម្ព។

## ជំពូកទី ៥
## កម្រៃសេវាក្នុងការចុះបញ្ជី

**ប្រការ ៤៦.-**

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា និងចុះបញ្ជីឯកសារផ្ដល់ព័ត៌មាន នៅពេលដាក់ពាក្យស្នើសុំ ឱ្យ **គ.ម.ក.** ដូចខាងក្រោម÷

១- ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ១២.០០០.០០០

(ដប់ពីរលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម ត្រូវបង់ប្រាក់ចំនួន៨.០០០.០០០ (ប្រាំបីលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៤.០០០.០០០(បួនលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៧.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា ឱ្យ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួស ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ១.២០០.០០០ (មួយលានពីរសែន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែមត្រូវបង់ប្រាក់ចំនួន ៨០០.០០០ (ប្រាំបីរយពាន់) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៤០០.០០០ (បួនរយពាន់) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៨.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា ឱ្យ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំពិនិត្យឡើងវិញលើឯកសារផ្តល់ព័ត៌មានដែលអស់សុពលភាព ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៣.០០០.០០០ (បីលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម ត្រូវបង់ប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៩.-**

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាដូចមានចែងក្នុងប្រការ ៤៦ ប្រការ ៤៧ និងប្រការ ៤៨ នៃប្រកាសនេះ មិនត្រូវបានប្រគល់ឱ្យក្រុមហ៊ុនបោះផ្សាយវិញឡើយ ទោះជាឯកសារផ្តល់ព័ត៌មានទទួលបានការអនុញ្ញាត និងចុះបញ្ជី ឬត្រូវបានបដិសេធក៏ដោយ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**ប្រការ ៥០.-**

បុគ្គលដែលបំពានលើបញ្ញត្តិនៃប្រកាសនេះត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលពីអគ្គនាយកនៃ **គ.ម.ក.** ដូចខាងក្រោម÷

១- ការស្នើឱ្យដាក់អនុស្សារណៈ។

២- ការព្រមាន ឬដាស់តឿន។

៣- ការកត់សម្គាល់ជាសាធារណៈហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤- ការដាក់កំហិតលើការបោះផ្សាយមូលបត្រកម្មសិទ្ធិ។

៥- ការផ្តល់អនុសាសន៍លើការបណ្តេញអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៦- ការប្រកាសជាសាធារណៈនូវទណ្ឌកម្មទៅលើបុគ្គលដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧- ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ឬការចែកចាយបន្ទាប់។

**ប្រការ ៥១.-**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ឬក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញមូលបត្រ ឬអ្នកជំនាញ ឬភាគីពាក់ព័ន្ធ ដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ១៥.០០០.០០០ (ដប់ប្រាំលាន) រៀលដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ ៥២.-**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួល

ដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះដល់បុគ្គលពាក់ព័ន្ធអ្នកចូលរួមក្នុងទីផ្សារមូល-បត្រប្រតិស្រុត និងសាធារណជន។

**ប្រការ ៥៣.-**

ប្រកាសនេះត្រូវជំនួសប្រកាសលេខ ០០១/គមក/ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្ដីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ប្រការ ៥៤.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយក-ដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់-ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៥៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ៤

# ប្រកាសស្តីពី

# ថ្លៃសេវាពីប្រតិបត្តិការ

# ជួញដូរមូលបត្រ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខៈ...០០១/១២ [illegible]....គ.ម.ក/ប្រ.ក.

# ប្រកាស

## ស្តីពី

## ថ្លៃសេវាលើប្រតិបត្តិការជួញដូរមូលបត្រកម្មសិទ្ធិ

* * * * *

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១២

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

## ស ម្រេ ច

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅកំណត់ថ្លៃសេវាលើប្រតិបត្តិការជួញដូរមូលបត្រកម្មសិទ្ធិ សម្រាប់គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

ក្រុមហ៊ុនមូលបត្រនៃភាគីអ្នកលក់ និងក្រុមហ៊ុនមូលបត្រនៃភាគីអ្នកទិញត្រូវបង់ថ្លៃសេវាលើប្រតិបត្តិការជួញដូរមូលបត្រកម្មសិទ្ធិជូន គ.ម.ក. តាមរយៈប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

ថ្លៃសេវាលើប្រតិបត្តិការជួញដូរមូលបត្រកម្មសិទ្ធិ ដែលក្រុមហ៊ុនមូលបត្របង់ជូន គ.ម.ក. គឺក្នុងអត្រា ០,០២ (សូន្យក្បៀសសូន្យពីរ) ភាគរយ នៃតម្លៃជួញដូរមូលបត្រកម្មសិទ្ធិនីមួយៗ ដែលភាគីអ្នកលក់ និងភាគីអ្នកទិញមូលបត្រ បានធ្វើឡើងនៅក្នុងប្រតិបត្តិករទីផ្សារមូលបត្រ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

**ប្រការ ៣.-**

ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក. ត្រូវប្រមូលថ្លៃសេវាលើប្រតិបត្តិការជួញដូរមូលបត្រកម្មសិទ្ធិដូចមានចែងក្នុងប្រកាសនេះ នៅរាល់ប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រកម្មសិទ្ធិដែលបានជោគជ័យ ជូន គ.ម.ក.។

ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ត្រូវផ្តល់ជូន គ.ម.ក. នូវរបាយការណ៍ពាក់ព័ន្ធនឹងថ្លៃសេវាលើប្រតិបត្តិការជួញដូរមូលបត្រកម្មសិទ្ធិដែលប្រមូលបានដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ និងបង់ប្រាក់ថ្លៃសេវាទាំងនេះជាប្រចាំខែជូន គ.ម.ក. នៅរៀងរាល់សប្តាហ៍ទី ១ នៃខែបន្ទាប់ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក.។

**ប្រការ ៤.-**

អគ្គនាយកនៃ គ.ម.ក. អាចចាត់ឱ្យមានការត្រួតពិនិត្យ និងធ្វើសវនកម្មពាក់ព័ន្ធនឹងថ្លៃសេវាលើប្រតិបត្តិការជួញដូរមូលបត្រកម្មសិទ្ធិដូចមានកំណត់ក្នុងប្រកាសនេះ។

**ប្រការ ៥.-**

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យ និងផ្តន្ទាទោសដោយយោងទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ក្រុមហ៊ុនមូលបត្រ សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១២

គាត ឈន់

**កន្លែងទទួល ៖**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
  នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៧
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ៥
# ប្រកាសស្តីពី
# ការកំណត់កម្រៃសេវាសម្រាប់ផ្តល់
# លេខអត្តសញ្ញាណ
# វិនិយោគិននៅក្នុងវិស័យមូលបត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:....០០១/១២.គ.ម.ក/ប្រ.ក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
## ស្តីពី
## ការកំណត់តម្លៃសេវាសម្រាប់ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន នៅក្នុងវិស័យមូលបត្រ

*****

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០០១ គ.ម.ក. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- បានឃើញប្រកាសលេខ ០០៨ គ.ម.ក.ប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ
- យោងតាមការចាំបាច់របស់គណៈកម្មការមូលបត្រកម្ពុជា

# ស ម្រេ ច

**ប្រការ ១.-**

បុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិនពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) អាចធ្វើឡើងដោយផ្ទាល់មក គ.ម.ក. ឬតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក.។

**ប្រការ ២.-**

បុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត នៅពេលដាក់ពាក្យស្នើសុំ ឬស្នើសុំបន្តលេខអត្តសញ្ញាណវិនិយោគិននៅ គ.ម.ក. ទៅតាមចំនួនដូចខាងក្រោម÷

- ជាសាច់ប្រាក់ចំនួន ២០.០០០(ពីរម៉ឺន) រៀល ចំពោះរូបវន្តបុគ្គល។
- ជាសាច់ប្រាក់ចំនួន ៥០.០០០(ប្រាំម៉ឺន) រៀល ចំពោះនីតិបុគ្គល។

លេខអត្តសញ្ញាណវិនិយោគិនមានសុពលភាពសម្រាប់រយៈពេល ៣ (បី) ឆ្នាំ ឬរយៈពេលតិចជាងនេះ ដោយស្របតាមសុពលភាពនៃអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន ឬសុពលភាពអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រពាក់ព័ន្ធ។ វិនិយោគិនត្រូវដាក់ពាក្យស្នើសុំបន្តលេខអត្តសញ្ញាណវិនិយោគិន មុនពេលអស់សុពលភាពរយៈពេល ១(មួយ) ខែ។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន និងអង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១២

គណៈកម្មការមូលបត្រកម្ពុជា

គាត ឈន់

**កន្លែងទទួល÷**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ៦

# ប្រកាសស្តីពី

# ការផ្តល់អាជ្ញាបណ្ណ

# និង

# ការគ្រប់គ្រងការជួញដូរឧបករណ៍

# និស្សន្ទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:.......០០៤/១៥........គ.ម.ក/ប្រ.ក.

# ប្រកាស

# ស្តីពី

# ការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ

*****

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមស្មារតីនៃអង្គប្រជុំគណៈកម្មការមូលបត្រកម្ពុជា ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥

# ស ម្រេ ច

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99 Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.-គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់ពីវិធាននិងបទប្បញ្ញត្តិក្នុងការផ្ដល់អាជ្ញាបណ្ណ និងគ្រប់គ្រងលើការជួញដូរឧបករណ៍និស្សន្ទដោយធ្វើការកំណត់ពីលក្ខខណ្ឌនៃការផ្ដល់អាជ្ញាបណ្ណ ការអនុញ្ញាត និងកាតព្វកិច្ចនានារបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត និងបុគ្គលពាក់ព័ន្ធផ្សេងទៀត ក្នុងគោលដៅធានាបាននូវដំណើរការទីផ្សារត្រឹមត្រូវ តម្លាភាព និងការពារវិនិយោគិនសាធារណៈ ដោយអនុលោមតាមច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

### ប្រការ ២.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រកាសនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ក្រុមហ៊ុនសមភាគីកណ្ដាល** (Central Counterparty) ÷ សំដៅដល់ក្រុមហ៊ុនដែលធ្វើជាដៃគូផ្ទាល់ចំពោះរាល់កិច្ចសន្យាជួញដូរលើឧបករណ៍និស្សន្ទមួយ ឬច្រើន ពោលគឺក្លាយជាភាគីអ្នកទិញចំពោះរាល់អ្នកលក់ និងក្លាយជាភាគីអ្នកលក់ចំពោះរាល់អ្នកទិញ។

**គម្លាតថ្លៃ** (Spread) ÷ សំដៅដល់គម្លាតរវាងថ្លៃទិញ និងថ្លៃលក់នៃផលិតផល។

**ច្បាប់** (Law) ÷ សំដៅដល់ច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ឈ្មួញជើងសាឧបករណ៍និស្សន្ទ** (Derivative Broker) ÷ សំដៅដល់ក្រុមហ៊ុនដែលត្រូវទទួលបានអាជ្ញាបណ្ណ ឬក្រុមហ៊ុនមូលបត្រដែលត្រូវទទួលបានការអនុញ្ញាតពីអគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ដើម្បីធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទ។

**ប្រាក់តម្កល់ធានាអាជីវកម្ម** (Security Bond) ÷ សំដៅដល់ចំនួនសាច់ប្រាក់ដែលក្រុមហ៊ុនត្រូវដាក់តម្កល់សម្រាប់ជាប្រាក់ធានាដែលត្រូវយកមកប្រើប្រាស់ដើម្បីបំពេញកាតព្វកិច្ចហិរញ្ញវត្ថុ ក្នុងករណីដែលក្រុមហ៊ុនបញ្ចប់អាជីវកម្ម។

**ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ** (Derivative Representative) ÷ សំដៅដល់រូបវន្តបុគ្គលដែលត្រូវទទួលអាជ្ញាបណ្ណពីអគ្គនាយកនៃ គ.ម.ក. ដើម្បីបើក និងគ្រប់គ្រងគណនីឱ្យអតិថិជន និងផ្ដល់សេវាផ្សេងទៀតក្នុងនាមឈ្មួញជើងសាឧបករណ៍និស្សន្ទ។

**ម៉ាជីនដំបូង** (Initial Margin) ÷ សំដៅដល់ទំហំសាច់ប្រាក់ដំបូង ដែលត្រូវបានកំណត់គិតជាភាគរយនៃទំហំវិនិយោគសរុប ដែលអតិថិជនត្រូវដាក់តម្កល់ជាចាំបាច់ក្នុងគណនីមុនធ្វើការជួញដូរ។

**ម៉ាជីនខល** (Margin Call)÷ សំដៅដល់ការតម្រូវឱ្យអតិថិជនដាក់សាច់ប្រាក់បំពេញបន្ថែមទៅក្នុងគណនីរបស់ខ្លួន ដើម្បីឱ្យសមតុល្យគណនីកើនឡើងដល់លក្ខខណ្ឌតម្រូវ។

**ម៉ាជីនទូទាត់** (Liquidation Margin)÷ សំដៅដល់កម្រិតម៉ាជីនដែលការជួញដូរត្រូវបានទូទាត់ជាស្វ័យប្រវត្តិ នៅពេលដែលមិនមានការបំពេញបន្ថែមសាច់ប្រាក់ទៅក្នុងគណនីតាមម៉ាជីនខល។

**ទំហំជួញដូរអតិបរមា/អប្បបរមា** (Maximum/Minimum Trade Size)÷ សំដៅដល់ចំនួនឯកតាជួញដូរ (Lot) ក្នុងកម្រិតខ្ពស់បំផុត/ទាបបំផុតដែលត្រូវបានកំណត់ និងអនុញ្ញាតឱ្យធ្វើការជួញដូរ។

**ឡេវើរ៉េច** (Leverage)÷ សំដៅដល់កម្រិតដែលអនុញ្ញាតឱ្យអតិថិជន អាចធ្វើការជួញដូរបានលើសពីទំហំសាច់ប្រាក់ជាក់ស្តែងដែលខ្លួនមាន។

**អនុក្រឹត្យ** (Anukret)÷ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**អាជីវកម្មជើងសាឧបករណ៍និស្សន្ទ** (Derivative Brokerage Business)÷សំដៅដល់អាជីវកម្មផ្តល់សេវាសម្រាប់ការជួញដូរឧបករណ៍និស្សន្ទក្នុងនាមជាភ្នាក់ងាររបស់អតិថិជនខ្លួន។

**ឧបករណ៍និស្សន្ទ** (Derivative Instrument)÷ សំដៅដល់កិច្ចសន្យាលើគម្លាតថ្លៃ (Contract For Difference) នៃឧបករណ៍ហិរញ្ញវត្ថុដើមដែលចេញពីមូលបត្រកម្មសិទ្ធិ មូលបត្របំណុល សន្ទស្សន៍ លោហៈធាតុមានតម្លៃ ប្រេងឆៅ ឧស្ម័នធម្មជាតិ កសិផល រូបិយបណ្ណ រួមទាំងគម្រោងការពារថ្លៃដើម (Principal Protected Scheme) ជាដើម និងដែលត្រូវបានជួញដូរក្នុងទីផ្សារ។ ឧបករណ៍និស្សន្ទទាំងនេះគឺជាឧបករណ៍ហិរញ្ញវត្ថុដែលជាប្រភេទមួយនៃមូលបត្រ។

**ឯកតាជួញដូរ** (Lot)÷ សំដៅដល់ចំនួនឯកតានៃផលិតផលដែលត្រូវបានកំណត់សម្រាប់ការជួញដូរ។

**ឯកតានៃបម្រែបម្រួលថ្លៃ** (Pip)÷ សំដៅដល់ឯកតាបម្រែបម្រួលថ្លៃរបស់ផលិតផលក្នុងកម្រិតតូចបំផុតដែលត្រូវបានកំណត់ជាស្តង់ដា។

## ជំពូកទី ២

## ក្រុមហ៊ុនសមភាគីកណ្តាល

### ប្រការ ៣.-អាជ្ញាបណ្ណ

គ្មានបុគ្គលណាមួយអាចធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល ឬតាំងខ្លួនជាក្រុមហ៊ុនសមភាគីកណ្តាលបានទេ លើកលែងតែបុគ្គលនោះទទួលអាជ្ញាបណ្ណពីអគ្គនាយកនៃ គ.ម.ក.។

ក្រុមហ៊ុនមូលបត្រទទួលបានអាជ្ញាបណ្ណពី គ.ម.ក. អាចដាក់ពាក្យស្នើសុំការអនុញ្ញាតបន្ថែមដើម្បីធ្វើជាក្រុមហ៊ុនសមភាគីកណ្តាលដោយអនុលោមតាមប្រកាសនេះមកអគ្គនាយកនៃ គ.ម.ក.។ ក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតជាក្រុមហ៊ុនសមភាគីកណ្តាល ត្រូវធ្វើអាជីវកម្មជាក្រុមហ៊ុនសមភាគីកណ្តាលដាច់ដោយ

ឡែកពីអាជីវកម្មដែលខ្លួនមាន ដោយត្រូវមានទីតាំងអាជីវកម្ម បរិក្ខារ ប្រព័ន្ធព័ត៌មានវិទ្យា ធនធានមនុស្សដាច់ដោយឡែកពីគ្នា និងត្រូវមានរបាំងព័ត៌មាន (Chinese Wall) សមស្រប។

## ប្រការ ៤.- ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត

បុគ្គលដែលមានបំណងធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត និងបន្តអាជ្ញាបណ្ណ/ការអនុញ្ញាត តាមទម្រង់បែបបទ និងឯកសារភ្ជាប់ជូនអគ្គនាយកនៃ គ.ម.ក.។

អាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្តាលមានសុពលភាពរយៈពេល ១ (មួយ) ឆ្នាំ។ អាជ្ញាបណ្ណ/ការអនុញ្ញាតបន្តមានសុពលភាពរយៈពេល ១ (មួយ) ឆ្នាំ ចាប់ពីអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព។ ករណីបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតក្រុមហ៊ុនសមភាគីកណ្តាលត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតមកអគ្គនាយកនៃ គ.ម.ក. ក្នុងអំឡុងពេលយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព។ ការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតនៅក្រោយកាលបរិច្ឆេទដែលអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព ត្រូវបានចាត់ទុកជាការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតថ្មី។

## ប្រការ ៥.- លក្ខខណ្ឌតម្រូវចំពោះអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល

បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

១. ជាក្រុមហ៊ុនមូលធន ឬក្រុមហ៊ុនសហកម្មសិទ្ធិដែលបង្កើត និងចុះបញ្ជីពាណិជ្ជកម្មអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា

២. ត្រូវចុះបញ្ជីពន្ធដារអនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ

៣. ត្រូវមានលក្ខន្តិកៈ រចនាសម្ព័ន្ធកម្មសិទ្ធិ និងភាគហ៊ុនិកសមស្រប

៤. ត្រូវមានធនធានគ្រប់គ្រាន់ដូចជា ហិរញ្ញវត្ថុ បច្ចេកវិទ្យា និងមានសមត្ថភាពក្នុងការត្រួតពិនិត្យធុរកិច្ចពាក់ព័ន្ធដើម្បីធ្វើប្រតិបត្តិការ ព្រមទាំងមានធនធានមនុស្សប្រកបដោយចំណេះដឹង សមត្ថភាព និងបទពិសោធន៍ខ្ពស់សមស្របនឹងមុខតំណែងនីមួយៗរបស់ក្រុមហ៊ុន

៥. មានរចនាសម្ព័ន្ធគ្រប់គ្រងក្រុមហ៊ុនដែលកំណត់ច្បាស់លាស់ពីការទទួលខុសត្រូវ និងភារកិច្ចដែលអាចធានាបាននូវគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងអភិបាលកិច្ចសាជីវកម្មល្អ

៦. មានយន្តការត្រួតពិនិត្យធុរកិច្ចពាក់ព័ន្ធនឹងប្រតិបត្តិការទីផ្សារ និងការជាត់ទាត់និងទូទាត់

៧. មានហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រាន់ ដើម្បីផ្តល់សេវាកម្មជាក្រុមហ៊ុនសមភាគីកណ្តាល និងប្រព័ន្ធទ្រទ្រង់ (Backup System) សមស្រប ដើម្បីធានាបាននូវប្រតិបត្តិការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព និងមានប្រព័ន្ធដែលអាចការពារភាពលើសហួសសមត្ថភាព (Exceeded Capacity) ឬការខូចប្រព័ន្ធ (System Failure) និងដែលអាចដោះស្រាយរាល់បញ្ហាដែលអាចកើតមាន

៨. មានប្រព័ន្ធ និងគោលនយោបាយគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុងសមស្រប
៩. មានវិធាន និងយន្តការត្រួតពិនិត្យ និងដោះស្រាយទំនាស់ផលប្រយោជន៍ដែលអាចកើតមាននៅក្នុងក្រុមហ៊ុន និងការបំពេញកាតព្វកិច្ចតាមច្បាប់
១០. មានទីតាំងសមស្រប និងបំពាក់បរិក្ខារគ្រប់គ្រាន់សម្រាប់ធ្វើអាជីវកម្ម
១១. មានភាគហ៊ុនិកដែលមានលក្ខណៈសម្បត្តិ និងអត្តចរិតល្អ
១២. មានវិធានប្រតិបត្តិការដែលកំណត់អំពីភ្នាក់ងារ ប្រតិបត្តិការជួញដូរ និងការផាត់ទាត់និងទូទាត់ និងនីតិវិធីគ្រប់គ្រាន់ដើម្បីធានាឱ្យអស់ពីលទ្ធភាពថា ប្រតិបត្តិការនឹងប្រព្រឹត្តទៅប្រកបដោយភាពត្រឹមត្រូវប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ល្អ និងមានតម្លាភាព។ វិធាន និងនីតិវិធីទាំងនេះត្រូវទទួលបានការអនុញ្ញាតពី គ.ម.ក.
១៣. មិនស្ថិតនៅក្រោមករណីណាមួយដូចខាងក្រោម÷
   ក. ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ទៅ គ.ម.ក. មានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស។
   ខ. បុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ ឬរំលាយអាជីវកម្ម។
   គ. សេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុល មិនត្រូវបានអនុវត្តទាំងស្រុង ឬមួយផ្នែកដោយបុគ្គលដាក់ពាក្យស្នើសុំនោះ។
   ឃ. បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់បុគ្គលដាក់ពាក្យស្នើសុំ÷
   - បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។
   - បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិដែលការពារសាធារណជនឱ្យចៀសផុតពីការខាតបង់ផ្នែកហិរញ្ញវត្ថុ ដោយសារតែភាពមិនស្មោះត្រង់ ឬអសមត្ថភាព ឬការប្រព្រឹត្តមិនត្រឹមត្រូវរបស់បុគ្គលដាក់ពាក្យស្នើសុំនោះក្នុងការផ្តល់សេវាហិរញ្ញវត្ថុ ឬក្នុងការគ្រប់គ្រងក្រុមហ៊ុន។
   - បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។
   - ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាព ដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិត និងភាពដែលអាចទុកចិត្តបានផ្នែកហិរញ្ញវត្ថុរបស់បុគ្គលទាំងនោះ។
   - ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌនៃអាជ្ញាបណ្ណ/ការអនុញ្ញាតប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌។
   ង. អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬនៅក្រៅ

ព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

ច. នៅពេលកើតមានហេតុការណ៍ណាមួយដែលអាច÷

- នាំឱ្យបុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ មិនអាចធ្វើអាជីវកម្មបានត្រឹមត្រូវ។
- ឆ្លុះបញ្ចាំងពីភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្ម របស់បុគ្គលដាក់ពាក្យស្នើសុំ។

ឆ. បុគ្គលដាក់ពាក្យស្នើសុំមាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬការផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំ អាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

១៤. លក្ខខណ្ឌផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ គ.ម.ក.។

## ប្រការ ៦.- លក្ខខណ្ឌតម្រូវទុនមូលធន

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាក្រុមហ៊ុនសមភាគីកណ្តាលមានដើមទុនអប្បបរមាចំនួន ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល និងមូលធនសុទ្ធអប្បបរមា ១០ (ដប់) ភាគរយនៃដើមទុន និងត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១៥ (ដប់ប្រាំ) ភាគរយនៃដើមទុនក្នុងគណនីរបស់ គ.ម.ក. នៅធនាគារជាតិនៃកម្ពុជា។

ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល ត្រូវរក្សាមូលធនរួមបញ្ចូលទាំងប្រាក់ចំណេញរក្សាទុក និងប្រាក់បម្រុងរក្សាទុក ឱ្យមានសមាមាត្រជាមួយនឹងហានិភ័យពាក់ព័ន្ធនឹងសកម្មភាពនៃក្រុមហ៊ុនសមភាគីកណ្តាល និងត្រូវរក្សាមូលធនភាគហ៊ុនិកឱ្យបានយ៉ាងតិចស្មើនឹងដើមទុនអប្បបរមាដូចមានកំណត់ក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

ក្រុមហ៊ុនមូលបត្រដែលដាក់ពាក្យស្នើសុំការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល ត្រូវបន្ថែមដើមទុនតាមលក្ខខណ្ឌតម្រូវស្តីពីដើមទុនអប្បបរមាដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ និងត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មបន្ថែមដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

## ប្រការ ៧.-លក្ខខណ្ឌតម្រូវធនធានមនុស្ស

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល ត្រូវមានធនធានមនុស្សមានគុណវុឌ្ឍិ និងមានចំនួនគ្រប់គ្រាន់សម្រាប់អាជីវកម្មនេះ។

អភិបាលយ៉ាងតិច ១ (មួយ) រូប ឬនាយកប្រតិបត្តិ និងប្រធានប្រតិបត្តិការ ប្រធានផ្នែកត្រូវជាសមត្ថជន និងជានិវាសនជននៅព្រះរាជាណាចក្រកម្ពុជា។

អភិបាលយ៉ាងតិច ១ (មួយ) រូប នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ និងប្រធានផ្នែកត្រូវមាន

គុណវុឌ្ឍិ បទពិសោធន៍គ្រប់គ្រាន់ បំពេញតាមលក្ខខណ្ឌក្នុងចំណុចទី ២ និងទី ៣ នៃប្រការ ២២ នៃប្រកាសនេះ ហើយទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក. និងត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម÷

១. មានលក្ខណសម្បត្តិ និងអត្តចរិតល្អ ដូចមានចែងក្នុងមាត្រា ៤២ នៃអនុក្រឹត្យ

២. មិនធ្លាប់ត្រូវបានប្រកាសក្ស័យធន ឬមិនធ្លាប់បង្កឱ្យក្រុមហ៊ុនមួយ ឬច្រើនឈានទៅរកភាពក្ស័យធននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ

៣. មិនធ្លាប់ប្រព្រឹត្តអំពើអ្វីដែលនាំឱ្យប៉ះពាល់ដល់ដំណើរការទីផ្សារមូលបត្រ ឬនៅក្នុងវិស័យហិរញ្ញវត្ថុ

៤. មិនធ្លាប់ត្រូវបានដកតំណែង ឬបណ្តេញចេញពីតំណែង ឬពីទីផ្សារដោយយោងតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធ

៥. មិនធ្លាប់ប្រព្រឹត្តអ្វីដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈធ្ងន់ធ្ងរ។

**ប្រការ ៨.- ទម្រង់បែបបទ និងឯកសារភ្ជាប់**

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល ត្រូវបំពេញបែបបទទៅតាមទម្រង់ដែលបានកំណត់ដោយអគ្គនាយកនៃ គ.ម.ក.។ ឯកសារភ្ជាប់នៃទម្រង់ពាក្យស្នើសុំអាចមានជាអាទិ៍ដូចខាងក្រោម÷

១. វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ

២. វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម និងប័ណ្ណប៉ាតង់ ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ

៣. លក្ខន្តិកៈក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ

៤. កំណត់ហេតុប្រជុំភាគហ៊ុនិក ឬស្ថាបនិក ឬក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត

៥. លិខិតបញ្ជាក់ពីដើមទុនដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ

៦. បញ្ជីរាយនាមភាគហ៊ុនិកដោយបញ្ជាក់ពីចំនួនភាគហ៊ុននិងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លងដោយមានចុះហត្ថលេខា ឬស្នាមម្រាមដៃរបស់ភាគហ៊ុនិកនីមួយៗ

៧. បញ្ជីរាយនាមអភិបាលក្រុមហ៊ុនដោយបញ្ជាក់ពីតួនាទី និងបទពិសោធន៍ការងារ និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លង ដោយមានចុះហត្ថលេខា ឬស្នាមម្រាមដៃរបស់អភិបាលនីមួយៗ ព្រមទាំងលិខិតថ្កោលទោសច្បាប់ដើម

៨. បញ្ជីរាយនាមបុគ្គលិកជាន់ខ្ពស់ទាំងអស់របស់ក្រុមហ៊ុន ដោយបញ្ជាក់ពីតួនាទី និងបទពិសោធន៍ការងារ និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លងដោយមានចុះហត្ថលេខា ឬស្នាមម្រាមដៃរបស់បុគ្គលិកជាន់ខ្ពស់នីមួយៗ ព្រមទាំងលិខិតថ្កោលទោសច្បាប់ដើម

៩. ផែនការគ្រប់គ្រងហានិភ័យ និងផែនការយថាភាព (Contingency Plan)។

## ប្រការ ៩.- ឯកសារបន្ថែម

អគ្គនាយកនៃ គ.ម.ក. អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំធ្វើជាក្រុមហ៊ុនសមភាគីកណ្តាលផ្តល់ឯកសារបន្ថែម និងបំភ្លឺនូវចំណុច ឬព័ត៌មានផ្សេងទៀតតាមការចាំបាច់ ដើម្បីធានាថាបុគ្គលដាក់ពាក្យស្នើសុំបំពេញបានគ្រប់លក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះ។

## ប្រការ ១០.-ការផ្តល់មធ្យោបាយ និងការត្រួតពិនិត្យដល់ទីកន្លែង

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវផ្តល់មធ្យោបាយគ្រប់ប្រភេទដើម្បីឱ្យ គ.ម.ក. អាចគ្រប់គ្រង ឃ្លាំមើល ត្រួតពិនិត្យរាល់ប្រតិបត្តិការជួញដូរប្រចាំថ្ងៃ និងទិន្នន័យទាំងអស់ដែលមានក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុន។

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវផ្តល់នូវទិន្នន័យលើប្រតិបត្តិការ ឬទ្រព្យសម្បត្តិ លិខិតសំអាងសក្ខីភាព ឬសៀវភៅ និងឯកសារផ្សេងទៀតរបស់ក្រុមហ៊ុនសមភាគីកណ្តាល ឬភាគីពាក់ព័ន្ធ តាមការតម្រូវរបស់អគ្គនាយក នៃ គ.ម.ក.។

អគ្គនាយកនៃ គ.ម.ក.ត្រូវចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត និងដើម្បីធ្វើការត្រួតពិនិត្យនូវរាល់ព័ត៌មាន ទិន្នន័យ ឯកសារ និងប្រតិបត្តិការពាក់ព័ន្ធនឹងអាជីវកម្មរបស់ក្រុមហ៊ុនសមភាគីកណ្តាល។

## ប្រការ ១១.- ការផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់

មុននឹងតែងតាំង ឬផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់រួមមាន អភិបាល នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ ប្រធានផ្នែក ឬសហកម្មសិទ្ធិករ ក្រុមហ៊ុនសមភាគីកណ្តាលត្រូវសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ គ.ម.ក.។

ប្រសិនបើតំណែងរបស់បុគ្គលិកជាន់ខ្ពស់ណាមួយនៅទំនេរ ក្រុមហ៊ុនសមភាគីកណ្តាលត្រូវតែជ្រើសរើសបេក្ខជនថ្មីក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ។

## ប្រការ ១២.- ការចាប់ផ្តើមធ្វើអាជីវកម្ម

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល ត្រូវចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ/ការអនុញ្ញាត។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្តាលត្រូវស្នើសុំការអនុញ្ញាតពី គ.ម.ក.លើប្រភេទនៃឧបករណ៍និស្សន្ទនីមួយៗ ដែលត្រូវយកមកជួញដូរ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្តាលត្រូវអនុវត្តតាមកម្រិតឡេវើរ៉េច (Leverage) ឯកតាជួញដូរ (Lot) ទំហំជួញដូរអប្បបរមា/អតិបរមា (Maximum/ Minimum Trade Size) គម្លាតថ្លៃ (Spread) ឯកតានៃបម្រែបម្រួលថ្លៃ (Pip) ម៉ាជីនដំបូង (Initial Margin) ម៉ាជីនខល (Margin Call) ម៉ាជីនទូទាត់ (Liquidation Margin) ដែលកំណត់ដោយ គ.ម.ក.។

## ប្រការ ១៣.- ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃអាជ្ញាបណ្ណ/ការអនុញ្ញាត

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាក្រុមហ៊ុនសមភាគីកណ្តាលត្រូវបង់ថ្លៃពាក្យ

ស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល នៅ គ.ម.ក. នៅពេលដាក់ពាក្យស្នើសុំ និងត្រូវបង់ថ្លៃអាជ្ញាបណ្ណចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

ក្រុមហ៊ុនមូលបត្រដែលដាក់ពាក្យស្នើសុំការអនុញ្ញាត ឬបន្តការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្ដាលត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល នៅ គ.ម.ក.នៅពេលដាក់ពាក្យស្នើសុំ និងត្រូវបង់ថ្លៃការអនុញ្ញាត ឬបន្តការអនុញ្ញាតចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមប្រការនេះ មិនត្រូវបានសងត្រលប់ទៅបុគ្គលដាក់ពាក្យស្នើសុំវិញឡើយទោះបីអាជ្ញាបណ្ណ/ការអនុញ្ញាត ឬការបន្តអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវបានបដិសេធក៏ដោយ។

ក្រុមហ៊ុនសមភាគីកណ្ដាល ដែលដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាត នៅ គ.ម.ក. តិចជាង ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព ត្រូវទទួលពិន័យអន្តរការណ៍ពី គ.ម.ក. ជាសាច់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុង ១ (មួយ) ថ្ងៃចំពោះការដាក់ពាក្យស្នើសុំយឺតយ៉ាវនេះ។

**ប្រការ ១៤.-ការព្យួរ ការដកអាជ្ញាបណ្ណ/ការអនុញ្ញាត**

អគ្គនាយកនៃ គ.ម.ក. អាចចាត់វិធានការដូចមានចែងក្នុងមាត្រា ៣៤ នៃច្បាប់ ចំពោះបុគ្គលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្ដាល ក្នុងករណីដែលក្រុមហ៊ុនសមភាគីកណ្ដាលស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១. មិនបានផ្ដល់សេវាកម្ម ឬធ្វើសកម្មភាពអាជីវកម្មក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ជាប់ៗគ្នា

២. ទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ឬអាជ្ញាបណ្ណ/ការអនុញ្ញាតបន្តដោយសេចក្ដីថ្លែងមិនពិត ឬដោយមធ្យោបាយទុច្ចរិតណាមួយ

៣. មិនអាចបំពេញបានតាម ឬល្មើសនឹងលក្ខខណ្ឌអាជ្ញាបណ្ណ/ការអនុញ្ញាត និង/ឬមិនបានចាត់វិធានការកែតម្រូវតាមការតម្រូវ ឬការណែនាំកែតម្រង់របស់អគ្គនាយកនៃ គ.ម.ក.

៤. នៅតែបន្តប្រតិបត្តិការក្នុងអំឡុងពេលព្យួរអាជ្ញាបណ្ណ/ការអនុញ្ញាត

៥. ផ្អាកប្រតិបត្តិការដោយមិនបានរាយការណ៍ជាមុនទៅអគ្គនាយកនៃ គ.ម.ក.

៦. មិនអាចអនុវត្តសេចក្ដីសម្រេចរបស់តុលាការដែលតម្រូវឱ្យសងបំណុលមួយភាគ ឬទាំងស្រុងទៅបុគ្គលពាក់ព័ន្ធ

៧. កំពុងស្ថិតនៅស្ថានភាពបច្ចេកទេស និង/ឬហិរញ្ញវត្ថុទន់ខ្សោយ ឬកំពុងត្រូវរំលាយដោយគ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត ឬដោយការវិនិច្ឆ័យរបស់តុលាការទៅតាមមូលហេតុស្របច្បាប់

៨. មិនអាចបន្តគោរពតាមលក្ខខណ្ឌដូចមានកំណត់ក្នុងប្រការ៥ ប្រការ ៦ និង/ឬប្រការ ៧ នៃប្រកាសនេះ

៩. បានប្រព្រឹត្តល្មើសនឹងច្បាប់ អនុក្រឹត្យ ប្រកាសនេះ និងបទប្បញ្ញត្តិជាធរមាន។

ក្រុមហ៊ុនសមភាគីកណ្តាលដែលអាជ្ញាបណ្ណ/ការអនុញ្ញាតរបស់ខ្លួនត្រូវបានព្យួរ ឬដកហូត ចាត់ទុកថាគ្មានអាជ្ញាបណ្ណ/ការអនុញ្ញាត ចាប់ពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវបានព្យួរ ឬដកហូត។

ក្នុងករណីចាំបាច់ណាមួយ គ.ម.ក. អាចចេញសេចក្តីសម្រេចបិទអាជីវកម្មធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល ដោយជូនដំណឹងជាមុនដល់ក្រុមហ៊ុនសមភាគីកណ្តាលក្នុងរយៈពេល ៣ (បី) ខែ។

## ជំពូកទី ៣
## ឈ្មួញជើងសាឧបករណ៍និស្សន្ទ និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ

### ប្រការ ១៥- អាជ្ញាបណ្ណ

គ្មានបុគ្គលណាមួយអាចធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទ ឬតាំងខ្លួនជាឈ្មួញជើងសាឧបករណ៍និស្សន្ទបានទេ លើកលែងតែបុគ្គលនោះទទួលអាជ្ញាបណ្ណពីអគ្គនាយកនៃ គ.ម.ក.។

គ្មានជនណាមួយអាចធ្វើជាភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ឬតាំងខ្លួនជាភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ដើម្បីធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទបានទេ លើកលែងតែជននោះត្រូវបានផ្តល់អាជ្ញា-បណ្ណដោយអគ្គនាយកនៃ គ.ម.ក.។

ក្រុមហ៊ុនមូលបត្រ/ក្រុមហ៊ុនសមភាគីកណ្តាលទទួលបានអាជ្ញាបណ្ណពី គ.ម.ក.អាចដាក់ពាក្យស្នើសុំការអនុញ្ញាតបន្ថែម ដើម្បីធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទអនុលោមតាមប្រកាសនេះ មកអគ្គនាយកនៃ គ.ម.ក.។ ក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតជាឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទដាច់ដោយឡែកពីអាជីវកម្មដែលខ្លួនមាន ដោយត្រូវមានទីតាំងអាជីវកម្ម បរិក្ខារ ធនធានមនុស្សដាច់ដោយឡែកពីគ្នា និងត្រូវមានរបាំងព័ត៌មាន (Chinese Wall) សមស្រប។

### ប្រការ ១៦.- អាជីវកម្មរបស់ឈ្មួញជើងសាឧបករណ៍និស្សន្ទ

ក្នុងក្របខ័ណ្ឌនៃប្រកាសនេះ ឈ្មួញជើងសាឧបករណ៍និស្សន្ទអាចធ្វើអាជីវកម្មដូចខាងក្រោម៖

១. ធ្វើការជួញដូរឧបករណ៍និស្សន្ទក្នុងនាមជាភ្នាក់ងាររបស់អតិថិជនខ្លួន។

២. ផ្តល់ប្រឹក្សាអំពីការវិនិយោគលើឧបករណ៍និស្សន្ទឬធ្វើការបោះពុម្ពផ្សាយសេចក្តីវិភាគអំពីការវិនិ-យោគលើឧបករណ៍និស្សន្ទជូនវិនិយោគិនសាធារណៈ។

### ប្រការ ១៧.- ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត

បុគ្គលដែលមានបំណងធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទ ឬភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតតាមទម្រង់បែបបទ និងឯកសារភ្ជាប់ជូនអគ្គនាយកនៃ គ.ម.ក.។

អាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទ និងអាជ្ញាបណ្ណភ្នាក់ងារជើងសាឧបករណ៍និស្សន្ទមានសុពលភាពរយៈពេល ១ (មួយ) ឆ្នាំ។ អាជ្ញាបណ្ណ/ការអនុញ្ញាតបន្តមានសុពលភាពរយៈពេល ១

(មួយ) ឆ្នាំ ចាប់ពីអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព។ ករណីបន្តអាជ្ញាបណ្ណ/ការអនុញ្ញាត ឈ្មួញជើងសាឧបករណ៍និស្សន្ទ ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតមកអគ្គនាយកនៃ គ.ម.ក.ក្នុងអំឡុងពេលយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព។ ការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតនៅក្រោយកាលបរិច្ឆេទដែលអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព ត្រូវបានចាត់ទុកជាការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតថ្មី។

អគ្គនាយកនៃគ.ម.ក.ត្រូវចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែង ដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត ដើម្បីធ្វើការត្រួតពិនិត្យនូវរាល់ព័ត៌មាន ទិន្នន័យ ឯកសារ និងប្រតិបត្តិការពាក់ព័ន្ធនឹងអាជីវកម្មរបស់ឈ្មួញជើងសាឧបករណ៍និស្សន្ទ។

**ប្រការ ១៨.- លក្ខខណ្ឌតម្រូវចំពោះអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទ**

បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១. ជាក្រុមហ៊ុនមូលធន ឬក្រុមហ៊ុនសហកម្មសិទ្ធិដែលបានចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា

២. ត្រូវចុះបញ្ជីពន្ធដារអនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ

៣. ជាភ្នាក់ងារ ឬមានគុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់ធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនដៃគូកណ្តាលណាមួយដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក. លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.

៤. មានរចនាសម្ព័ន្ធគ្រប់គ្រងដែលកំណត់ច្បាស់លាស់ពីការទទួលខុសត្រូវ និងភារកិច្ច

៥. មានហេដ្ឋារចនាសម្ព័ន្ធនិងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រាន់

៦. មានគោលនយោបាយសមស្រប និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង

៧. មានប្រព័ន្ធនិងគោលនយោបាយលើទំនាស់ផលប្រយោជន៍ និងការបំពេញកាតព្វកិច្ចតាមច្បាប់

៨. មានទីតាំងសមស្រប និងបំពាក់ប្រព័ន្ធ បរិក្ខារ សម្ភារៈជារូបវន្តគ្រប់គ្រាន់សម្រាប់ធ្វើអាជីវកម្មដូចខាងក្រោម៖

   ក. ត្រូវរៀបចំប្រព័ន្ធកុំព្យូទ័រ សម្រាប់ធ្វើអាជីវកម្មឱ្យមានលក្ខណៈស្ថិរភាព និងសុវត្ថិភាព និងមិនមានវិសមិតភាពជាមួយប្រព័ន្ធកុំព្យូទ័ររបស់ក្រុមហ៊ុនសមភាគីកណ្តាល ដែលបុគ្គលដាក់ពាក្យស្នើសុំនោះជាភ្នាក់ងារ។

   ខ. ត្រូវរៀបចំវិធានការសុវត្ថិភាព ដើម្បីទប់ស្កាត់សាធារណជនពីខាងក្រៅដែលមិនមានការអនុញ្ញាតឱ្យចូលក្នុងកន្លែងហាមឃាត់។

៩. ត្រូវមានធនធានគ្រប់គ្រាន់ដូចជា ហិរញ្ញវត្ថុ បច្ចេកវិទ្យា និងមានសមត្ថភាពដើម្បីធ្វើអាជីវកម្ម ព្រម-ទាំងមានធនធានមនុស្សប្រកបដោយចំណេះដឹង សមត្ថភាព និងបទពិសោធន៍ខ្ពស់សមស្របនឹងមុខតំណែងនីមួយៗរបស់ក្រុមហ៊ុន។

## ប្រការ ១៩.- លក្ខខណ្ឌតម្រូវទុនមូលធន

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទ ត្រូវមានដើមទុនអប្បបរមាចំនួន ១.០០០.០០០.០០០(មួយពាន់លាន) រៀល និងមូលធនសុទ្ធអប្បបរមា ១០(ដប់) ភាគរយ នៃដើមទុន និងត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១៥ (ដប់ប្រាំ) ភាគរយនៃដើមទុន ក្នុងគណនីរបស់ គ.ម.ក. នៅធនាគារជាតិនៃកម្ពុជា។

ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទ ត្រូវរក្សាមូលធនរួមបញ្ចូលទាំងប្រាក់ចំណេញរក្សាទុក និងប្រាក់បម្រុងរក្សាទុក ឱ្យមានសមាមាត្រជាមួយនឹងហានិភ័យពាក់ព័ន្ធនឹងអាជីវកម្មជើងសាឧបករណ៍និស្សន្ទ និងត្រូវរក្សាមូលធនភាគហ៊ុនិកឱ្យបានយ៉ាងតិចស្មើនឹងដើមទុនអប្បបរមាដូចមានកំណត់ក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

ករណីក្រុមហ៊ុនមូលបត្រដាក់ពាក្យស្នើសុំការអនុញ្ញាតធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទ លក្ខ-ខណ្ឌតម្រូវស្តីពីដើមទុនអប្បបរមាដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ត្រូវបានលើកលែង ប៉ុន្តែត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មបន្ថែមដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

ក្រុមហ៊ុនសមាជិកកណ្តាលដែលដាក់ពាក្យស្នើសុំការអនុញ្ញាតធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទបន្ថែម មិនតម្រូវឱ្យអនុវត្តលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

## ប្រការ ២០.-លក្ខខណ្ឌតម្រូវធនធានមនុស្ស

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើអាជីវកម្មជើងសាឧបករណ៍និស្សន្ទ ត្រូវមាន÷

១. នាយកប្រតិបត្តិ និងអភិបាល ឬសហកម្មសិទ្ធិករយ៉ាងតិច ១ (មួយ) រូប ដែលមានគុណវុឌ្ឍិអនុ-លោមតាមកថាខណ្ឌទី ៣ ប្រការ ៧ នៃប្រកាសនេះ និងត្រូវទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.។

២. ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ និងបុគ្គលិកជំនាញផ្សេងទៀត។

## ប្រការ ២១.- ទម្រង់បែបបទ និងឯកសារភ្ជាប់

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវបំពេញបែបបទទៅតាមទម្រង់ដែលបានកំណត់ដោយអគ្គនាយកនៃ គ.ម.ក.។ ឯកសារភ្ជាប់នៃទម្រង់ពាក្យស្នើសុំអាចមានជាអាទិ៍ដូចខាងក្រោម÷

១. វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ

២. វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម និងប័ណ្ណប៉ាតង់ ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ

៣. លក្ខន្តិកៈក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ

៤. កំណត់ហេតុប្រជុំភាគហ៊ុនិក ឬស្ថាបនិក ឬក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត

៥. លិខិតបញ្ជាក់ពីដើមទុនដូចមានចែងក្នុងប្រការ ១៩ នៃប្រកាសនេះ

៦. បញ្ជីរាយនាមភាគហ៊ុនិកដោយបញ្ជាក់ពីចំនួនភាគហ៊ុន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនថតចម្លង ដោយមានចុះហត្ថលេខា ឬស្នាមម្រាមដៃរបស់ភាគហ៊ុនិកនីមួយៗ

៧. បញ្ជីរាយនាមអភិបាលក្រុមហ៊ុនដោយបញ្ជាក់ពីតួនាទី និងបទពិសោធន៍ការងារនិងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លងដោយមានចុះហត្ថលេខាឬស្នាមម្រាមដៃរបស់អភិបាលនីមួយៗ ព្រមទាំងលិខិតថ្កោលទោសច្បាប់ដើម

៨. បញ្ជីរាយនាមភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ និងបទពិសោធន៍ការងារ និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនថតចម្លងដោយមានចុះហត្ថលេខាឬស្នាមម្រាមដៃរបស់ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទនីមួយៗ ព្រមទាំងលិខិតថ្កោលទោសច្បាប់ដើម។

**ប្រការ ២២.- លក្ខខណ្ឌតម្រូវចំពោះភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ**

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ត្រូវបំពេញបែបបទទៅតាមទម្រង់ដែលបានកំណត់ដោយ គ.ម.ក. និងត្រូវមានគុណវុឌ្ឍិ បទពិសោធន៍គ្រប់គ្រាន់ ហើយទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក. និងត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម÷

១. មានលក្ខណសម្បត្តិ និងអត្តចរិតល្អ ដូចមានចែងក្នុងមាត្រា ៤២ នៃអនុក្រឹត្យ

២. បំពេញលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម÷

   ក. មានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ មូលបត្រ សេដ្ឋកិច្ច ច្បាប់ គណនេយ្យ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែល

   ខ. មានបទពិសោធន៍វិជ្ជាជីវៈពាក់ព័ន្ធនឹងអាជីវកម្មជើងសាឧបករណ៍និស្សន្ទ វិស័យហិរញ្ញវត្ថុ ឬមូលបត្រ

៣. ចូលរួមការបណ្តុះបណ្តាល និងឆ្លងកាត់ការប្រឡងដែលរៀបចំដោយ គ.ម.ក. ឬស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី គ.ម.ក. ហើយលទ្ធផលប្រឡងមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការប្រកាសលទ្ធផលប្រឡង

៤. មានលិខិតបញ្ជាក់យល់ព្រមពីឈ្មួញជើងសាឧបករណ៍និស្សន្ទឱ្យបុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ

៥. មិនធ្លាប់ប្រព្រឹត្តអ្វីដែលប៉ះពាល់ដល់ប្រយោជន៍សាធារណៈធ្ងន់ធ្ងរ។

**ប្រការ ២៣.- ឯកសារបន្ថែម**

អគ្គនាយកនៃ គ.ម.ក. អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទ

ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ផ្តល់ឯកសារបន្ថែមនិងបំភ្លឺនូវចំណុច ឬព័ត៌មានផ្សេងទៀតតាមការចាំបាច់ ដើម្បីធានាថាបុគ្គលដាក់ពាក្យស្នើសុំបំពេញបានគ្រប់លក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះ។

**ប្រការ ២៤.-ការផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់**

ឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ គ.ម.ក. មុននឹងតែងតាំង ឬផ្លាស់ប្តូរនាយកប្រតិបត្តិ អភិបាល ឬសហកម្មសិទ្ធិករ។ ប្រសិនបើតំណែងសម្រាប់នាយកប្រតិបត្តិ អភិបាល ឬសហកម្មសិទ្ធិករ ឬភ្នាក់ងារជើងសាឧបករណ៍និស្សន្ទនៅទំនេរ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវជ្រើសរើសបេក្ខជនថ្មីក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ។

**ប្រការ ២៥.- ការចាប់ផ្តើមធ្វើអាជីវកម្ម**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ/ការអនុញ្ញាត។

ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ត្រូវចាប់ផ្តើមធ្វើសកម្មភាពអាជីវកម្មក្នុងរយៈពេលយ៉ាងយូរ ១ (មួយ) ខែ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។

**ប្រការ ២៦.-ការបើកគណនីជួញដូរ**

វិនិយោគិនអាចបើកគណនីជួញដូរឧបករណ៍និស្សន្ទបានមួយនៅឈ្មួញជើងសាឧបករណ៍និស្សន្ទមួយ ដោយគណនីជួញដូរនោះមានទំហំសាច់ប្រាក់មិនលើសពី ៤០.០០០.០០០ (សែសិបលាន) រៀល ឬ ១០.០០០ (ដប់ពាន់) ដុល្លារអាមេរិក។ វិនិយោគិនអាចបើកគណនីជួញដូរមានទំហំសាច់ប្រាក់លើសពីការកំណត់ខាងលើ ដោយត្រូវមានការអនុញ្ញាតដោយឡែកពីអគ្គនាយកនៃ គ.ម.ក.។

**គ.ម.ក.** អាចធ្វើការកែប្រែនូវទំហំសាច់ប្រាក់ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃប្រការនេះក្នុងរយៈពេល ២ (ពីរ) ឆ្នាំម្តង ឬតាមការចាំបាច់។

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវរៀបចំប្រព័ន្ធជួញដូរដែលតម្រូវឱ្យបិទប្រតិបត្តិការជួញដូរ (Close Positions) របស់អតិថិជនជាស្វ័យប្រវត្តក្នុងករណីអតិថិជននោះរងកំហាតដល់ ៥០ (ហាសិប) ភាគរយនៃសាច់ប្រាក់របស់ខ្លួន។

**ប្រការ ២៧.-ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃអាជ្ញាបណ្ណ/ការអនុញ្ញាត**

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀលនៅ គ.ម.ក. នៅពេលដាក់ពាក្យស្នើសុំ និងត្រូវបង់ថ្លៃអាជ្ញាបណ្ណចំនួន ១០.០០០.០០០ (ដប់លាន) រៀលសម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

ក្រុមហ៊ុនមូលបត្រ/ក្រុមហ៊ុនសមភាគីកណ្តាល ដែលដាក់ពាក្យស្នើសុំការអនុញ្ញាត ឬបន្តការអនុញ្ញាតធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់

ចំនួន ១.០០០.០០០ (មួយលាន) រៀលនៅ គ.ម.ក. នៅពេលដាក់ពាក្យស្នើសុំ និងត្រូវបង់ថ្លៃការអនុញ្ញាត ឬបន្តការអនុញ្ញាតចំនួន ៥.០០០.០០០ (ប្រាំលាន) រៀលសម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់ចំនួន ២០០.០០០ (ពីររយពាន់) រៀល នៅ គ.ម.ក. នៅពេលដាក់ពាក្យស្នើសុំ និងត្រូវបង់ថ្លៃអាជ្ញាបណ្ណចំនួន ៥០០.០០០ (ប្រាំរយពាន់) រៀលសម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមប្រការនេះ មិនត្រូវបានសងត្រលប់ទៅបុគ្គលដាក់ពាក្យស្នើសុំវិញឡើយទោះបីអាជ្ញាបណ្ណ/ការអនុញ្ញាត ឬការបន្តអាជ្ញាបណ្ណ ឬការអនុញ្ញាតត្រូវបានបដិសេធក៏ដោយ។

ឈ្មួញជើងសាឧបករណ៍និស្សន្ទ ដែលដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតនៅ គ.ម.ក. តិចជាង ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព ត្រូវទទួលពិន័យអន្តរការណ៍ពី គ.ម.ក. ជាសាច់ប្រាក់ចំនួន ៥០០.០០០ (ប្រាំរយពាន់) រៀល ក្នុង ១ (មួយ) ថ្ងៃចំពោះការដាក់ពាក្យស្នើសុំយឺតយ៉ាវនេះ។

ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដែលដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទៅ គ.ម.ក. តិចជាង ៣០ (សាមសិប) ថ្ងៃមុនកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព ត្រូវទទួលពិន័យអន្តរការណ៍ពី គ.ម.ក. ជាសាច់ប្រាក់ចំនួន១០០.០០០(មួយរយពាន់) រៀល ក្នុង១(មួយ) ថ្ងៃចំពោះការដាក់ពាក្យស្នើសុំយឺតយ៉ាវនេះ។

**ប្រការ ២៨.-ការព្យួរ និងការដកអាជ្ញាបណ្ណ/ការអនុញ្ញាត**

អគ្គនាយកនៃ គ.ម.ក. អាចចាត់វិធានការដូចមានចែងក្នុងមាត្រា ៣៤ នៃច្បាប់ ចំពោះបុគ្គលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទក្នុងករណីដែលឈ្មួញជើងសាឧបករណ៍-និស្សន្ទ ស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១. មិនបានផ្តល់សេវាកម្ម ឬធ្វើសកម្មភាពអាជីវកម្មក្នុងអំឡុងពេល ៣ (បី) ខែ ជាប់ៗគ្នា
២. ទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ឬអាជ្ញាបណ្ណ/ការអនុញ្ញាតបន្តដោយសេចក្តីថ្លែងមិនពិត ឬដោយមធ្យោបាយទុច្ចរិតណាមួយ
៣. មិនអាចបំពេញបានតាម ឬល្មើសនឹងលក្ខខណ្ឌអាជ្ញាបណ្ណ/ការអនុញ្ញាត និង/ឬមិនបានចាត់វិធានការកែតម្រូវតាមការតម្រូវ ឬការណែនាំកែតម្រង់របស់អគ្គនាយកនៃ គ.ម.ក.
៤. នៅតែបន្តប្រតិបត្តិការក្នុងអំឡុងពេលព្យួរអាជ្ញាបណ្ណ/ការអនុញ្ញាត
៥. ផ្អាកប្រតិបត្តិការដោយមិនបានរាយការណ៍ជាមុនទៅអគ្គនាយកនៃ គ.ម.ក.
៦. មិនអាចអនុវត្តសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឱ្យសងបំណុលមួយភាគ ឬទាំងស្រុងទៅបុគ្គលពាក់ព័ន្ធ

៧. កំពុងស្ថិតនៅស្ថានភាពបច្ចេកទេស និង/ឬហិរញ្ញវត្ថុទន់ខ្សោយ ឬកំពុងត្រូវរំលាយដោយគ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត ឬដោយការវិនិច្ឆ័យរបស់តុលាការទៅតាមមូលហេតុស្របច្បាប់

៨. មិនអាចបន្តគោរពតាមលក្ខខណ្ឌដូចមានកំណត់ក្នុងប្រការ ១៨ ប្រការ ១៩ និង/ឬ ប្រការ ២០ នៃប្រកាសនេះ

៩. បានប្រព្រឹត្តល្មើសនឹងច្បាប់ អនុក្រឹត្យ ប្រកាសនេះ និងបទប្បញ្ញត្តិជាធរមាន។

ឈ្មួញជើងសាឧបករណ៍និស្សន្ទដែលអាជ្ញាបណ្ណ/ការអនុញ្ញាតរបស់ខ្លួនត្រូវបានព្យួរ ឬដកហូតចាត់ទុកថាគ្មានអាជ្ញាបណ្ណ/ការអនុញ្ញាត ចាប់ពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវបានព្យួរ ឬដកហូត។

អគ្គនាយកនៃ គ.ម.ក. អាចចាត់វិធានការដូចមានចែងក្នុងមាត្រា ៣៤ នៃច្បាប់ ចំពោះបុគ្គលទទួលបានអាជ្ញាបណ្ណធ្វើជាភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ក្នុងករណីដែលភ្នាក់ងារជើងសាឧបករណ៍និស្សន្ទស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១. ទទួលមរណភាព ឬក្លាយជាជនអសមត្ថភាព

២. បញ្ឈប់ ឬមិនអាចធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារជើងសាឧបករណ៍និស្សន្ទក្នុងរយៈពេល ១ (មួយ) ខែ ដោយមិនបានជូនដំណឹងទៅអគ្គនាយកនៃ គ.ម.ក.

៣. អាជ្ញាបណ្ណនៃឈ្មួញជើងសាឧបករណ៍និស្សន្ទរបស់ភ្នាក់ងារនោះត្រូវបានព្យួរ ឬដកហូត

៤. មិនអនុវត្តតាមលក្ខខណ្ឌតម្រូវណាមួយដែលមានចែងក្នុងប្រការ ២២ នៃប្រកាសនេះ

៥. បានប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌ ឬការដាក់កំហិតលើអាជ្ញាបណ្ណ ឬសេចក្តីណែនាំណាមួយរបស់អគ្គ-នាយកនៃ គ.ម.ក. ដែលស្ថិតនៅក្រោមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ

៦. បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដែលអាជ្ញាបណ្ណរបស់ខ្លួនត្រូវបានព្យួរ ឬដកហូត ចាត់ទុកថាគ្មានអាជ្ញាបណ្ណ ចាប់ពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណត្រូវបានព្យួរ ឬដកហូត។

## ជំពូកទី ៤
## បទប្បញ្ញត្តិផ្សេងៗ

### ប្រការ ២៩.-ការទូទាត់សាច់ប្រាក់

ការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងការជួញដូរឧបករណ៍និស្សន្ទ ត្រូវធ្វើតាមរយៈភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលមានការទទួលស្គាល់ពី គ.ម.ក.។

### ប្រការ ៣០.-ថ្លៃសេវាលើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទ

ឈ្មួញជើងសាឧបករណ៍និស្សន្ទនៃភាគីអ្នកលក់ និងឈ្មួញជើងសាឧបករណ៍និស្សន្ទនៃភាគីអ្នកទិញត្រូវបង់ថ្លៃសេវាលើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទជូន គ.ម.ក. តាមរយៈក្រុមហ៊ុនសមភាគីកណ្តាលដែលបានទទួលអាជ្ញាបណ្ណ/ការអនុញ្ញាតពី គ.ម.ក. ក្នុងអត្រា ០,៣ (សូន្យក្បៀសបី) ភាគរយ នៃទំហំសាច់

ប្រាក់វិនិយោគដើមនៅរាល់ពេលមានការបើក និងបិទស្ថានភាពជួញដូរនីមួយៗ។

ក្រុមហ៊ុនសមភាគីកណ្តាល ដែលបានទទួលអាជ្ញាបណ្ណ/ការអនុញ្ញាតពី គ.ម.ក. ត្រូវប្រមូលថ្លៃសេវាលើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទ ដូចមានចែងនៅក្នុងប្រការនេះ ជូន គ.ម.ក.។

ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវស្នើសុំការអនុញ្ញាតជាមុនពី គ.ម.ក. លើការកំណត់យកកម្រៃសេវាសម្រាប់ការជួញដូរឧបករណ៍និស្សន្ទ។

ក្រុមហ៊ុនសមភាគីកណ្តាល ត្រូវផ្តល់ជូន គ.ម.ក. នូវរបាយការណ៍ពាក់ព័ន្ធនឹងថ្លៃសេវាលើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទដែលប្រមូលបានដូចមានចែងក្នុងប្រការនេះ និងបង់ប្រាក់ថ្លៃសេវាទាំងនេះជាប្រចាំខែជូន គ.ម.ក. នៅរៀងរាល់សប្តាហ៍ទី ១ នៃខែបន្ទាប់លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក.។

អគ្គនាយកនៃ គ.ម.ក. អាចចាត់ឱ្យមានការត្រួតពិនិត្យ និងសវនកម្មពាក់ព័ន្ធនឹងថ្លៃសេវាលើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទដូចមានកំណត់នៅក្នុងប្រការនេះ។

### ប្រការ ៣១.-ការជូនដំណឹងអំពីការកែប្រែឯកសារ ឬព័ត៌មាន

ក្រុមហ៊ុនសមភាគីកណ្តាល ឈ្មួញជើងសាឧបករណ៍និស្សន្ទ ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ឬបុគ្គលដាក់ពាក្យស្នើសុំ ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក គ.ម.ក. ក្នុងករណីមានការកែប្រែឯកសារ ឬព័ត៌មានពាក់ព័ន្ធនឹងពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាត។

### ប្រការ ៣២.- កាតព្វកិច្ចផ្តល់របាយការណ៍

ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទមានកាតព្វកិច្ចផ្តល់របាយការណ៍សមាយិកជូន គ.ម.ក. និងរបាយការណ៍ផ្សេងទៀត តាមការកំណត់របស់អគ្គនាយកនៃ គ.ម.ក.។ ក្នុងករណីក្រុមហ៊ុនមូលបត្រធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល ឬឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវផ្តល់របាយការណ៍សមាយិកនេះ ដាច់ដោយឡែកពីរបាយការណ៍ដែលជាកាតព្វកិច្ចរបស់ក្រុមហ៊ុនមូលបត្រ។

### ប្រការ ៣៣.- ការផ្លាស់ប្តូរ ឬការកែប្រែ

មុននឹងធ្វើការផ្លាស់ប្តូរ ឬកែប្រែរចនាសម្ព័ន្ធភាគហ៊ុនិក ដើមទុន នាមករណ៍ ទីស្នាក់ការ លក្ខន្តិកៈ ក្រុមហ៊ុនសមភាគីកណ្តាល ឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ គ.ម.ក.។

### ប្រការ ៣៤.-ការចូលរួមវគ្គបណ្តុះបណ្តាលបន្ត

អភិបាល សហកម្មសិទ្ធិករ នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ ប្រធានផ្នែកដែលទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ គ.ម.ក. និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវចូលរួមវគ្គបណ្តុះ-បណ្តាលបន្តរៀបចំដោយ គ.ម.ក. ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី គ.ម.ក. លើកលែងតែមានការកំណត់ដោយឡែកតាមស្ថានភាពជាក់ស្តែងដោយអគ្គនាយកនៃ គ.ម.ក.។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

### ប្រការ ៣៥.-ការចាត់វិធានការ

អគ្គនាយកនៃ គ.ម.ក. អាចចាត់វិធានការដូចមានចែងក្នុងមាត្រា ៣៤ នៃច្បាប់ ចំពោះបុគ្គលកាន់អាជ្ញាបណ្ណ ឬការអនុញ្ញាត ដែលប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌអាជ្ញាបណ្ណ/ការអនុញ្ញាត ឬ/និងបញ្ញត្តិណាមួយដែលមានចែងនៅក្នុងប្រកាសនេះ។

### ប្រការ ៣៦.-ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ/ការអនុញ្ញាត

បុគ្គលណាដែលធ្វើអាជីវកម្ម ឬតាំងខ្លួនធ្វើអាជីវកម្មជាក្រុមហ៊ុនសមភាគីកណ្តាល ឈ្មួញជើងសាឧបករណ៍និស្សន្ទ ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ដោយគ្មានអាជ្ញាបណ្ណ/ការអនុញ្ញាត ឬដោយអាជ្ញាបណ្ណ/ការអនុញ្ញាតអស់សុពលភាព ត្រូវផ្តន្ទាទោសតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

### ប្រការ ៣៧.-ពិន័យអន្តរការណ៍

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀត ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនសមភាគីកណ្តាល ឈ្មួញជើងសាឧបករណ៍និស្សន្ទ ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដែលប្រព្រឹត្តល្មើសនឹងប្រការ ១១ ប្រការ ១២ ប្រការ ២៤ ប្រការ ៣០ ប្រការ ៣១ ឬបញ្ញត្តិផ្សេងទៀតនៃប្រកាសនេះ ឬលក្ខខណ្ឌណាមួយដែលចែងដោយអនុលោមតាមប្រកាសនេះ ឬមិនគោរពតាមការណែនាំរបស់អគ្គនាយកនៃ គ.ម.ក. ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងប្រការ ៣៨ នៃប្រកាសនេះ និង/ឬទទួលពិន័យអន្តរការណ៍ពី គ.ម.ក. ជាប្រាក់÷

១. ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ ៥០.០០០.០០០(ហាសិបលាន) រៀល ចំពោះរូបវន្តបុគ្គល។

២. ពី ២០.០០០.០០០(ម្ភៃលាន) រៀល ទៅ ២០០.០០០.០០០(ពីររយលាន) រៀល ចំពោះនីតិបុគ្គល។

### ប្រការ ៣៨.-ទណ្ឌកម្មរដ្ឋបាល

អនុលោមតាមប្រការ ៣៧ នៃប្រកាសនេះ អគ្គនាយកនៃ គ.ម.ក.អាចសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

១. ការព្រមាន។

២. ដឹកនាំកែតម្រង់បុគ្គលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតឱ្យអនុវត្តតាមលក្ខខណ្ឌ ឬលក្ខខណ្ឌបន្ថែម។

៣. ដាក់កំហិតលើអាជ្ញាបណ្ណ/ការអនុញ្ញាត។

៤. ព្យួរអាជ្ញាបណ្ណ/ការអនុញ្ញាត។

៥. ដកហូតអាជ្ញាបណ្ណ/ការអនុញ្ញាត។

# ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**ប្រការ ៣៩.-គោលការណ៍ណែនាំផ្សេងៗ**

គ.ម.ក. អាចចេញគោលការណ៍ណែនាំ អនុលោមតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្ត។

**ប្រការ ៤០.-បដិវាទកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤១.-ការអនុវត្ត**

អគ្គនាយកនៃ គ.ម.ក. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន អង្គភាពដទៃទៀតដែលចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១៥

**បណ្ឌិត. អួន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤១

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ